ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឯកសារជំនួយស្មារតី

# គ្រូបង្រៀន
# វិទ្យាល័យអប់រំពិសេស

នាយកដ្ឋានអប់រំពិសេស
តុលា ២០២៣

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងអនុវត្តគោលនយោបាយ ស្តីពីការអប់រំបរិយាបន្ន ដែលមានលក្ខណៈទូលំទូលាយ ដើម្បីធានាឱ្យកុមារស្ថិតក្នុងសេចក្តីត្រូវការពិសេសគ្រប់រូបទទួលបានសិទ្ធិក្នុងការអប់រំដូចកុមារទូទៅប្រកបដោយសមធម៌ និងបរិយាបន្ន។ យុទ្ធសាស្ត្រនៃគោលនយោបាយ និងផែនការសកម្មភាព ស្តីពីការអប់រំបរិយាបន្ន ឆ្នាំ២០១៩-២០២៣ មានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីពិការភាព ជួយគាំទ្រដល់កុមារមានពិការភាព កុមារជួបការលំបាក និងកុមារស្ថិតក្នុងសេចក្តីត្រូវការពិសេស ទទួលបានការអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងចំណូលចិត្តរបស់ពួកគេ និងដើម្បីសម្រេចបានតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ និងឆ្ពោះទៅឆ្នាំ២០៣០។

ការអប់រំបរិយាបន្ន គឺជាសិទ្ធិមូលដ្ឋានរបស់សិស្សគ្រប់គ្នា និងជាកត្តាមួយយ៉ាងសំខាន់ក្នុងការរួមចំណែកលើកកម្ពស់គុណភាពអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ហើយដើម្បីឱ្យការបង្រៀន និងរៀនកាន់តែប្រសើរឡើង ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយដៃគូអភិវឌ្ឍកសាងឯកសារជំនួយស្មារតីសម្រាប់គ្រូបង្រៀន ស្តីពីវិធីជួយសិស្សមានពិការភាពនៅវិទ្យាល័យអប់រំពិសេស។

ឯកសារជំនួយស្មារតីនេះត្រូវបានតាក់តែងឡើងក្នុងគោលបំណងជួយលោកគ្រូ អ្នកគ្រូយល់ដឹងទូទៅអំពីការអប់រំកុមារមានពិការភាព ប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងល្អ ការគ្រប់គ្រងថ្នាក់រៀនល្អ កម្មវិធីសិក្សាសមស្របសម្រាប់សិស្សមានពិការភាព វិធីសាស្ត្របង្រៀន វាយតម្លៃការសិក្សា ផែនការជួយសិស្ស និងការរៀបចំបណ្ណាល័យសមស្របសម្រាប់សិស្សមានពិការភាព។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមថា លោកគ្រូ អ្នកគ្រូនឹងប្រើប្រាស់ឯកសារជំនួយស្មារតីនេះ ដើម្បីរួមចំណែកលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែប្រសើរឡើង។ ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដល់ក្រុមការងាររបស់គម្រោងអប់រំបរិយាបន្ននៅបឋមសិក្សា ដែលបានយកចិត្តទុកដាក់ និងគាំទ្របច្ចេកទេសក្នុងការកសាងឯកសារជំនួយស្មារតីនេះ។

ថ្ងៃសុក្រ ១៣កើត ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# មាតិកា


មេរៀនទី១៖ ការយល់ដឹងអំពីពិការភាព............ ១

វត្ថុបំណង............ ១

ខ្លឹមសារ............ ១

១.១ ពិការកាយសម្បទា............ ១

១.២ ពិការសតិបញ្ញា............ ២

១.៣ ពិការផ្លូវចិត្ត............ ២

១.៤ ពិការផ្សេងៗ............ ២

១.៥ មូលហេតុនៃពិការភាព និងការបង្ការ............ ៣

១.៦ ព័ត៌មានផ្តល់សេវាកម្មទៅតាមប្រភេទពិការ............ ៥

មេរៀនទី២៖ ការអប់រំកុមារមានពិការភាព............ ៦

វត្ថុបំណង............ ៦

ខ្លឹមសារ............ ៦

២.១ ការអប់រំបរិយាបន្ន............ ៦

២.២ ការអប់រំថ្នាក់សមាហរណកម្ម............ ៩

២.៣ ការអប់រំពិសេស............ ១០

មេរៀនទី៣៖ សិស្សពិបាកក្នុងការមើល............ ១១

វត្ថុបំណង............ ១១

ខ្លឹមសារ............ ១១

៣.១ លក្ខណៈសម្គាល់សិស្សពិបាកក្នុងការមើល............ ១១

៣.២ មូលហេតុ និងការបង្ការ............ ១១

៣.៣ កម្រិតពិបាកក្នុងការមើល............ ១២

៣.៤ ការប្រើប្រាស់ឧបករណ៍ជំនួយក្នុងការមើល............ ១៣

មេរៀនទី៤៖ សិស្សពិបាកក្នុងការស្តាប់............ ១៤

វត្ថុបំណង............ ១៤

**ខ្លឹមសារ** ........ ១៤

៤.១ លក្ខណៈសម្គាល់សិស្សពិបាកក្នុងការស្តាប់ ........ ១៤

៤.២ មូលហេតុ និងការបង្ការ ........ ១៤

៤.៣ កម្រិតពិបាកក្នុងការស្តាប់ ........ ១៥

៤.៤ ការប្រើប្រាស់ឧបករណ៍ជំនួយការស្តាប់ ........ ១៦

ក) របៀបប្រើប្រាស់ឧបករណ៍ជំនួយការស្តាប់ ........ ១៦

ខ) ការសម្អាតពុម្ពត្រចៀក ........ ១៧

គ) ការរក្សាទុក ........ ១៧

**មេរៀនទី៥៖ សិស្សពិការសតិបញ្ញា និងអូទីស្សឹម** ........ ១៨

**វត្ថុបំណង** ........ ១៨

**ខ្លឹមសារ** ........ ១៨

៥.១ លក្ខណៈសម្គាល់បញ្ហាសតិបញ្ញា និងអូទីស្សឹម ........ ១៨

៥.២ ការស្វែងយល់អំពីដំណាក់កាលនៃការលូតលាស់របស់កុមារ ........ ២០

៥.៣ ផ្នែកនៃការលូតលាស់របស់កុមារ ........ ២០

៥.៤ ដំណាក់កាលនៃការលូតលាស់របស់កុមារនៅអាយុចូលរៀន ........ ២១

៥.៥ ភាពយឺតយ៉ាវនៃការលូតលាស់របស់កុមារ ........ ២២

៥.៦ មូលហេតុ និងការបង្ការពិការសតិបញ្ញា និងអូទីស្សឹម ........ ២៣

**មេរៀនទី៦៖ ប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងល្អ** ........ ២៧

**វត្ថុបំណង** ........ ២៧

**ខ្លឹមសារ** ........ ២៧

៦.១ ការប្រាស្រ័យទាក់ទង ........ ២៧

៦.២ លំនាំនៃការប្រាស្រ័យទាក់ទង ........ ២៨

៦.៣ ប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទង ........ ២៨

**មេរៀនទី៧៖ ការគ្រប់គ្រងថ្នាក់រៀនសិស្សមានពិការភាព** ........ ៣១

**វត្ថុបំណង** ........ ៣១

**ខ្លឹមសារ** ........ ៣១

៧.១ ថ្នាក់រៀនសិស្សពិបាកក្នុងការមើល ..... ៣១
៧.២ ថ្នាក់រៀនសិស្សពិបាកក្នុងការស្ដាប់ ..... ៣១
៧.៣ ថ្នាក់រៀនសិស្សពិការសតិបញ្ញា និងអូទីស្សឹម ..... ៣២

**មេរៀនទី៨៖ កម្មវិធីសិក្សាសិស្សមានពិការភាព ..... ៣៤**

**វត្ថុបំណង ..... ៣៤**

**ខ្លឹមសារ ..... ៣៤**

៨.១ កម្មវិធីសិក្សាសិស្សពិបាកក្នុងការមើល ..... ៣៥
៨.២ កម្មវិធីសិក្សាសិស្សពិបាកក្នុងការស្ដាប់ ..... ៣៦
៨.៣ កម្មវិធីសិក្សាសិស្សពិការសតិបញ្ញា និងអូទីស្សឹម ..... ៣៧
៨.៤ ឧទាហរណ៍កម្មវិធីសិក្សាលម្អិតភាសាខ្មែរ ថ្នាក់ទី១ ..... ៣៧

**មេរៀនទី៩៖ វិធីបង្រៀនសិស្សមានពិការភាព ..... ៥៤**

**វត្ថុបំណង ..... ៥៤**

**ខ្លឹមសារ ..... ៥៤**

៩.១ វិធីបង្រៀន និងរៀនបែបសកល សម្រាប់ការអប់រំបរិយាបន្ន ..... ៥៤
៩.២ វិធីបង្រៀនសិស្សពិបាកក្នុងការមើល ..... ៥៨
៩.៣ វិធីបង្រៀនសិស្សពិបាកក្នុងការស្ដាប់ ..... ៦០
៩.៤ វិធីបង្រៀនសិស្សពិការសតិបញ្ញា និងអូទីស្សឹម ..... ៦៣
៩.៥ ការផលិតសម្ភារៈបង្រៀន និងរៀន ..... ៦៨
៩.៦ ការប្រើប្រាស់សម្ភារៈការបង្រៀន និងរៀនតាមប្រព័ន្ធឌីជីថល ..... ៦៩

**មេរៀនទី១០៖ តេស្តវាយតម្លៃការសិក្សា ..... ៧០**

**វត្ថុបំណង ..... ៧០**

**ខ្លឹមសារ ..... ៧០**

១០.១ តេស្តវាយតម្លៃអំណានថ្នាក់ដំបូងតាមដំណាក់ ..... ៧០
១០.២ កិច្ចការវាស់តេស្តវាយតម្លៃអំណានថ្នាក់ដំបូងតាមដំណាក់ ..... ៧១

**មេរៀនទី១១៖ ផែនការជួយសិស្សជាបុគ្គល ..... ៧៥**

**វត្ថុបំណង** ..... ៧៥
**ខ្លឹមសារ** ..... ៧៥
១១.១ ការស្វែងយល់អំពីតម្រូវការរបស់សិស្ស ..... ៧៥
១១.២ ការរៀបចំផែនការជួយសិស្សជាបុគ្គល ..... ៧៥
១១.៣ ការអនុវត្តផែនការជួយសិស្សជាបុគ្គល ..... ៧៥
**មេរៀនទី១២៖ បណ្ណាល័យសម្រស់** ..... ៧៨
**វត្ថុបំណង** ..... ៧៨
**ខ្លឹមសារ** ..... ៧៨
១២.១ ទិដ្ឋភាពទូទៅនៃបណ្ណាល័យ ..... ៧៨
១២.២ ការគ្រប់គ្រងបណ្ណាល័យ ..... ៧៩
១២.៣ កាលវិភាគបណ្ណាល័យ ..... ៨២
១២.៤ ធនធានបណ្ណាល័យ ..... ៨២
**ឯកសារយោង** ..... ៨៥

# សេចក្ដីផ្ដើម

ព្រះរាជាណាចក្រកម្ពុជាជាប្រទេសហត្ថលេខីនៃអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារ និងបានផ្ដល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្ដីពីសិទ្ធិជនពិការ។ ដើម្បីឆ្លើយតបទៅនឹងអនុសញ្ញានេះ ក្រសួងអប់រំ យុវជន និងកីឡា បានប្ដេជ្ញាចិត្ត ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយ ចីរភាពទី៤ ដោយដាក់ចេញគោលនយោបាយអប់រំ ធានាគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងមានផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

ទន្ទឹមនឹងនេះក្រសួងអប់រំ យុវជន និងកីឡា មានគោលនយោបាយស្ដីពីការអប់រំសម្រាប់កុមារមានពិការភាពនៅឆ្នាំ២០០៨ និងគោលនយោបាយស្ដីពីការអប់រំបរិយាបន្ននៅឆ្នាំ ២០១៨។ ក្រសួងបានអនុវត្តការអប់រំពិសេស ថ្នាក់សមាហរណកម្ម និងការអប់រំបរិយាបន្ន ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់កម្មវិធីសិក្សា និងលើកកម្ពស់គុណភាពអប់រំនៅតាមសាលារៀនចំណេះទូទៅ និងគ្រឹះស្ថានសិក្សាអប់រំពិសេសសាធារណៈ ឱ្យស្របតាមយុគសម័យឌីជីថល និងសង្គមផ្អែកលើពុទ្ធិ។

ដើម្បីចូលរួមចំណែកអនុវត្តឱ្យការអប់រំបរិយាបន្នកាន់តែទូលំទូលាយ ក្រសួងបានសហការជាមួយគម្រោងអប់រំបរិយាបន្ននៅបឋមសិក្សាក្នុងការអនុវត្តកញ្ចប់អំណានថ្នាក់ដំបូងនៅតាមវិទ្យាល័យអប់រំពិសេស។ ក្នុងនោះក្រុមការងារបានកសាងឯកសារជំនួយស្មារតី ដោយមានការពិគ្រោះយោបល់ជាច្រើនលើកច្រើនសារទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងធានាថា ទស្សនៈ និងតម្រូវការរបស់ជនដែលមានពិការភាពត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍសាលារៀន។ ឯកសារជំនួយស្មារតីនេះត្រូវបានតាក់តែងឡើងក្នុងគោលបំណងឱ្យលោកគ្រូ អ្នកគ្រូយល់ដឹងទូទៅអំពីការអប់រំកុមារមានពិការភាពប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងល្អ ការគ្រប់គ្រងថ្នាក់រៀនល្អ កម្មវិធីសិក្សាសមស្របសម្រាប់សិស្សមានពិការភាព វិធីសាស្ត្របង្រៀន រង្វាយតម្លៃការសិក្សា ផែនការជួយសិស្ស និងការរៀបចំបណ្ណាល័យសមស្របសម្រាប់សិស្សមានពិការភាព។ ទន្ទឹមនឹងនេះ ឯកសារជំនួយស្មារតីក៏ជួយដល់លោកគ្រូ អ្នកគ្រូឱ្យចេះប្រើប្រាស់សម្ភារៈបង្រៀន និងរៀន ល្បែងសិក្សា និងវីដេអូដែលបានផលិតឡើងហើយបានដាក់បញ្ចូលនៅក្នុងបណ្ដាញសង្គមផងដែរ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមថា លោកគ្រូ អ្នកគ្រូនឹងប្រើប្រាស់ឯកសារជំនួយស្មារតី ដើម្បីរួមចំណែកលើកកម្ពស់គុណភាពអប់រំឱ្យកាន់តែប្រសើរឡើង។ ក្នុងនាមក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដល់ក្រុមការងាររបស់គម្រោងអប់រំបរិយាបន្ននៅបឋមសិក្សា ដែលបានយកចិត្តទុកដាក់ និងគាំទ្របច្ចេកទេសក្នុងការកសាងឯកសារជំនួយស្មារតី។

## ក្រុមការងារដឹកនាំ និងសម្របសម្រួល

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **សេរី** | **ជំនះ** | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ២. ឯកឧត្តម | **ជា** | **ជាតិ** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣. ឯកឧត្តម | **អ៊ុង** | **ជិនណា** | អគ្គនាយក នៃអគ្គនាយកដ្ឋានអប់រំ |
| ៤. លោកជំទាវ | **នាង** | **ផល្លា** | ប្រធានគណៈគ្រប់គ្រងនាយកដ្ឋានអប់រំពិសេស |

## ក្រុមការងារបច្ចេកទេស

| | | | |
|---|---|---|---|
| ១. លោក | **ទឹម** | **សាហែន** | អនុប្រធាននាយកដ្ឋានអប់រំពិសេស |
| ២. លោក | **ហង់** | **គឹមឈាន់** | នាយករងវិទ្យាស្ថានជាតិអប់រំពិសេស |
| ៣. លោក | **ទន** | **ទី** | នាយករងវិទ្យាស្ថានជាតិអប់រំពិសេស |
| ៤. លោក | **អៀត** | **ឧទ្ធី** | ប្រធានការិយាល័យ នាយកដ្ឋានអប់រំពិសេស |
| ៥. លោក | **ហ៊ឹម** | **សារិន** | អនុប្រធានការិយាល័យ នាយកដ្ឋានអប់រំពិសេស |
| ៦. លោកស្រី | **យាត** | **ថាវី** | អនុប្រធានការិយាល័យ នាយកដ្ឋានអប់រំពិសេស |
| ៧. លោកស្រី | **ឡៅ** | **សុខិតា** | អនុប្រធានដេប៉ាតឺម៉ង់ វិទ្យាស្ថានជាតិអប់រំពិសេស |
| ៨. លោក | **ឃឹម** | **ចំណាប់** | អ្នកឯកទេសផ្នែកអប់រំពិសេស SCI / គម្រោង IPEA |
| ៩. លោក | **នួន** | **ទិបុល** | អ្នកឯកទេសផ្នែកអប់រំបរិយាបន្នគម្រោង IPEA |

# មេរៀនទី១៖ ការយល់ដឹងអំពីពិការភាព

## វត្ថុបំណង

វត្ថុបំណងនៅក្នុងមេរៀននេះ បង្ហាញអំពីការកំណត់លក្ខណៈវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាពរបស់ពិការកាយសម្បទា ពិការសតិបញ្ញា ពិការផ្លូវចិត្ត និងពិការផ្សេងៗ ក៏ដូចគ្នានឹងប្រាប់អំពីមូលហេតុនៃពិការភាព ការបង្ការ និងព័ត៌មានផ្តល់សេវាកម្មទៅតាមប្រភេទពិការ។

## ខ្លឹមសារ

យោងតាមប្រកាសអន្តរក្រសួងស្តីពីការកំណត់លក្ខណៈវិនិច្ឆ័យប្រភេទ និងកម្រិតពិការភាព លេខ ២៤៩២ សអយ/បក ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ២០១១ និងឯកសារជំនួយស្មារតីស្តីពីការកំណត់អត្តសញ្ញាណកុមារមានពិការភាព ឆ្នាំ២០២២ ត្រូវបានកំណត់ជា ៤ ប្រភេទដូចជា ពិការកាយសម្បទា ពិការសតិបញ្ញា ពិការផ្លូវចិត្ត និងពិការផ្សេងៗ។ ចំពោះលក្ខណៈវិនិច្ឆ័យនៃប្រភេទពិការភាព ត្រូវបានកំណត់ដូចខាងក្រោមនេះ៖

| ប្រភេទពិការ | និយមន័យ | លក្ខណៈវិនិច្ឆ័យ |
|---|---|---|
| **១.១ ពិការកាយសម្បទា** | | |
| **ពិបាកក្នុងការធ្វើចលនា** | ជនទាំងឡាយណាដែលមានលទ្ធភាពធ្វើចលនា (ដោយរាងកាយ) ផ្លាស់ទីដោយលំបាក ឬលំបាកកម្រើកផ្នែកណាមួយនៃរាងកាយ ឬមិនអាចកម្រើកបាន។ | ដាច់ដៃ ដាច់ជើង ស្វិតដៃ ស្វិតជើង ស្វិតសាច់ដុំ គាំងសន្លាក់ បាក់ឆ្អឹង សាច់ដុំរួញខ្លី ខូចប្រព័ន្ធបញ្ជាចលនារបស់ខួរក្បាល ជើងខ្វេរ ជើងកែក ទន់ត្រឹមកដៃ ជើងទន់ ខូចទ្រង់ទ្រាយពីកំណើត ស្លាប់មួយចំហៀងខ្លួន/កំណាត់ខ្លួន/អវយវៈខូចសរសៃ ខូចរាងឆ្អឹងខ្នង (កោងទៅមុខកោងទៅចំហៀង និងកោងទៅក្រោយ) ពិការដោយសារផលវិបាកនៃជំងឺ ខូចស្មាម្ខាង ភ្លាត់ត្រគៀកធ្ងន់ធ្ងរ របួសខួរឆ្អឹងខ្នង គ្រិចធ្ងន់ធ្ងររលាកធ្ងន់ធ្ងរ (ភ្លើង ទឹកអាស៊ីដ)។ |
| **ពិបាកក្នុងការស្តាប់** | ជនទាំងឡាយណាដែលពិបាកក្នុងការស្តាប់ ឬលទ្ធភាពនៃការស្តាប់ចុះខ្សោយ ឬមិនអាចស្តាប់បាន។ | ថ្លង់ ត្រចៀកអត់រន្ធ ពុំមានក្រដាសត្រចៀក ធ្លាយក្រដាសត្រចៀក ហៀរអំបៅអំបែកធ្ងន់ធ្ងរ រន្ធត្រចៀកមានដុំពក (ពីកំណើតដោយសារគ្រោះថ្នាក់ របួសជំងឺ ឬវ៉ែដរា...)។ |
| **ពិបាកក្នុងការនិយាយ** | ជនទាំងឡាយណាដែលពិបាក ក្នុងការនិយាយ និយាយមិនច្បាស់ ឬនិយាយមិនរួចទាល់តែសោះ ឬអ្នកដទៃពិបាកស្តាប់។ | និយាយត្រឡាន់(អណ្តាតធំ)/ត្រដឹតធ្ងន់ធ្ងរ ឆែបក្រអូមមាត់ ក្រឡើត ក្រង្ហរ និយាយមិនច្បាស់ និយាយមិនចេញ គ ផលវិបាកនៃជំងឺ (ពីកំណើតដោយសារគ្រោះថ្នាក់ របួស ជំងឺ ឬវ៉ែដរា...)។ |

<table>
<tr><td>ពិបាកក្នុងការមើល</td><td>ជនទាំងឡាយណាដែលមានគំហើញចុះខ្សោយ ឬមិនអាចមើលឃើញ។</td><td>ងងឹតភ្នែកម្ខាង ឬទាំងសងខាង ស្វិតសរសៃបាតភ្នែក ភ្នែកលៀនមើលមិនឃើញ កន្ទុយថ្លៃនធ្ងន់ធ្ងរ ភ្នែកឡើងបាយ ត្រាក់កូមធ្ងន់ធ្ងរ បណ្តាលឱ្យមានប្រេងចាក់ ភ្នែកស្រលៀង ភ្នែកមីញ៉ូប ធ្លាក់ត្របកភ្នែក សម្លាកកញ្ចក់ភ្នែក សម្ពាធទឹកក្នុងភ្នែកកើនឡើង រលាកសរសៃបាតភ្នែក ងងឹតពណ៌ (ពីកំណើតដោយសារគ្រោះថ្នាក់ របួស ជំងឺ ឬវ័យជរា...)។</td></tr>
<tr><td>ពិការសរីរាង្គខាងក្នុង</td><td>ជនទាំងឡាយណាដែលបានវះកាត់សរីរាង្គខាងក្នុងសំខាន់ៗ (ដោយមានការបញ្ជាក់ពីគ្រូពេទ្យជំនាញ) ខ្សោយសរីរាង្គខាងក្នុង ឬចុះខ្សោយមុខងារនៃភាពស៊ាំ និងមានជំងឺរ៉ាំរ៉ៃ...។</td><td>ខ្សោយមុខងារសរីរាង្គ បេះដូង ក្រលៀន ប្រព័ន្ធដង្ហើម តម្រងនោម ពោះវៀន និងថ្លើម។</td></tr>
<tr><td colspan="3">១.២ ពិការសតិបញ្ញា</td></tr>
<tr><td colspan="2">និយមន័យ</td><td>លក្ខណៈវិនិច្ឆ័យ</td></tr>
<tr><td colspan="2">ជនទាំងឡាយណាដែលមានផលវិបាកក្នុងការចងចាំ ភ្លេចច្រើន ឬមិនអាចធ្វើដូចមនុស្សដទៃទៀតដែលមានអាយុដំណាលគ្នា (ពីកំណើតដោយសារគ្រោះថ្នាក់ របួស ឬជំងឺ...)។</td><td>បញ្ញាលូតលាស់យឺត រៀនខ្សោយ/ការចងចាំមានកម្រិត (Cretinism) ខូចប្រព័ន្ធបញ្ញាក្នុងខួរក្បាល (Cerebral Palsy) និងជំងឺដោនសាំងដ្រូម (Down Syndrome) មានចរិតទុយមុយ (Autism)។</td></tr>
<tr><td colspan="3">១.៣ ពិការផ្លូវចិត្ត</td></tr>
<tr><td colspan="2">ជនទាំងឡាយណាដែលមានវិបត្តិផ្នែកអាកប្បកិរិយា អារម្មណ៍ និងការគិត ដែលកើតឡើងជាប្រចាំ ហើយរំខានដល់ការបំពេញមុខងារប្រចាំថ្ងៃ។</td><td>អាក្រាត និយាយ សើច យំ ច្រៀងរាំលេងតែម្នាក់ឯង ខុសពីប្រក្រតី ស្ទឹងស្មាធ ដើរគេដើរឯង វាយ ឬប្រព្រឹត្តអំពើហិង្សាដោយមិនដឹងខ្លួន មិនដឹងគ្រោះថ្នាក់ ជំងឺ មន្ទិលសង្ស័យ វិកលចរិត ខូចសតិអារម្មណ៍ តានតឹងផ្លូវចិត្ត ជំងឺធ្លាក់ទឹកចិត្ត ថប់អារម្មណ៍ ជំងឺវង្វេង។</td></tr>
<tr><td colspan="3">១.៤ ពិការផ្សេងៗ</td></tr>
<tr><td colspan="2">ជនទាំងឡាយណា ដែលលំបាកក្នុងការបំពេញតួនាទីផ្នែករាងកាយ ឬតួនាទីក្នុងសង្គម ឬពិការដែលមិនអាចចាត់ចូលទៅក្នុងប្រភេទពិការណាមួយខាងលើ ឬពហុពិការ។</td><td>មុខមាត់ខូចទ្រង់ទ្រាយ ក្បាលធំ តឿ ក្រិន ពកក ផលវិបាកក្នុងការបំពេញមុខងារដោយសារគ្រោះថ្នាក់ និងជំងឺរ៉ាំរ៉ៃ...។</td></tr>
</table>

## ១.៨ មូលហេតុនៃពិការទាព និងការបង្ការ

| មូលហេតុ | ការបង្ការ |
|---|---|
| **មុនពេលសម្រាល** | |
| • ភាពមិនប្រក្រតីនៃក្រូម៉ូហ្សូម ឬជំងឺតពូជ<br>• មូលហេតុបរិស្ថានដូចជាការប៉ះពាល់ជាមួយសារធាតុពុល (ម្តាយ ឬឪពុក)<br>• កង្វះអាហារូបត្ថម្ភរបស់ម្តាយ<br>• ម្តាយទទួលថ្នាំបង្ការមិនគ្រប់គ្រាន់ (កញ្ជ្រិល និងជំងឺផ្សេងៗ)<br>• ជំងឺរបស់ម្តាយ (ជំងឺកាមរោគ)<br>• ម្តាយមានវ័យក្មេងពេក ឬចាស់ពេក<br>• ការប្រើប្រាស់ឱសថដោយគ្មានវេជ្ជបញ្ជា ការជក់បារី សេពគ្រឿងស្រវឹង គ្រឿងញៀន<br>• កង្វះការថែទាំមុនសម្រាល ឬការកំណត់ភាពស្មុគស្មាញដែលអាចកើតមានដូចជា សម្ពាធឈាមខ្ពស់នៅពេលមានគភ៌ ឬទារកកើតច្រាសជើងជាដើម | • ញ៉ាំអាហារដែលមានជីវជាតិគ្រប់គ្រាន់<br>• ទៅពិនិត្យផ្ទៃពោះឱ្យបានទៀងទាត់( ទទួលថ្នាំបង្ការ លេបថ្នាំជាតិដែក)<br>• កុំធ្វើការហួសកម្លាំង<br>• ចៀសវាងការខឹងច្រើន<br>• មិនត្រូវប៉ះពាល់សារជាតិពុល ឬសារធាតុគីមី |
| **អំឡុងពេលសម្រាល** | |
| • ការប្រើឱសថអំឡុងពេលឈឺពោះសម្រាល និងអំឡុងពេលកើត<br>• ការកើតមិនគ្រប់ខែ<br>• ទារកខ្វះអុកស៊ីសែន<br>• ការឆ្លងវីរុស<br>• ការសម្រាលមិនចេញ<br>• ការសម្រាលប្រឈមនឹងគ្រោះថ្នាក់<br>• ទីតាំងសម្រាលគ្មានសុវត្ថិភាព និងអនាម័យ | • រកឆ្មបដែលមានជំនាញត្រឹមត្រូវ<br>• ឧបករណ៍ត្រូវមានអនាម័យល្អ<br>• កន្លែងសម្រាលត្រូវមានសុវត្ថិភាព |
| **ក្រោយពេលសម្រាល** | |
| • របួសដោយសារគ្រោះថ្នាក់<br>• កង្វះអាហារូបត្ថម្ភ<br>• ទទួលថ្នាំបង្ការមិនគ្រប់គ្រាន់<br>• មានជំងឺក្នុងវ័យកុមារភាព<br>• មូលហេតុបរិស្ថាន ដូចជាការប៉ះពាល់ជាតិពុល សារធាតុគីមី និងគ្រឿងផ្ទុះ<br>• កង្វះភាពរំញោច និងទំនាក់ទំនង | • យកកូនទៅទទួលថ្នាំបង្ការឱ្យបានគ្រប់មុខ (១១មុខ)<br>• ត្រូវតាមដានសុខភាពកូនឱ្យបានទៀងទាត់<br>• ផ្តល់អាហារដែលមានជីវជាតិគ្រប់គ្រាន់ដល់កូន<br>• ទុកកូននៅកន្លែងដែលមានសុវត្ថិភាព និងសមស្រប<br>• កុំប្រឡែងលេងជាមួយកូនខ្លាំងៗពេក<br>• ត្រូវផ្តល់ភាពកក់ក្តៅ និងមានទំនុកចិត្តដល់កូន |


ភាពអន់ខ្សោយ
រនាំងឧបសគ្គ (សង្គមមិនរាប់រក និងរើសអើង)
ពិការភាព


ភាពអន់ខ្សោយ
រនាំងឧបសគ្គ (សង្គមមិនរាប់រក និងរើសអើង)
គ្មានពិការភាព

## ១.៦ ព័ត៌មានផ្តល់សេវាកម្មនៅតាមប្រភេទពិការ

# សេវាគាំទ្រ

### នាយកដ្ឋានអប់រំពិសេស

សេវាកម្ម៖ គាំទ្រវិស័យអប់រំសម្រាប់កុមារមានពិការភាព

ទូរស័ព្ទ៖ ០១២ ២៩៨ ៨១៦

ទីតាំង៖ ភ្នំពេញ



### វិទ្យាស្ថានជាតិអប់រំពិសេស

សេវាកម្ម៖ បណ្តុះបណ្តាលគ្រូផ្នែកអប់រំពិសេស ផលិតសម្ភារបង្រៀន និងរៀន និងសិក្សាស្រាវជ្រាវសញ្ញាណថ្មីៗដើម្បីគាំទ្រការអប់រំពិសេស

ទូរស័ព្ទ៖ ០១២ ៨៩៥ ៨៨៥

ទីតាំង៖ ភ្នំពេញ



### All Ears Cambodia

សេវាកម្ម៖ គាំទ្រកុមារពិបាកក្នុងការស្តាប់

ទូរស័ព្ទ៖ ០១២ ៦២៤ ៥៣០

ទីតាំង៖ ភ្នំពេញ



### CCAMH

សេវាកម្ម៖ គាំទ្រកុមារពិការសតិបញ្ញា និងអូទីស្សឹម

ទូរស័ព្ទ៖ ០២៣ ៣០០ ៥៣៤

ទីតាំង៖ មន្ទីរពេទ្យជ័យជំនះ ក្រុងតាខ្មៅ ភ្នំពេញ



### អង្គការគ្រួសារថ្មី

សេវាកម្ម៖ គាំទ្រកុមារពិបាកក្នុងការមើល និងការស្តាប់

ទូរស័ព្ទ៖ ០២៣ ៨៨០ ៥០២

ទីតាំង៖ ទឹកល្អក់១ ទួលគោក ភ្នំពេញ

# មេរៀនទី២៖ ការអប់រំកុមារមានពិការភាព

## វត្ថុបំណង

ក្នុងមេរៀននេះ បង្ហាញអំពីភាពខុសប្លែកគ្នារវាងការអប់រំបរិយាបន្ន ថ្នាក់សមាហរណកម្ម និងការអប់រំពិសេស ដូចគ្នានឹងផលប្រយោជន៍ដែលនឹងទទួលបានតាមរយៈការអប់រំទាំងបីប្រភេទនេះ។

## ខ្លឹមសារ

### ២.១ ការអប់រំបរិយាបន្ន

ការអប់រំបរិយាបន្ន សំដៅទៅលើការដាក់បញ្ចូលគ្រប់កុមារទាំងអស់ឱ្យរៀនជាមួយគ្នាទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ដោយពុំមានការបែងចែកអំពី ភេទ ចរិតលក្ខណៈ កាយសម្បទា បញ្ញាស្មារតី ស្ថានភាពសង្គម ភាសា វប្បធម៌ សាសនា ឬលក្ខណៈផ្សេងៗទៀតឡើយ។ ក្នុងនោះផងដែរ កុមារម្នាក់ៗមានតម្រូវការរៀនសូត្រ និងការលំបាកខុសៗគ្នា ហើយដើម្បីបំពេញតម្រូវការពិសេសរបស់សិស្សម្នាក់ៗនៅក្នុងថ្នាក់រៀនបាន គ្រូបង្រៀនគួរគប្បីចេះបត់បែនទៅតាមលក្ខណៈពិសេសរបស់កុមារ និងត្រូវយល់ថា កុមារពុំមែនជាបញ្ហាដែលពួកគេមិនអាចទទួលបានការអប់រំឡើយ គឺមានតែដំណើរការអប់រំទេដែលអាចបង្កជាបញ្ហាដល់ការរៀនសូត្ររបស់ពួកគេ។

កុមារមានពិការភាព ត្រូវបានដាក់បញ្ចូលក្នុងថ្នាក់រៀនធម្មតាជាមួយកុមារមិនមានពិការភាពតាមដែលអាចធ្វើទៅបាន ហើយការអប់រំបរិយាបន្ននៅក្នុងថ្នាក់រៀនធម្មតាមានប្រសិទ្ធភាពដរាបណាសិស្សមានពិការភាពទទួលបានការគាំទ្រសមស្រប និងគ្រូបង្រៀនទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់។

ប្រព័ន្ធអប់រំជាបញ្ហា

- ឥរិយាបថគ្រូមិនទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស
- ការបំប៉នគ្រូបង្រៀននៅមានកម្រិត
- វិធីបង្រៀន និងកម្មវិធីសិក្សាពុំទាន់ឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស
- ខ្វះសម្ភារបង្រៀន និងរៀន
- ខ្វះឧបករណ៍ជំនួយដល់ការរៀនសូត្រ
- សាលារៀនពុំបង្កលក្ខណៈងាយស្រួលតាមស្តង់ដានៅឡើយ
- ពុំមានការចូលរួមពីឪពុកម្តាយ និងសហគមន៍

| សាលារៀនអប់រំបរិយាបន្ន | • សាលារៀនដែលទទួលស្គាល់ថាកុមារគ្រប់រូបមានសិទ្ធិ និងមានកាតព្វកិច្ចសិក្សាដូចៗគ្នា<br>• ទទួលស្គាល់ថាកុមារគ្រប់រូបមានលក្ខណៈខុសប្លែកពីគ្នា<br>• ទទួលយកកុមារគ្រប់ប្រភេទដោយគ្មានរើសអើង<br>• ឆ្លើយតបទៅនឹងសេចក្ដីត្រូវការរៀនសូត្រគ្រប់ប្រភេទ<br>• ជំរុញគុណភាព និងប្រសិទ្ធភាពនៃការរៀន និងបង្រៀន |
|---|---|

ការអប់រំបរិយាបន្នមិនត្រឹមតែដាក់បញ្ចូលកុមារស្ថិតក្នុងសេចក្ដីត្រូវការពិសេស ឱ្យទទួលបានការអប់រំប៉ុណ្ណោះទេ ថែមទាំងមាននិន្នាការឱ្យមានការរៀន និងបង្រៀនកាន់តែមានគុណភាព ប្រសិទ្ធភាព និងមានបរិស្ថានសមស្របបម្រើផលប្រយោជន៍ដល់កុមារទាំងអស់ទៀតផង។ សាលារៀនអប់រំបរិយាបន្នជាសាលារៀនដែលតម្រូវឱ្យមានការបត់បែនតាមកាលៈទេសៈ ហើយគ្រូបង្រៀនត្រូវព្យាយាមសម្របសម្រួលប្រព័ន្ធអប់រំឱ្យឆ្លើយតប ទៅនឹងសេចក្ដីត្រូវការរបស់សិស្សម្នាក់ៗ ហើយត្រូវទទួលស្គាល់ថា កុមារមិនមែនជាបញ្ហានោះឡើយ។ ម៉្យាងវិញទៀត ប្រសិនបើពួកគេទទួលបាននូវសេវាគាំទ្រសមស្របទៅតាមតម្រូវការរបស់ពួកគេជាពិសេសមានដូចជា គ្រឿងជំនួយក្នុងការបំលាស់ទី ឧបករណ៍ជំនួយក្នុងការស្ដាប់ ស្លេត និងស្ទៃឡាស់សរសេរអក្សរប្រៃយ៍ ក្រដាសសរសេរអក្សរប្រៃយ៍ នោះពួកគេនឹងទទួលបាននូវការអប់រំប្រកបដោយប្រសិទ្ធភាពផងដែរ។

| **ផលប្រយោជន៍នៃការអប់រំបរិយាបន្ន** |
|---|
| ក) ចំពោះកុមារ |
| ➢ កុមារមានភាពជឿជាក់លើខ្លួនឯងច្រើនជាងមុន |
| ➢ កុមារឱ្យតម្លៃខ្លួនឯង និងមានមោទនភាពលើសមិទ្ធផលនានារបស់ខ្លួន |
| ➢ កុមារបង្កើនភាពម្ចាស់ការចំពោះការរៀនសូត្ររបស់ខ្លួនទាំងក្នុង និងក្រៅសាលារៀន |
| ➢ កុមាររៀនពីរបៀបប្រាស្រ័យទាក់ទងជាមួយគ្រូ និងមិត្តរួមថ្នាក់យ៉ាងសកម្ម និងសប្បាយរីករាយ |
| ➢ កុមាររៀនពីរបៀបលេងកម្សាន្តជាមួយកុមារដទៃដែលមានស្ថានភាពខុសៗគ្នាដោយមិនប្រកាន់ការរើសអើង |
| ➢ ជួយកុមារឱ្យទទួលយក និងគោរពច្បាប់ទម្លាប់ប្រកបដោយការទទួលខុសត្រូវ |
| ➢ អប់រំកុមារពីសកម្មភាពដែលជួយគេឱ្យក្លាយជាមនុស្សដ៏មានប្រយោជន៍សម្រាប់គ្រួសារ និងសហគមន៍ |
| ➢ កុមារទទួលបានអត្ថប្រយោជន៍នៅពេលដែលគ្រូប្រើវិធីបង្រៀនជាច្រើនខុសគ្នា និងតាមរបៀបប្រាស្រ័យទាក់ទងល្អ |

| |
|---|
| ➢ កុមារមិនមានពិការភាពរៀន និងលេងជាមួយកុមារមានពិការភាព និងចាប់ផ្ដើមទទួលយកពួកគេធ្វើជាមិត្ត |
| ➢ ការរៀនទំនាក់ទំនងក្នុងសង្គម |
| **ខ) ចំពោះគ្រូបង្រៀន** |
| ➢ គ្រូបង្រៀនមានឱកាសកាន់តែច្រើនដើម្បីរៀនសូត្រពីវិធីប្លែកៗ និងទទួលបានចំណេះដឹងថ្មីៗក្នុងការបង្រៀន |
| ➢ គ្រូអាចយល់ដឹង និងរិះរកវិធីផ្សេងៗដើម្បីដោះស្រាយបញ្ហាប្រឈម ហើយអាចអភិវឌ្ឍឥរិយាបថវិជ្ជមានរបស់ខ្លួនជាមួយនឹងស្ថានភាព និងមនុស្សទូទៅ ពិសេសនៅពេលបង្រៀន គឺជាភាពសប្បាយរីករាយដោយមិនមែនជាការងារច្រំដែលនោះទេ |
| ➢ គ្រូបង្រៀនមានឱកាសកាន់តែច្រើនក្នុងការស្រាវជ្រាវគំនិតថ្មីតាមរយៈការទំនាក់ទំនងកាន់តែញឹកញាប់ជាមួយគ្រូដទៃទាំងក្នុង និងក្រៅសាលារៀន |
| ➢ យុទ្ធសាស្ត្រជាច្រើនដែលគ្រូប្រើសម្រាប់បង្រៀនកុមារមានពិការភាព ក៏អាចជួយកុមារមិនមានពិការភាពបានផងដែរ ដូចនេះការរៀនសូត្ររបស់កុមារទាំងអស់កាន់តែមានភាពប្រសើរ |
| **គ) ចំពោះមាតាបិតា** |
| ➢ ឪពុកម្ដាយយល់ដឹងបានច្រើនពីរបៀបដែលកូនគាត់ទទួលបានការអប់រំ |
| ➢ ឪពុកម្ដាយទទួលបានវិធីសាស្ត្រសំខាន់ៗក្នុងការជួយកូនខ្លួនឱ្យរៀន |
| ➢ នៅពេលដែលគ្រូបង្រៀនសុំយោបល់ពីរឿងកូនគាត់ ពួកគេមានអារម្មណ៍ថាគាត់មានតម្លៃហើយគិតថាជាដៃគូស្មើភាពក្នុងការផ្ដល់ឱកាសរៀនសូត្រដល់កូនរបស់គាត់ |
| ➢ ឪពុកម្ដាយយល់ដឹងពីរបៀបដោះស្រាយបញ្ហាជាមួយកូនគាត់បានប្រសើរជាងមុន ដោយប្រើបច្ចេកទេសដែលគ្រូប្រើនៅសាលារៀន |
| ➢ សំខាន់បំផុត គឺឪពុកម្ដាយដឹងថា កូនគាត់ និងកុមារទូទៅទទួលបានការអប់រំមួយដែលមានគុណភាព និងគ្មានការខកចិត្ត ឬតូចចិត្តចំពោះកូនខ្លួនដែលមានពិការភាព |
| **ឃ) ចំពោះសហគមន៍** |
| ➢ សហគមន៍មានមោទនភាពដោយសារកុមារកាន់តែច្រើនបានចូលរៀន និងរៀនសូត្រដោយសមធម៌ |
| ➢ សហគមន៍មើលឃើញថា អនាគតគ្រូដឹកនាំសហគមន៍កាន់តែច្រើន ដែលត្រូវបានរៀបចំសម្រាប់ការចូលរួមយ៉ាងសកម្មក្នុងសង្គមជាតិ |
| ➢ សហគមន៍យល់ឃើញថា បញ្ហាសង្គម ដូចជា បទឧក្រិដ្ឋតូចតាច ឬបញ្ហាយុវវ័យអាចថយចុះ |
| ➢ ជានាឱ្យបាននូវឱកាសស្មើភាពគ្នាដល់កុមារស្ថិតក្នុងក្រុមដែលងាយរងគ្រោះបំផុត |
| ➢ ធ្វើឱ្យប្រាកដថា កុមារស្ថិតក្នុងសេចក្ដីត្រូវការពិសេស មិនត្រឹមតែបានទទួលការអប់រំប៉ុណ្ណោះទេ ប៉ុន្តែពួកគេត្រូវទទួលបាននូវការអប់រំប្រកបដោយគុណភាពខ្ពស់ទៀតផង |




## ២.២ ការអប់រំថ្នាក់សមាហរណកម្ម

លក្ខណៈមួយទៀតនៃការអប់រំបរិយាបន្ន គឺជាថ្នាក់សមាហរណកម្ម ដែលជាថ្នាក់រៀនដោយឡែកសម្រាប់តែកុមារមានពិការភាពនៅក្នុងសាលាចំណេះទូទៅ។ ជាធម្មតា កុមារដែលមានពិការភាពប្រភេទដូចគ្នាដូចជា ពិការភ្នែក គថ្លង់ ឬបញ្ញាសតិបញ្ញា និងអូទីស្សឹម ត្រូវបានដាក់ឱ្យរៀនជាមួយគ្នា ដើម្បីឱ្យមានភាពងាយស្រួលសម្រាប់ការបង្រៀនរបស់គ្រូ និងការរៀនសូត្ររបស់សិស្ស។ នៅក្នុងថ្នាក់សមាហរណកម្ម ពួកគេនឹងទទួលបាននូវសេវាអប់រំពិសេសមានដូចជា ការណែនាំអំពីអក្សរប្រែយ៍ ឬភាសាសញ្ញាតាមរយៈគ្រូដែលបានបណ្ដុះបណ្ដាលពិសេស ថែមទាំងមានឱកាសទំនាក់ទំនងជាមួយនឹងកុមារមិនមានពិការភាពនៅក្នុងសាលារៀនតែមួយទៀតផង។ ប្រសិនបើសិស្សមានពិការភាពទទួលបាននូវជំនាញពិសេសដូចជា ការរៀនសរសេរអក្សរប្រែយ៍ ការអានអក្សរប្រែយ៍ ឬការៀនភាសាសញ្ញាកម្ពុជា ពួកគេអាចផ្លាស់ទៅរៀននៅថ្នាក់បរិយាបន្ន ប៉ុន្តែគ្រូក៏ត្រូវមានជំនាញអប់រំពិសេសដែលទទួលបានតាមរយៈវគ្គបណ្ដុះបណ្ដាលលើជំនាញ ឬក៏មានគ្រូជំនួយអប់រំពិសេសចាំជួយគាំទ្រនៅថ្នាក់រៀន។

គ្រូបង្រៀននឹងត្រូវទទួលការបណ្ដុះបណ្ដាល អំពីភាសាសញ្ញា និងអក្សរប្រែយ៍ ដោយផ្អែកតាមសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា។ តាមបទពិសោធន៍នៅតាមបណ្ដាប្រទេសជាច្រើន ការធ្វើសមាហរណកម្មរវាងកុមារ និងមនុស្សធំដែលមានតម្រូវការពិសេសគឺមានលក្ខណៈល្អប្រសើរនៅក្នុងសាលាអប់រំបរិយាបន្ន ហើយនេះក៏បង្ហាញឱ្យឃើញថា កុមារ និងមនុស្សធំដែលមានតម្រូវការពិសេសអាចសម្រេចបានការអភិវឌ្ឍ និងការចូលរួមក្នុងសង្គមពេញលេញ។

## ២.៣ ការអប់រំពិសេស

ជាទូទៅនៅលើពិភពលោកតែងតែមានកុមារមួយចំនួនស្ថិតក្នុងសេចក្ដីត្រូវការពិសេស ហើយពួកគេមានបញ្ហាដោយឡែកមួយចំនួនដែលរារាំងពួកគេក្នុងការរៀនសូត្រ និងការអភិវឌ្ឍ។ ពួកគេត្រូវការបង្រៀនពិសេសដើម្បីឱ្យសមស្របទៅនឹងបញ្ហារបស់ពួកគេ។ ក្នុងករណីកុមារមានពិការភាពសតិបញ្ញា និងអូទីស្សឹមចាំបាច់ត្រូវរៀននៅវិទ្យាល័យអប់រំពិសេស ពីព្រោះកុមារត្រូវការគ្រូដែលមានជំនាញអប់រំពិសេស ត្រូវការបរិយាកាសពិសេស និងត្រូវការឧបករណ៍ពិសេស ដោយសារតែពួកគេពុំអាចរៀនតាមទាន់កម្មវិធីសិក្សាថ្នាក់ជាតិបាន ដោយផ្អែកទៅលើបញ្ហាពិការភាពរបស់ពួកគេ។

រីឯកុមារពិការភ្នែក និងគថ្លង់ ក៏ចាំបាច់ត្រូវតែរៀននៅវិទ្យាល័យអប់រំពិសេសជាមុនដូចគ្នា ពីព្រោះដំបូងឡើយពួកគេត្រូវរៀនអក្សរប្រែយ៍ និងភាសាសញ្ញាជាមូលដ្ឋានឱ្យបានច្បាស់លាស់។ យោងតាមបទពិសោធន៍របស់វិទ្យាល័យអប់រំពិសេសបានបញ្ជាក់ថា កុមារមានពិការភាពភ្នែកមិនសូវជាមានបញ្ហានោះឡើយពាក់ព័ន្ធនឹងការរៀនសូត្ររបស់ពួកគេនៅថ្នាក់អប់រំបរិយាបន្ន លើកលែងតែកុមារគថ្លង់ទាំងស្រុងពិតជាមានការលំបាកច្រើនក្នុងការសិក្សាជាមួយសិស្សមិនមានពិការភាពផ្សេងទៀតនៅក្នុងថ្នាក់រៀន ហើយទាំងនេះមិនមែនបណ្ដាលមកពីខួរក្បាលរបស់ពួកគេគ្មានសមត្ថភាពនោះទេ គឺដោយសារនៅប្រទេសកម្ពុជាយើងមានគ្រូតិចតួចប៉ុណ្ណោះដែលទទួលបានការបណ្ដុះបណ្ដាលអំពីភាសាសញ្ញាកម្ពុជា ដើម្បីអាចធ្វើការទំនាក់ទំនងជាមួយកុមារគថ្លង់បានទាំងក្រៅថ្នាក់រៀន និងក្នុងថ្នាក់រៀន។ ទោះបីជាវិទ្យាល័យអប់រំពិសេសផ្ដល់ឱកាសសម្រាប់សិស្សមានពិការភាព និងសិស្សមិនមានពិការភាពបានជួបគ្នាយ៉ាងណាក្ដី ប៉ុន្តែវិទ្យាល័យអប់រំពិសេស ក៏បានផ្ដល់នូវលទ្ធភាពដល់សិស្សមានពិការភាពទាំងអស់ឱ្យទទួលបានការអប់រំជាមធ្យោបាយសមស្របសម្រាប់សិស្សដែលមានតម្រូវការរៀនសូត្រជាពិសេសផងដែរ។

# មេរៀនទី៣៖ សិស្សពិបាកក្នុងការមើល

## ខ្លឹមបំណង

ក្នុងមេរៀននេះបង្ហាញអំពីលក្ខណៈសម្គាល់សិស្សពិបាកក្នុងការមើល មូលហេតុ និងការបង្ការកម្រិតពិបាកក្នុងការមើល និងការប្រើប្រាស់ឧបករណ៍ជំនួយក្នុងការមើល។

## ខ្លឹមសារ

### ៣.១ លក្ខណៈសម្គាល់សិស្សពិបាកក្នុងការមើល

នៅក្នុងថ្នាក់រៀន គ្រូត្រូវដឹងពីសញ្ញាណនៃបញ្ហាភ្នែករបស់សិស្ស ដាក់ស្តែងបទពិសោធន៍នៅវិទ្យាល័យអប់រំពិសេស មានសិស្សមួយចំនួនដែលគ្រូបង្រៀនអាចសម្គាល់ថាសិស្សអាចពិបាកក្នុងការមើល មានដូចជា ដើរងើយ ដើរស្ទាប ដើរអូសជើង ដើរគោងគ្នា ភ្នែកឡើងក្រហម ករនេនៃភ្នែកខ្មៅ (មិនថ្លា ឬស្រអាប់) កូនក្រមុំភ្នែកមិនមានពណ៌ខ្មៅហើយភ្នែកឡើងស ឈឺចាប់ក្នុងភ្នែក និងមានហូរទឹកភ្នែក ភ្នែកទាំងសងខាងមិនធ្វើចលនាព្រមគ្នាពល់ពេលសម្លឹងត្រង់ មើលវត្ថុ និងសៀវភៅជិតខ្លាំង ដើរប៉ះវត្ថុផ្សេងៗ ជ្រួញមុខ ព្រិចៗភ្នែក ញ័រក្បាល ចុចភ្នែកម្ខាង ឬទាំងសងខាង ចងចិញ្ចើមពេលខំប្រឹងសម្លឹងអ្វីមួយ និងភ្នែកពុំអាចមើលឃើញអ្វីសោះមានន័យថាងងឹតទាំងស្រុងជាដើម ដើម្បីឱ្យគ្រូឯកទេសភ្នែកធ្វើការវាយតម្លៃពីបញ្ហាភ្នែក និងបំពេញព័ត៌មាននៅក្នុងបែបបទណែនាំ ថាតើត្រូវប្រើប្រាស់វ៉ែនតា ឧបករណ៍ជំនួយការមើល ឬវិធីណាមួយដែលអាចជួយឱ្យសិស្សរៀនសូត្របានយ៉ាងងាយស្រួលនៅក្នុងថ្នាក់រៀន។

### ៣.២ មូលហេតុ និងការបង្ការ

តាមការអង្កេតបានបង្ហាញថា កង្វះវីតាមីនអា ភ្នែកឡើងបាយពីកំណើត បញ្ហាលំអៀងកំណុំរូបភាព និងជំងឺត្រាក់កូម គឺជាមូលហេតុទូទៅនៃពិការភ្នែក និងខ្សោយគំហើញ។ មូលហេតុទាំងអស់មានពី ៨០% ទៅ ៩០% អាចបង្ការ ឬព្យាបាលបាន។ ការកើតមានឡើងនៃបញ្ហាមើលមានចំនួនកាន់តែខ្ពស់ក្នុងប្រទេសដែលមានប្រាក់ចំណូលទាប ហើយថយចុះពេលទទួលបានសេវាថែទាំសុខភាពល្អប្រសើរ។

| មូលហេតុ | ការបង្ការ |
|---|---|
| ➢ កង្វះវីតាមីនអាចបង្កឱ្យករនេ (ផ្នែករបស់ភ្នែកដែលមើលឃើញមានពណ៌ស) កើតមានស្លាកស្នាម ហើយបង្កឱ្យងងឹតពេលយប់ផងដែរគឺ មាន១.៨% នៃកុមារស្ថិតក្នុងចន្លោះអាយុពី២ឆ្នាំទៅ៥ឆ្នាំ | ➢ ថ្នាំគ្រាប់វីតាមីនអា បានចាប់ផ្តើមធ្វើនៅប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩៤ ហើយក៏បានដាក់បញ្ចូលទៅក្នុងកម្មវិធីពង្រីកការចាក់ថ្នាំបង្ការថ្នាក់ជាតិនៅឆ្នាំ១៩៩៨<br>➢ ភ្នែកឡើងបាយ ត្រូវធ្វើការវះកាត់ឱ្យបានឆាប់រហ័សពីព្រោះគំហើញនឹងកាន់តែប្រសើរឡើង |

- ភ្នែកឡើងបាយបង្កឡើងពេលដែលគ្រាប់ភ្នែកឡើងស្រអាប់ ឬពណ៌ស និងភ្នែកឡើងបាយពីកំណើតជាជំងឺតំណពូជធ្វើឱ្យប៉ះពាល់ដល់កុមារ
- បញ្ហាលំអៀងកំណុំរូបភាពមិនល្អ គឺមានប្រហែល ១០% ក្នុងចំណោមមូលហេតុទាំងអស់នៃពិការភ្នែក ហើយមាន ១% នៃកុមារជាសិស្សនៅប្រទេសកម្ពុជា
- ជំងឺត្រាក់កូមឆ្លងតាមរយៈការប្រើប្រាស់ទឹកមិនស្អាត និងខ្វះអនាម័យ និងសេវាសុខភាព
- គ្រោះថ្នាក់ផ្សេងៗប៉ះពាល់ដល់ភ្នែក (ដុង ឬមុតនឹងវត្ថុស្រួចៗល។)
- ជំងឺកញ្ជ្រិលឆ្លងតាមរយៈខ្យល់បន្ទាប់ពីបុគ្គលមានជំងឺកញ្ជ្រិលក្អក ឬកណ្ដាស់ អាការៈគ្រុនក្ដៅឡើងកន្ទួល ភ្នែកក្រហម និងហូរទឹកភ្នែក
- បញ្ហាលម្អៀងកំណុំរូបភាព ងាយស្រួលធ្វើរោគវិនិច្ឆ័យវាស់ និងតម្រូវជាមួយនឹងវ៉ែនតា
- ជំងឺត្រាក់កូមអាចព្យាបាលជាមួយថ្នាំអង់ទីប៊ីយ៉ូទិច និងអាចទប់ស្កាត់បានដោយលាងដៃ ជាមួយសាប៊ូក្រោយពីការប្រើប្រាស់បង្គន់ និងការរក្សាផ្ទៃមុខឱ្យបានស្អាត ជាពិសេសចំពោះកុមារអាយុក្រោម ១០ឆ្នាំ
- ត្រូវមានការប្រុងប្រយ័ត្នខ្ពស់កុំឱ្យមានគ្រោះថ្នាក់ផ្សេងៗកើតឡើង
- វិធីល្អបំផុតមានតែការចាក់វ៉ាក់សាំងមួយប៉ុណ្ណោះដែលអាចការពារខ្លួនយើងបាន

### ៣.៣ កម្រិតពិបាកក្នុងការមើល

ការមើលត្រូវបានបែងចែកជាបួនកម្រិតធំៗ ក្នុងនោះមានកម្រិតធម្មតាដែលសិស្សអាចមើលឃើញច្បាស់ទាំងទីជិត និងទីឆ្ងាយ សម្រាប់កម្រិតផ្សេងទៀតមាន ស្រាល មធ្យម ធ្ងន់ធ្ងរ និងងងឹតទាំងស្រុងសំដៅលើសមត្ថភាពមើលឃើញមានការថយចុះ ហើយការមើលឃើញនេះពុំអាចត្រឡប់មករកភាពធម្មតាវិញបានទេ បើទោះបីជាទទួលបាននូវការព្យាបាល វះកាត់ ឬប្រើឧបករណ៍ជំនួយក្នុងការមើលក៏ដោយ។



| កម្រិតនៃការមើល | គំហើញច្បាស់ |
|---|---|
| ធម្មតា | ៦/៦ |
| ស្រាល | ប្រហែល ៦/១៨ |
| មធ្យម | ប្រហែល ៦/៦០ |
| ធ្ងន់ធ្ងរ | ច្រើនជាង ៦/៦០ |
| ងងឹតទាំងស្រុង | មិនទទួលដឹងថាមានពន្លឺ |

## ៣.៤ ការប្រើប្រាស់ឧបករណ៍ជំនួយក្នុងការមើល

សិស្សពិបាកក្នុងការមើលខ្លះត្រូវការជំនួយពីឧបករណ៍អុបទិច កុមារខ្លះទៀតត្រូវការប្រើប្រាស់ឧបករណ៍មិនមែនឧបទិច និងកុមារខ្លះទៀតគឺត្រូវការទាំងពីរប្រភេទ។ សម្រាប់គ្រូបង្រៀនវិញក៏ ត្រូវចេះប្រើប្រាស់ឧបករណ៍ជំនួយគំហើញមួយចំនួនមានដូចជា ម៉ាស៊ីនពង្រីក (CCTV) កែវពង្រីកមានដង កែវពង្រីកមានជើងទម្រ វ៉ែនតាពង្រីក និងសៀវភៅពុម្ពធំ ដែលជាឧបករណ៍ផ្តល់ពណ៌ធ្លាស់អាចជួយពង្រីកអក្សរបានច្បាស់ជាងមុន ជើងទម្រសម្រាប់អាន ឬសរសេរ អក្សរពុម្ពធំ និងវ៉ែនតាមួកកាត់បន្ថយការចាំងពន្លឺជាដើម។



ឧបករណ៍សរសេរអក្សរប្រែយ៍




ម៉ាស៊ីនពង្រីក (CCTV)



កែវពង្រីក



ជើងទម្រសម្រាប់អាន ឬសរសេរ

# មេរៀនទី៤៖ សិស្សពិបាកក្នុងការស្តាប់

## ខ្លឹមបំណាច

នៅក្នុងមេរៀននេះ ប្រាប់អំពីលក្ខណៈសម្គាល់សិស្សពិបាកក្នុងការស្តាប់ មូលហេតុ និងការបង្ការ កម្រិតពិបាកក្នុងការស្តាប់ និងបង្ហាញពីការប្រើប្រាស់ឧបករណ៍ជំនួយក្នុងការស្តាប់។

## ខ្លឹមសារ

### ៤.១ លក្ខណៈសម្គាល់សិស្សពិបាកក្នុងការស្តាប់

បញ្ហាស្តាប់ សំដៅលើលទ្ធភាពស្តាប់ឮតិចតួច ឬពុំមានលទ្ធភាពស្តាប់ឮទាល់តែសោះដោយត្រចៀកម្ខាង ឬទាំងសងខាង។ យើងអាចកត់សម្គាល់ថា ការមានបញ្ហាស្តាប់តាមរយៈសញ្ញាមួយចំនួនដូចជា ពិបាកស្តាប់ ពិបាកនិយាយ យល់មិនច្បាស់ពីការពន្យល់ ឬណែនាំផ្ទាល់មាត់របស់គ្រូ អាចឆ្លើយខុសសំណួរ និងឧស្សាហ៍ឈឺត្រចៀកជាដើម។

ការបាត់បង់សមត្ថភាពស្តាប់អាចប៉ះពាល់ដល់ការអភិវឌ្ឍការនិយាយ ភាសា និងជំនាញទំនាក់ទំនងសង្គម ប្រសិនបើយើងដឹងថា កុមារបាត់បង់នូវសមត្ថភាពស្តាប់ យើងត្រូវបញ្ជូនគាត់ទៅរកសេវាជំនាញ ហើយពិគ្រោះយោបល់ជាមួយគ្រូពេទ្យ ដើម្បីឱ្យគាត់ធ្វើការពិនិត្យយ៉ាងល្អិតល្អន់ និងមិនត្រូវពន្យាពេល ឬរង់ចាំឡើយ។

កុមារដែលមានបញ្ហាស្តាប់អាចដាក់បញ្ចូលទៅក្នុងប្រព័ន្ធអប់រំតាមលក្ខណៈជាច្រើន អាស្រ័យទៅតាមតម្រូវការជាក់ស្តែង និងសេវាជំនួយដែលមានស្រាប់។ បច្ចុប្បន្ន កុមារដែលមានបញ្ហាស្តាប់អាចរៀនសូត្របាននៅថ្នាក់អប់រំបរិយាបន្ន ប្រសិនបើពួកគេទទួលបាននូវការគាំទ្រ ដូចជា វិធីសាស្ត្របង្រៀន និងរៀន និងឧបករណ៍ជំនួយផ្សេងៗពាក់ព័ន្ធនឹងបញ្ហាស្តាប់។ ពាក់ព័ន្ធនឹងការរៀនសូត្រវិញ កុមារមានបញ្ហាស្តាប់ដែលរៀននៅតាមគ្រឹះស្ថានសិក្សាសាធារណៈ មិនអាចរៀនឆាប់ចេះដូចកុមារដទៃទៀតបានទេ គឺដោយសារពួកគេមិនអាចស្តាប់ឮសំឡេងរបស់គ្រូនិយាយ ឬពន្យល់នៅក្នុងថ្នាក់រៀន។

### ៤.២ មូលហេតុ និងការបង្ការ

ការបាត់បង់ការស្តាប់ចំពោះកុមារ មានមូលហេតុមួយចំនួនកើតចេញអំពីជំងឺត្រចៀកដែលបណ្តាលមកពីបាក់តេរី ឬមេរោគ ព្រោះថា កុមារងាយទទួលរងគ្រោះជាងគេពីព្រោះប្រព័ន្ធការពាររាងកាយរបស់កុមារពុំទាន់រឹងមាំនៅឡើយ។ ជំងឺត្រចៀករួមមាន រលាក អំបៅអំបែក គ្រុនក្តៅ និងឈឺត្រចៀក ប្រសិនបើជំងឺនេះមិនព្យាបាលឱ្យទាន់ពេលវេលា និងត្រឹមត្រូវតាមរយៈឱសថនោះទេ ជំងឺនេះអាចបង្កឱ្យមានភាពធ្ងន់ធ្ងរ និងពុំរ៉ៃ នាំទៅរកការខូចត្រចៀកជារៀងរហូតដែលបណ្តាលឱ្យបាត់បង់ការស្តាប់បាន។ ម៉្យាងវិញទៀត កង្វះអនាម័យក៏ជាមូលហេតុចម្បងនៃជំងឺត្រចៀកផងដែរ។ ជំងឺមួយចំនួនដូចជា ក្រឡែនទែន កញ្ជ្រិល រលាកស្រោមខួរ គ្រុនចាញ់ និងការរហែកក្រដាសត្រចៀកសុទ្ធតែអាចបណ្តាលឱ្យបាត់បង់ការស្តាប់ ហើយជំងឺទាំងនេះអាចបង្ការបានដោយការរក្សាអនាម័យ និងការចាក់ថ្នាំបង្ការក្រោយសម្រាលកូន។ ម៉្យាងវិញទៀត ការបាត់បង់ការស្តាប់ចំពោះ

កុមារមានមូលហេតុផ្សេងទៀតដូចជា គ្រោះថ្នាក់ចរាចរណ៍ គ្រឿងបំពងសម្លេង ហូរទឹកភ្នែកចូលត្រចៀក យកវត្ថុរឹងមកត្បារត្រចៀកជាដើម ទាំងអស់នេះជាកត្តាបណ្តាលឱ្យខូចក្រដាសត្រចៀក។

ពេលខ្លះការបាត់បង់ការស្តាប់ ក៏អាចបណ្តាលមកពីអាចម៍ត្រចៀកច្រើនពេក ប៉ុន្តែអាចម៍ត្រចៀកក៏អាចជួយការពារផ្នែកខាងក្នុងនៃត្រចៀកបានផងដែរ ដូច្នេះមិនត្រូវយកវាចេញទាំងអស់នោះទេ។ ផលប៉ះពាល់នៃការស្តាប់នឹងកាន់តែធ្ងន់ធ្ងរ ប្រសិនបើការបាត់បង់ការស្តាប់កើតឡើងនៅពេលកុមារកំពុងរៀននិយាយ ដែលនាំឱ្យកុមារនិយាយមិនច្បាស់ ពីព្រោះកុមារមិនអាចស្តាប់ឮច្បាស់ពីអ្វីដែលគេនិយាយ។ ប្រសិនបើកុមារបាត់បង់ការស្តាប់ក្រោយពេលគេចេះនិយាយ នោះការបាត់បង់ការស្តាប់មិនមានផលប៉ះពាល់ដល់ការនិយាយរបស់គេឡើយ។ គ្រូបង្រៀនក៏ត្រូវតែជួយជំរុញឱ្យកុមារចេះលាងសម្អាតដៃឱ្យបានស្អាតក្រោយពេលបន្ទោរបង់ផងដែរ បើពុំដូច្នោះទេ មេរោគដែលនៅជាប់ដៃនឹងឆ្លងមកត្រចៀក នៅពេលពួកគេយកម្រាមដៃមកប៉ះពាល់ត្រចៀក។

## ៤.៣ កម្រិតពិបាកក្នុងការស្តាប់

កម្រិតពិបាកក្នុងការស្តាប់ត្រូវបានបែងចែកជាបួនកម្រិតធំៗមាន កម្រិតស្រាល មធ្យម បង្គួរ និងធ្ងន់ធ្ងរ ដែលនាំមកនូវការរំខាន និងបង្កឱ្យមានការលំបាកក្នុងកិច្ចសន្ទនា និងការស្តាប់ជាដើម។

| កម្រិតពិបាកក្នុងការស្តាប់ | លក្ខណៈសម្គាល់ |
|---|---|
| **កម្រិតស្រាល** | សិស្សដែលបាត់បង់ការស្តាប់កម្រិតស្រាលមានការលំបាកខ្លះៗក្នុងការសន្ទនា ជាពិសេសនៅកន្លែងទីប្រជុំជន និងមានសំឡេងអ៊ូអរ។ |
| **កម្រិតមធ្យម** | សិស្សដែលបាត់បង់ការស្តាប់កម្រិតមធ្យម មានការលំបាកក្នុងការសន្ទនា ប្រសិនបើពួកគេមិនបានប្រើប្រាស់ឧបករណ៍ជំនួយការស្តាប់។ |
| **កម្រិតបង្គួរ** | សិស្សដែលបាត់បង់ការស្តាប់កម្រិតបង្គួរ ជារឿយៗពឹងផ្អែកយ៉ាងខ្លាំង លើការមើលចលនាបបូរមាត់បើទោះបីជាប្រើប្រាស់ឧបករណ៍ជំនួយការស្តាប់ក្តី។ |
| **កម្រិតធ្ងន់** | សិស្សដែលបាត់បង់ការស្តាប់កម្រិតធ្ងន់គឺមិនអាចស្តាប់ឮតាមរយៈការប្រើប្រាស់ឧបករណ៍ជំនួយការស្តាប់បានទេគឺត្រូវពឹងផ្អែកយ៉ាងខ្លាំងលើការមើលចលនាបបូរមាត់ និងភាសាសញ្ញា។ |



## ៤.៤ ការប្រើប្រាស់ឧបករណ៍ជំនួយការស្ដាប់

កុមារពិបាកក្នុងការស្ដាប់ពីកម្រិតស្រាលទៅកម្រិតមធ្យម អាចទទួលប្រយោជន៍ពីការប្រើប្រាស់ឧបករណ៍ជំនួយការស្ដាប់ប៉ុន្ដែឧបករណ៍នេះមិនបានធ្វើឱ្យការស្ដាប់ឮល្អដូចធម្មតាវិញនោះទេ។ នេះគឺដោយសារឧបករណ៍ជំនួយការស្ដាប់មានតួនាទីក្នុងការបង្កើនកម្រិតសំឡេងពោលគឺជួយធ្វើឱ្យសំឡេងកាន់តែឮខ្លាំងឡើងដូច្នេះ ហើយការស្ដាប់ គឺមានលក្ខណៈងាយស្រួល ហើយឧបករណ៍នេះក៏មិនបានជួយបង្កើតរលកសំឡេងបានច្បាស់ ល្អផងដែរ។ ម៉្យាងវិញទៀតសំឡេងខ្លះឮខ្លាំងជាងសំឡេងផ្សេងៗទៀតផងឧទាហរណ៍ដូចជា សំឡេងរំកិលតុ កៅអី និងសំឡេងនៅជុំវិញឮខ្លាំងជាងសំឡេងរបស់គ្រូនិយាយជាហេតុ ធ្វើឱ្យសិស្សពិបាកក្នុងការផ្ដោតអារម្មណ៍លើមេរៀន និងអ្វីដែលគ្រូកំពុងតែនិយាយ។

កុមារដែលពិបាកក្នុងការស្ដាប់ ប្រើឧបករណ៍ជំនួយការស្ដាប់នឹងអាចទទួលបានប្រយោជន៍ច្រើនពីការហាត់និយាយពីព្រោះកុមារទាំងនេះស្ដាប់ឮពាក្យដែលគេនិយាយ។ ការហាត់និយាយអាចជួយដល់កុមារ ដែលពិបាកក្នុងការស្ដាប់ឱ្យរៀននិយាយ ឬនិយាយឱ្យបានច្បាស់ ព្រោះគ្រូបង្ហាត់និយាយបង្ហាញប្រាប់កុមារពីរបៀបនិយាយពាក្យដោយឱ្យកុមារមើលរបៀបធ្វើចលនាបបូរមាត់ និងអណ្ដាតនៅពេលដែលគាត់និយាយ បន្ទាប់មកឱ្យកុមារហ្វឹកហាត់ធ្វើចលនាបបូរមាត់។

សូមបញ្ជាក់ថា ការធ្វើបែបនេះទាមទារនូវការផ្ដង់អារម្មណ៍ខ្ពស់ និងហាត់រៀនប្រើប្រាស់ឧបករណ៍ជំនួយស្ដាប់ឱ្យបានល្អក្នុងការស្វែងយល់តាមរយៈការមើលចលនាបបូរមាត់ ដើម្បីព្យាយាមយល់អំពីអ្វីដែលគេកំពុងតែនិយាយដោយប៉ាន់ស្មានលើចលនាបបូរមាត់ ទឹកមុខ អណ្ដាត និងកាយវិការរបស់គ្រូនិយាយ។ ក្នុងនេះក៏ចង់បញ្ជាក់បន្ថែមផងដែរថា កុមារដែលស្ដាប់ឮកាន់តែតិច ការធ្វើសំឡេងឱ្យដូចគឺកាន់តែពិបាក ហើយចំពោះកុមារស្ដាប់បានកម្រិតបង្គួរភាគច្រើនមិនត្រូវការ ការហាត់និយាយទេគឺត្រូវការការប្រាស្រ័យទាក់ទងតាមភាសាសញ្ញាជំនួសវិញ។



ឧបករណ៍ជំនួយស្ដាប់



ការហាត់និយាយ

### ក) របៀបប្រើប្រាស់ឧបករណ៍ជំនួយការស្ដាប់

- ប្រើឧបករណ៍ជំនួយការស្ដាប់ឱ្យបានច្រើនម៉ោងជាប្រៀងរាល់ថ្ងៃ
- ឧបករណ៍ជំនួយការស្ដាប់ត្រូវដោះទុកមុនពេលដេក និងមុនពេលងូតទឹក
- មិនត្រូវប្រើឧបករណ៍ជំនួយការស្ដាប់ពេលត្រចៀកកំពុងតែឈឺ
- ពាក់ឧបករណ៍ជំនួយការស្ដាប់ឱ្យបានត្រឹមត្រូវដោយប្រាកដថាមិនមានឮសំឡេងចេញមកខាងក្រៅ

## ខ) ការសម្អាតពុម្ពត្រចៀក

- ដោះពុម្ពចេញពីឧបករណ៍ជំនួយការស្តាប់ ហើយសម្អាតពុម្ពដោយទឹកសាប៊ូ និងជូតឱ្យស្ងួត
- ផ្ទឹះ ឬផ្លុំធូលីដែលកកស្ទះចេញពីរន្ធបញ្ចេញសំឡេងនៃពុម្ព
- សម្អាតត្រចៀកឱ្យបានស្អាតមុនពេលប្រើឧបករណ៍ជំនួយការស្តាប់
- ត្រូវច្បាស់ថារន្ធត្រចៀកមិនមានអ្វីបាំង ឬផ្ទុកណែនក្នុងពេលប្រើឧបករណ៍ជំនួយការស្តាប់ មានដូចជាអាចម៍ត្រចៀក ឬវត្ថុផ្សេងៗចុករន្ធត្រចៀក។ល។ (សូមប្រយ័ត្នកុំព្យាយាមយកអាចម៍ត្រចៀក ឬវត្ថុផ្សេងៗដោយខ្លួនឯង សូមទៅជួបគ្រូពេទ្យឯកទេសត្រចៀកដើម្បីសម្អាតចេញ)



ឧបករណ៍ និងពុម្ព



ការដោះពុម្ពចេញពីឧបករណ៍



ការផ្លុំសម្អាតពុម្ព

## គ) ការរក្សាទុក

- រក្សាទុកនៅកន្លែងមានសុវត្ថិភាព និងគ្មានសំណើម (ដាក់ក្នុងប្រអប់សុវត្ថិភាព)
- បង្កើបកុងតាក់ថ្ម ឬយកថ្មចេញ
- រក្សាឧបករណ៍ជំនួយការស្តាប់ឱ្យឆ្ងាយពីដៃកុមារ
- ហាមកុមារៗយកដុំថ្មឧបករណ៍ជំនួយការស្តាប់ដាក់ចូលក្នុងមាត់ ឬបៀមលេង



បើក

# មេរៀនទី៥៖ សិស្សពិការសតិបញ្ញា និងអូទីស្សឹម

## ខ្លឹមបំណង

ការស្វែងយល់អំពីដំណាក់កាលនៃការលូតលាស់ ផ្នែកនៃការលូតលាស់ ដំណាក់កាលនៃការលូតលាស់នៅអាយុចូលរៀន ភាពយឺតយ៉ាវនៃការលូតលាស់ និងបង្ហាញអំពីមូលហេតុ និងការបង្ការពិការសតិបញ្ញា និងអូទីស្សឹមផងដែរ។

## ខ្លឹមសារ

### ៥.១ លក្ខណៈសម្គាល់បញ្ហាសតិបញ្ញា និងអូទីស្សឹម

បើទោះបីជាមានកុមារខ្លះមានលក្ខណៈប្រហាក់ប្រហែលគ្នា ឬស្រដៀងគ្នាក៏ដោយ ក៏កុមារម្នាក់ៗមិនអាចមានលក្ខណៈដូចគ្នាទាំងអស់នោះទេ។ តួយ៉ាងបុគ្គលិកលក្ខណៈរបស់កុមារមានបញ្ហាបញ្ញាក៏មានភាពខុសគ្នា ឬដូចគ្នាទៅនឹងកុមារមិនមានពិការភាពផងដែរ។ ចំពោះចរិតលក្ខណៈវិញ គឺមានភាពយឺតយ៉ាវក្នុងការទទួលយកបំណិនដូចជា ការសម្របសម្រួលរវាងចលនាភ្នែក និងចលនាដៃ ពិបាកក្នុងការអភិវឌ្ឍជំនាញផ្នែកសង្គមដោយសារមិនយល់អំពីសញ្ញាក្នុងការប្រាស្រ័យទាក់ទងដែលមិនប្រើភាសា។

| | |
|---|---|
| **ដោនសាំងដ្រូម** | - មានកំហុសក្រូម៉ូហ្សូមដែលធ្វើឱ្យកុមារលូតលាស់យឺតយ៉ាវទាំងផ្នែករាងកាយ និងបញ្ញា<br>- មិនមានការព្យាបាលអំពីពិការដោនសាំងដ្រូមទេប៉ុន្តែអាចជួយបានតាមរយៈការគាំទ្រដោយចលនា និងដោយការបញ្ចេញសំឡេងដែលអាចជួយការពារដល់បំពង់ក និងការដកដង្ហើមផងដែរ<br>- អាចមានកម្រិត ស្រាល មធ្យម និងធ្ងន់ធ្ងរ (កម្រិតស្រាលអាចរៀននៅក្នុងថ្នាក់អប់រំបរិយាបន្នបាន)<br>- លំបាកក្នុងការជួយខ្លួនឯងដូចជា ការស្លៀកពាក់ ឬងូតទឹកជាដើម<br>- ទ្រង់ទ្រាយផ្ទៃមុខ មានដូចជា ភ្នែកបញ្ឈរឡើងលើ ត្រចៀកក្រាស់ ខើចមាត់ រង្វះមាត់តូច និងអណ្តាតលៀនចេញ<br>- មានសាច់ដុំខ្សោយ ដូចជា សាច់ដុំក ឬសាច់ដុំអណ្តាត ជាដើម<br>- មានបាតដៃ និងម្រាមដៃធំហើយខ្លី (ធម្មតាបាតដៃមានខ្សែពីរអូសកាត់បាតដៃ ហើយខ្សែមួយអូសកាត់ជុំមេដៃ ចំណែកដោនសាំងដ្រូម មានខ្សែតែមួយប៉ុណ្ណោះអូសកាត់)<br>- មានជង្គង់ញែកចេញ និងមេជើងឃ្លាតគ្នា<br>- ភាគច្រើនមានប្រព័ន្ធដង្ហើមខ្សោយ (ងាយឆ្លងជំងឺផ្តាសាយ ជំងឺរលាកទងសួត និងជំងឺនៅផ្នែកដើមទ្រូង) |

| | |
|---|---|
| **ខួចប្រព័ន្ធបញ្ញាក្នុងខួរក្បាល** | - បញ្ហានេះបណ្តាលមកពីការប៉ះទង្គិចផ្នែកណាមួយនៃខួរក្បាលជាញឹកញាប់ មុនពេលសម្រាល<br>- មានបញ្ហាលំបាកទាំងចលនាតូច និងចលនាធំ |
| **ពិការទឹកដក់ក្នុងខួរក្បាល** | - បណ្តាលមកពីការកកស្ទះវត្ថុរាវនៅក្នុងក្បាល (កើតឡើងតាំងពីទារកនៅក្នុងផ្ទៃ)<br>- ក្បាលរីកកាន់តែធំឯខួរក្បាលមិនរីកលូតលាស់<br>- អាចព្យាបាលដោយវះកាត់បាន (អាចបណ្តាលឱ្យស្លាប់បានប្រសិនបើមិនធ្វើការព្យាបាល)<br>- មានបញ្ហាលំនឹងដែលអាចប៉ះពាល់ដល់ការដើរ |
| **អូទីស្សឹម** | - ប្រភេទពិការមានសភាពស្មុគស្មាញ<br>- សញ្ញាណដំបូងកើតឡើងនៅអាយុប្រហែល២ឆ្នាំ ដែលមានលក្ខណៈសម្គាល់ដូចជាមានបញ្ហាទំនាក់ទំនងសង្គម និងមិនយល់ពីអារម្មណ៍អ្នកដទៃក៏ដូចគ្នានឹងពិបាកក្នុងការប្រាស្រ័យទាក់ទង ដូចជា មិនយល់ន័យរបស់ពាក្យ ប្រយោគ របៀបបញ្ចេញសំឡេង និងចង្វាក់នៃការនិយាយ<br>- ការបង្ហាញឥរិយាបថទន់ភ្លន់ដូចជាមានការពេញចិត្តខុសធម្មតាចំពោះអ្វីមួយ ឬទម្លាប់នឹងចំណាប់អារម្មណ៍សកម្មភាពដដែលៗ<br>- អាចពូកែជំនាញភាសា ប៉ុន្តែជំនាញសង្គមនៅមានកម្រិត<br>- ប្រហែល ៨០% នៃកុមារអូទីស្សឹមទាំងអស់នឹងមិនមានបញ្ហាបញ្ញា ឬគ្រាន់តែមានបញ្ហាបញ្ញាកម្រិតស្រាលតែប៉ុណ្ណោះ<br>- ពិបាកទំនាក់ទំនងសង្គម មានដូចជា ខ្សោយទំនាក់ទំនងតាមរយៈក្រសៃភ្នែក មិនចូលចិត្តលេងនៅក្នុងក្រុម មិនអាចធ្វើការសន្ទនាបាន កម្រនឹងមានមិត្តភក្តិ និងមិនយល់អំពីអារម្មណ៍សិស្សដទៃ<br>- ពិបាកជំនាញប្រាស្រ័យទាក់ទងមានដូចជាមិនយល់រឿងកំប្លែង មិនយល់ពីការសួរសំណួរ មិនចេះពិភាក្សា និងចែករំលែកគំនិត មិនមានការស្រមើស្រមៃ និងនិយាយមិនយល់ដដែលៗ<br>- ចូលចិត្តលេងជុំថ្ម ឬខ្សែក្នុងរយៈពេលជាច្រើនម៉ោង<br>- ចង់ធ្វើអ្វីៗតាមវិធីរបស់ខ្លួនឯង<br>- មិនចូលចិត្តប្តូរពីសកម្មភាពមួយទៅសកម្មភាពមួយទៀត |

## ៩.២ ការស្វែងយល់អំពីដំណាក់កាលនៃការលូតលាស់របស់កុមារ

ដំណាក់កាលនៃការលូតលាស់របស់កុមារ គឺជាការលូតលាស់លើកាយសម្បទា ឬអាកប្បកិរិយារបស់ទារក និងកុមារ។ វាជាព័ត៌មានដ៏សំខាន់ទាក់ទងនឹងការអភិវឌ្ឍរបស់កុមារព្រោះដំណាក់កាលនេះគឺមានភាពខុសគ្នាតាមលំដាប់អាយុកុមារ។ ឧទាហរណ៍ ការក្រឡាប់ ការលូន ឬវារ ការដើរ និងការនិយាយរបស់កុមារត្រូវបានពិចារណាថាជាដំណាក់កាលសំខាន់ ដើម្បីកំណត់ថា កុមារកំពុងតែលូតលាស់ និងអភិវឌ្ឍដូចកុមារធម្មតា។

| ចំណុចសំខាន់ទាំង៣ ត្រូវចងចាំក្នុងដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារ | |
|---|---|
| ចំណុចទី១ | ទារកភាគច្រើនក្រឡាប់នៅពេលពួកគេមានអាយុប្រហែល៣ខែ ឬចាប់ផ្តើមដើរ នៅអាយុប្រហែលជា១២ខែ ហើយអាកប្បកិរិយានេះភាគច្រើនត្រូវបានកំណត់ជាដំណាក់កាលនៃការអភិវឌ្ឍ។ នេះមិនមែនមានន័យថា ទារកម្នាក់នឹងក្រឡាប់នៅពេលដែលគេមានអាយុ ៣ខែ ឬចាប់ផ្តើមដើរបានពេលគេមានអាយុគម្រប់១ឆ្នាំនោះទេ គឺគ្រាន់តែជាការប៉ាន់ប្រមាណពេលវេលាត្រួសៗតែប៉ុណ្ណោះ។ |
| ចំណុចទី២ | ការកត់សម្គាល់ដំណាក់កាលអភិវឌ្ឍអាចខុសគ្នាខ្លះនៅតាមប្រទេសផ្សេងៗ ឧទាហរណ៍ដូចជាប្រពៃណីនៅក្នុងប្រទេសអាមេរិកជឿថា ការញញឹមលើកដំបូងរបស់ទារក គឺជាដំណាក់កាលលូតលាស់របស់កុមារ ចំពោះប្រទេសកម្ពុជាវិញគេ ប្រារព្ធពិធីបង្កក់កូននៅពេលទារកអាយុបាន១ខែ។ |
| ចំណុចទី៣ | ដំណាក់កាលអភិវឌ្ឍ អាចកើតឡើងចំពោះកុមារមានអាយុមិនដូចគ្នា ដោយអាស្រ័យលើការអនុវត្តនូវវប្បធម៌ខុសៗគ្នាក្នុងការបីបាច់កុមារ។ ឧទាហរណ៍នៅក្នុងប្រទេសលោកខាងលិច ភាគច្រើនកុមាររៀនយល់ដឹងនៅពេលដែលគេត្រូវទៅបង្គន់នៅអាយុ២ទៅ៣ឆ្នាំ។ ចំណែកឯនៅប្រទេសអាស៊ីមួយចំនួនកុមាររៀនពីចំណុចនេះតាំងពីក្មេងជាងនេះ ដូចជាអាយុប្រហែល១ឆ្នាំ ឬក៏ប្រហែលពី៦ខែ ទៅ១ឆ្នាំ ពីព្រោះម្តាយនៅអាស៊ីបង្រៀនកូនៗឱ្យចេះប្រាប់នៅពេលបត់ជើងតូច តាំងពីនៅកុមារមិនដូចម្តាយនៅប្រទេសលោកខាងលិចទេ ដែលប្រើខោទ្រនាប់កូនក្មេងការពារទៅវិញ។ |

## ៩.៣ ផ្នែកនៃការលូតលាស់របស់កុមារ

| | |
|---|---|
| ការលូតលាស់ផ្នែកចលនាតូច និងចលនាធំ | ជាសមត្ថភាពក្នុងការប្រើចលនាសាច់ដុំតូចជាពិសេសការប្រើដៃ និងម្រាមដៃ ដើម្បីចាប់កាន់វត្ថុតូចៗ កាន់ស្លាបព្រា បើកសៀវភៅ ឬកាន់ខ្មៅដៃសម្រាប់គូរ និងកាន់កន្ត្រៃ។ សមត្ថភាពសម្រាប់ប្រើចលនាធំ មានការវារ ការដើរ និងការលោត ឧទាហរណ៍ ទារកអាយុ៦ខែ រៀនអង្គុយដោយមានជំនួយខ្លះៗ ការលូតលាស់សកម្មភាពរស់នៅប្រចាំថ្ងៃនៅអាយុ១២ខែ ដោយរៀនចាប់តោងអ្វីដែលនៅជិតដើម្បីឈរ និងកុមារអាយុ៣ឆ្នាំរៀនលោត។ |
| ការលូតលាស់បញ្ញា ឬការយល់ដឹង | ជាសមត្ថភាពកុមារ ដើម្បីរៀនដោះស្រាយបញ្ហា និងការអភិវឌ្ឍផ្នែកភាសា។ កុមារក្នុងវ័យសិក្សា រៀនអាន សរសេរ និងគណនាលេខ ឧទាហរណ៍ ទារកចាប់ពី២ខែឡើង |

| | |
|---|---|
| | ទៅ ទារករៀនស្វែងរកនូវបរិយាកាសជាមួយនឹងការប្រើដៃ ភ្នែក ឬកុមារមានអាយុ ៥ឆ្នាំ រៀនដោះស្រាយលំហាត់ងាយៗ។ |
| **ការលូតលាស់ផ្នែកទំនាក់ទំនងសង្គម និងការរំជួលចិត្ត** | ជាសមត្ថភាពរបស់កុមារ សម្រាប់ទំនាក់ទំនងជាមួយអ្នកដទៃរាប់បញ្ចូលទាំងការជួយខ្លួនឯង និងការគ្រប់គ្រងខ្លួនឯង។ ឧទាហរណ៍ ការលូតលាស់ប្រភេទនេះដោយរាប់បញ្ចូលទារកចាប់ពី៦សប្តាហ៍អាចចេះសើច ទារក១០ខែ អាចលើកដៃលាគ្នាបាន កុមារអាយុ៥ឆ្នាំ យល់ដឹងពីការផ្លាស់ប្តូរវេននៅពេលលេងល្បែងសិក្សានៅសាលារៀន។ |

## ៥.៥ ដំណាក់កាលនៃការលូតលាស់របស់កុមារនៅអាយុចូលរៀន

នៅពេលចាប់ផ្តើម ដំបូងឡើយទារកពឹងផ្អែកទាំងស្រុងទៅលើអ្នកដទៃ ដើម្បីជួយបំពេញតម្រូវការរបស់ខ្លួន។ នៅពេលដែលពួកគេលូតលាស់ កុមាររៀនច្រើន និងរៀនជំនាញផ្សេងៗដែលអាចជួយឱ្យគេមានភាពជាម្ចាស់ការ និងអាចធ្វើកិច្ចការអ្វីបានដោយខ្លួនឯង។

កុមារអាយុ ៦ឆ្នាំ អាចធ្វើអ្វីបានច្រើនដោយខ្លួនឯងដូចជាការស្លៀកពាក់ ការចាប់បាល់ ការរាក់ទាក់ជាមួយភ្ញៀវដែលមកលេងផ្ទះ ជាដើម។ នៅពេលដែលកុមារចូលរៀន គាត់ចេះចាប់ផ្តើមបង្កើតមិត្តភក្តិនៅតាមភូមិ តាមសហគមន៍ ដែលមិនមែនជាបងប្អូនរបស់គាត់។ ចំណែកឯ បំណិនផ្នែកកាយសម្បទា ទំនាក់ទំនងសង្គម ចលនា និងបញ្ញាមានការលូតលាស់លឿនក្នុងដំណាក់កាលនេះ។

| ជំនាញសង្គម ការយល់ដឹង និងការលូតលាស់ផ្នែករាងកាយរបស់កុមារ | |
|---|---|
| **ជំនាញសង្គម** | - សំពះសួរមនុស្សចាស់ ដោយភាពគួរសម<br>- លេងជាមួយកុមារដទៃទៀត ដោយភាពសប្បាយរីករាយ<br>- នៅស្ងៀមស្ងាត់ម្នាក់ឯងនៅពេលមិនសប្បាយចិត្ត<br>- ចេះសុំទោសនៅពេលដឹងខ្លួនថាបានធ្វើខុស ឬសាងកំហុសអ្វីមួយ<br>- យល់ដឹងនៅពេលនរណាម្នាក់និយាយកុហក<br>- សុំការអនុញ្ញាតមុនយករបស់អ្វីមួយពីគ្រូដទៃ<br>- ចេះបង្ហាញពីអារម្មណ៍ផ្ទាល់ខ្លួន<br>- យល់ដឹងពីអារម្មណ៍របស់គ្រូដទៃ |
| **ការយល់ដឹង** | - និយាយជាប្រយោគពេញ<br>- យល់តាមការណែនាំយ៉ាងតិច៣ជំហាន<br>- ប្រើប័ណ្ណរូបភាពយ៉ាងហោចណាស់ចំនួន៣ ដើម្បីនិទានរឿង<br>- ទន្ទេញព្យញ្ជនៈ<br>- កាន់សៀវភៅរឿងបានត្រឹមត្រូវ (មិនបញ្ច្រាស)<br>- បង្ហាញភាពខុសគ្នា និងដូចគ្នា (ធំ និងតូច ក្រាស់ និងស្តើង)<br>- យល់ ឬដឹងអំពីទីតាំង ឬទិសដៅ (លើ ក្រោម ក្នុង ក្រៅ ឆ្វេង ឬស្តាំ) |

| | |
|---|---|
| | - ទន្ទេញលេខពី១ ដល់១០<br>- ចាំពណ៌នៅពេលគេបង្ហាញ<br>- ចាំបានពីទ្រង់ទ្រាយ (មូល ការេ ចតុកោណ ផ្កាយ និងបេះដូង ជាដើម)<br>- យល់ពីពេលប្រចាំថ្ងៃ (ព្រឹក ល្ងាច ថ្ងៃនេះ និងម្សិលមិញ)<br>- អាចប្រាប់បានពីថ្ងៃនៅក្នុងសប្តាហ៍ (ច័ន្ទ អង្គារ ពុធ ។ល។) |
| **ចលនាធំ** | - អាចញាំ ស្លៀកពាក់ និងចូលបង្គន់ដោយខ្លួនឯងបាន<br>- ដើរ និងរត់យ៉ាងងាយស្រួល<br>- បោះ និងចាប់បាល់បាន<br>- ឡើង និងចុះជណ្តើរដោយប្រើជើងម្ខាង |
| **ចលនាតូច** | - កាន់ខ្មៅដៃបានត្រឹមត្រូវ ដោយប្រើម្រាម៣<br>- កាន់ចង្កឹះបានត្រឹមត្រូវ ដោយចេះចាប់កៀប<br>- អាចបើកគម្របដបទឹកបាន<br>- ចេះប្រើកន្ត្រៃ<br>- ចេះហែកក្រដាស |

## ៥.៥ ភាពយឺតយ៉ាវនៃការលូតលាស់របស់កុមារ

កុមារមួយចំនួនត្រូវការពេលវេលាយូរខុសពីកុមារភាគច្រើនដែលមានការលូតលាស់ធម្មតា ឬមិនអាចលូតលាស់ទៅតាមដំណាក់កាលណាមួយ មានន័យថា កុមារមានភាពយឺតយ៉ាវក្នុងការលូតលាស់ផ្នែកការយល់ដឹង ឬកាយសម្បទា ទំនាក់ទំនងសង្គម ឬមានបញ្ហាលើផ្នែកលូតលាស់ទាំង៣តែម្តង។

| លក្ខណៈសម្គាល់ ៦ក្រុម ពាក់ព័ន្ធនឹងភាពលូតលាស់យឺតយ៉ាវ | |
|---|---|
| **ការនិយាយ** | - ការនិយាយខុសប្លែកពីកុមារដទៃដែលមានអាយុស្មើគ្នា<br>- អាចមិននិយាយទាល់តែសោះ<br>- ការនិយាយរបស់កុមារមិនអាចយល់បានក្រៅពីសមាជិកក្រុមគ្រួសាររបស់គាត់ |
| **ការយល់ដឹងអំពីភាសា** | - មិនអាចឆ្លើយសំណួរងាយៗបាន<br>- មិនអាចធ្វើតាមការណែនាំងាយៗនៅក្នុងថ្នាក់<br>- ពិបាកយល់អ្វីមួយដែលគ្រូដទៃនិយាយ បើធៀបទៅនឹងកុមារដទៃទៀត ដែលមានអាយុដំណាលគ្នា |
| **ការចូលរួមលេងជាមួយគ្រូដទៃ** | - មិនចូលចិត្តលេងជាមួយកុមារដទៃទៀត<br>- មិនចេះលេងដូចកុមារដទៃដែលមានអាយុដំណាលគ្នា |
| **ការបំលាស់ទី** | - មិនអាចរក្សាលំនឹងខ្លួនដោយជើងម្ខាងក្នុងរយៈពេលខ្លី<br>- ខុសប្លែកពីកុមារដទៃដែលមានអាយុដំណាលគ្នា |

| | |
|---|---|
| | - កម្លាំងសាច់ដុំខ្សោយក្នុងការធ្វើសកម្មភាពផ្សេងៗ បើធៀបទៅនឹងកុមារដទៃដែលមានអាយុដំណាលគ្នា |
| អាកប្បកិរិយា | - អាចផ្តោតការយកចិត្តទុកដាក់បានរយៈពេលខ្លី<br>- មានការចងចាំខ្សោយ<br>- មិនចាប់អារម្មណ៍លើមេរៀន<br>- ធ្វើសកម្មភាពបំពាន និងឆាឆៅគ្រូដទៃ |
| ការអាន និង ការសរសេរ | <u>នៅពេលអាយុបាន ៥ឆ្នាំ ឬក្រោយពីការចូលរៀនបាន១ឆ្នាំ៖</u><br>- មានការលំបាកក្នុងការចម្លងទ្រង់ទ្រាយនៃរូបមួយចំនួនជារង្វង់ ឬការ៉េ<br>- មានការលំបាកលេងល្បែងផ្គុំរូបភាព<br>- មានការលំបាកចងចាំអក្សរ ឬពាក្យនៅលើបណ្ណ<br>- សរសេរអក្សរមិនស្អាត មិនត្រង់ ឬឡើងចុះ ទៅមុខ និងទៅក្រោយ<br>- មិនអាចចងចាំលេខ ឬអក្សរចំនួន៥ ឱ្យបានត្រឹមត្រូវតាមលំដាប់ដែលបានប្រាប់ |

## ៥.៦ មូលហេតុ និងការបង្ការពិការសតិបញ្ញា និងអូទីស្សឹម

### ក) មូលហេតុពិការសតិបញ្ញា និងអូទីស្សឹម

- ពិការសតិបញ្ញាអាចបណ្តាលមកពីលក្ខខណ្ឌណាមួយ ដែលធ្វើឱ្យការលូតលាស់របស់ខួរក្បាលជួបការលំបាកមុនពេលសម្រាល អំឡុងពេលសម្រាល និងក្នុងវ័យកុមារភាព
- ប្រមាណជា១/៣នៃ កុមារទទួលរងផលប៉ះពាល់អវិជ្ជមាន ប៉ុន្តែពុំអាចរកឃើញនូវមូលហេតុច្បាស់លាស់នៅឡើយ
- បញ្ហាហ្សែនមានតាំងពីកំណើតទាក់ទងនឹងពិការខ្សោយសតិបញ្ញា ឧទាហរណ៍ ជំងឺបង្កពីប៉ារ៉ាស៊ីតឈ្មោះតុក្សូប្លាស្មា ការបាត់បង់ ឬចុះខ្សោយអង់ហ្ស៊ីម និងហ្សែនតែមួយគត់ដែលមាននៅក្នុងក្រូម៉ូហ្សូមអិច នាំទៅរកពិការសតិបញ្ញាតពូជ
- កត្តាតំណពូជដែលបណ្តាលមកពីភាពមិនប្រក្រតីរបស់ហ្សែនឪពុកម្តាយ ដូចជាដំណើរខុសប្រក្រតីនៅពេលហ្សែនប្រមូលផ្តុំគ្នា ហ្សែនបង្កឡើងក្នុងពេលមានផ្ទៃពោះដោយសារការឆ្លងរោគការថតកាំរស្មីអិចច្រើនពេក និងកត្តាផ្សេងៗទៀត
- ដោនសាំងដ្រូមបណ្តាលមកពីក្រូម៉ូហ្សូមកើតមានឡើងមិនទៀងទាត់ ដោយសារក្រូម៉ូហ្សូមច្រើនពេក ឬតិចពេក ឬដោយសារការផ្លាស់ប្តូរចនាសម្ព័ន្ធរបស់ក្រូម៉ូហ្សូម
- បញ្ហាមួយចំនួនអាចកើតឡើងក្នុងអំឡុងពេលមានផ្ទៃពោះ មានដូចជា ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនពីសំណាក់ម្តាយ កង្វះអាហារូបត្ថម្ភ ការពុលដោយសារបរិស្ថានជាក់លាក់ ម្តាយឆ្លងប៉ារ៉ាស៊ីតរបស់សត្វ រោគកញ្ជ្រិលស្រោល ឬស្អូច និងជំងឺស្វាយកាមរោគ ជាដើម
- បញ្ហាមួយចំនួនអាចកើតមានឡើងក្នុងពេលសម្រាល មានដូចជា ការសម្រាលមុនពេលកំណត់ ឬទារកកើតមកមិនគ្រប់គីឡូ អាចបណ្តាលឱ្យមានបញ្ហាធ្ងន់ធ្ងរ រំខានដល់ដំណើរការសំខាន់ៗ

ទាក់ទងនឹងការលូតលាស់របស់ខួរក្បាលនៅដំណាក់កាលដំបូង និងការថប់ដង្ហើមដោយខ្វះអុកស៊ីហ្សែនមួយរយៈ ឬការរងរបួសក្នុងពេលសម្រាលអាចបណ្តាលឱ្យមានពិការសតិបញ្ញា

- បញ្ហាផ្សេងៗក៏អាចកើតមានក្រោយពេលសម្រាលផងដែរ មានដូចជា ជំងឺក្អកមាន់ អុតស្វាយ កញ្ជ្រិល និងជំងឺរលាកស្រោមខួរ ការមានរបួសស្នាមប៉ះទង្គិចក្បាល ឬការឈ្លក់ទឹក ការពុលសារធាតុសំណបារ៉ត និងផ្នែកបរិស្ថានផ្សេងៗទៀតអាចបណ្តាលឱ្យខូចទាំងស្រុងដល់ប្រព័ន្ធខួរក្បាល និងសរសៃប្រសាទ
- កុមារលូតលាស់ជំក្នុងភាពក្រីក្រដោយពុំមានអាហារគ្រប់គ្រាន់នាំឱ្យកើតជំងឺកង្វះអាហារូបត្ថម្ភ និងពុំទទួលបាននូវការថែទាំសុខភាពគ្រប់គ្រាន់ អាចបង្កើននូវហានិភ័យចំពោះពិការសតិបញ្ញា

## ខ.ការបង្ការពិការសតិបញ្ញា និងអូទីស្សឹម

- ស្ត្រីគួរទៅពិនិត្យសុខភាពទូទៅរយៈពេល ៦ខែមុនពេលមានផ្ទៃពោះរួមមាន ការធ្វើបច្ចុប្បន្នភាពការចាក់ថ្នាំបង្ការ ការពិនិត្យមើលឡើងវិញនូវការប្រើប្រាស់ថ្នាំផ្សេងៗ ការពិនិត្យមើលឡើងវិញនូវរបបអាហារ និងការបន្ថែមវីតាមីនរួមទាំងអាស៊ីតហ្វូលីក ការប្រឹក្សាយោបល់ទាក់ទងនឹងហ្សែន និងការឈប់ទទួលទានគ្រឿងស្រវឹង បារី និងគ្រឿងញៀន
- ការថែរក្សាគភ៌អំឡុងពេលមានផ្ទៃពោះ មានដូចជា ការសម្រាក និងទទួលទានដំណេកឱ្យបានគ្រប់គ្រាន់ ការទទួលទានអាហារដែលមានសារជាតុចិញ្ចឹមច្រើន ការគេចចេញពីមនុស្សដែលមានជំងឺ និងការមិនលើករបស់អ្វីដែលធ្ងន់ ឬការធ្វើអ្វីដែលប៉ះពាល់ដល់រូបរាងកាយធ្ងន់ធ្ងរ
- ការប្រឹក្សាយោបល់អំពីហ្សែន មានដូចជា ការពាក់ព័ន្ធនឹងប្រវត្តិគ្រួសារពីការផ្តល់កំណើតពីមុនរបស់ឪពុកម្តាយទាំងសងខាងដែលធ្វើឱ្យកូនមានបញ្ហាពិការសតិបញ្ញា ម្តាយធ្លាប់បានពន្លូតកូន ២ដង ឬច្រើនជាងនេះ ឬទារកបានស្លាប់ក្នុងវ័យជាកូនង៉ែត ម្តាយមានអាយុ៣៥ឆ្នាំ ឬលើសពីនេះ និងដៃគូណាមួយជាពូជសាសន៍ ឬក្រុមជនជាតិភាគតិចដែលមានឧប្បត្តិហេតុខ្ពស់ទាក់ទងនឹងលក្ខខណ្ឌហ្សែន ឬដៃគូដែលជាប់សាច់ឈាមនឹងគ្នា
- ពិការសតិបញ្ញាអាចការពារបាននៅក្នុងវ័យកុមារភាពតាមរយៈការដឹងពីមូលហេតុ និងការចាត់វិធានការនានាដើម្បីធ្វើឱ្យកុមារមានសុវត្ថិភាព និងសុខភាពល្អ ក្នុងនោះរួមមានការចាក់ថ្នាំបង្ការនៅក្នុងវ័យកុមារភាពដើម្បីការពារកុមារកុំឱ្យមានជំងឺយ៉ាងហោចណាស់ចំនួន៦មុខដែលអាចធ្វើឱ្យខូចខួរក្បាលរបស់កុមារ ហើយជំងឺទាំងនេះមាន កញ្ជ្រិល ក្រឡែនទែន ក្អកមាន់ រលាកស្រោមខួរ អុតស្វាយ និងរលាកសួតជាដើម
- ការការពារកុំឱ្យមានរបួសដើម្បីចៀសវាងការខូចខួរក្បាល ដូចជាការប្រើប្រាស់មួកសុវត្ថិភាពសម្រាប់ជិះកង់ និងកន្លែងអង្គុយដែលមានសុវត្ថិភាពព្រមទាំងដាក់ខ្សែក្រវ៉ាត់ពេលជិះរថយន្ត ការការពារការឈ្លក់ទឹក ការការពារការធ្លាក់ និងការការពារកុមារពីការក្រឡុកខ្លាំងៗ
- ការពិនិត្យមើលក្រោយពីការសម្រាលភ្លាមៗដើម្បីរកមើលនូវលក្ខណៈផ្សេងៗរបស់ហ្សែនដែលអាចព្យាបាលបាន

- ការកាត់បន្ថយការប្រឈមនឹងការបំពុលដោយសារជាតុសំណ បារ៉ត និងសារជាតុផ្សេងទៀត នៅក្នុងបរិស្ថានដែលគេដឹងឮថាធ្វើឱ្យខូចខួរក្បាល
- ការការពារកុមារពីផលិតផលដែលមានជាតិពុលផ្សេងៗនៅផ្ទះផងដែរ

| កម្រិតកម្សោយបញ្ញា | |
|---|---|
| កម្រិតស្រាល | - ពិន្ទុ IQ ចាប់ពី៥០ ទៅ ៧០<br>- មានភាពយឺតយ៉ាវជាងកុមារទូទៅនៅគ្រប់ផ្នែកទាំងអស់នៃការលូតលាស់<br>- លក្ខណៈផ្នែករាងកាយមិនមានភាពខុសធម្មតាទេ<br>- មានសមត្ថភាពក្នុងការរៀនពីបំណិនជីវិតដោយការអនុវត្តផ្ទាល់<br>- អាចទទួលបានបំណិនក្នុងការអាន និងគណិតវិទ្យាកម្រិតថ្នាក់ទី៣-៦ មានសមត្ថភាពក្នុងការចូលរួមសង្គម<br>- មានសមត្ថភាពប្រតិបត្តិសម្រាប់ជីវិតប្រចាំថ្ងៃ<br>- ប្រមាណជា៨៥% ស្ថិតក្នុងកម្រិតស្រាល អាចសម្រេចបានជោគជ័យក្នុងការសិក្សា ពួកគេអាចចេះអាន ប៉ុន្តែមានការលំបាកក្នុងការយល់ដឹងពីអ្វីដែលគេអាន |
| កម្រិតមធ្យម | - ពិន្ទុ IQ ពី៣៥ ទៅ ៤៩<br>- ភាពយឺតយ៉ាវក្នុងការលូតលាស់គួរឱ្យកត់សម្គាល់ (ការនិយាយស្តី និងបំណិនចលនា)<br>- អាចមានសញ្ញានៃការលំបាកផ្នែករាងកាយ (អណ្តាតក្រាស់)<br>- អាចប្រាស្រ័យទាក់ទងក្នុងកម្រិតដំបូងក្នុងលក្ខណៈងាយៗ<br>- មានសមត្ថភាពរៀនពីបំណិនផ្នែកសុខភាព និងសុវត្ថិភាពជាមូលដ្ឋាន<br>- មានលទ្ធភាពមើលថែខ្លួនឯងបាន<br>- អាចធ្វើដំណើរតែម្នាក់ឯងបានទៅទីកន្លែងជិតៗដែលធ្លាប់ស្គាល់<br>- អាចប្រាស្រ័យទាក់ទងបានខ្លះ ប៉ុន្តែមិនអាចប្រាស្រ័យទាក់ទងក្នុងលក្ខណៈស្មុគស្មាញបានទេ<br>- មានការលំបាកចំពោះស្ថានភាពសង្គម និងមានបញ្ហាក្នុងការយល់ពីព្រឹត្តិការណ៍ និងវិនិច្ឆយកិច្ចការសង្គម<br>- អាចមើលថែខ្លួនឯងបាន ប៉ុន្តែត្រូវការការណែនាំ និងការគាំទ្រច្រើនជាងមនុស្សធម្មតា<br>- ១០% ស្ថិតក្នុងកម្រិតមធ្យម អាចរស់នៅដោយម្ចាស់ការបាន ប៉ុន្តែពេលខ្លះពួកគេមួយចំនួននៅតែត្រូវការការគាំទ្រពីក្រុមគ្រួសារ ឬគ្រូនៅជាមួយ |
| កម្រិតធ្ងន់ | - ពិន្ទុ IQ ចាប់ពី ២០ ទៅ ៣៤<br>- ការគិតពិចារណាមានការលូតលាស់យឺតយ៉ាវ<br>- យល់ពីការនិយាយស្តី ប៉ុន្តែមានលទ្ធភាពតិចតួចក្នុងការប្រាស្រ័យទាក់ទង<br>- មានសមត្ថភាពរៀនពីសកម្មភាពទម្លាប់ប្រចាំថ្ងៃ |

| | |
|---|---|
| | - អាចរៀនមើលថែខ្លួនឯងដែលមានលក្ខណៈងាយៗ<br>- ត្រូវការមើលថែដោយផ្ទាល់ពីសង្គម<br>- តាមរយៈការធ្វើរោគវិនិច្ឆ័យប្រមាណ ៣% ឬ៤% ប៉ុណ្ណោះស្ថិតក្នុងកម្រិតធ្ងន់អាចប្រាស្រ័យទាក់ទងគ្នាក្នុងកម្រិតដំបូង ហើយពួកគេមិនអាចអនុវត្តសកម្មភាពមើលថែខ្លួនឯងដោយម្ចាស់ការបានទេ ដូច្នេះពួកគេត្រូវការថែទាំ និងការគាំទ្រប្រចាំថ្ងៃ<br>- ភាគច្រើនសិស្សស្ថិតនៅក្នុងកម្រិតនេះ មិនអាចរស់នៅ បានដោយជោគជ័យក្នុងជីវិតម្ចាស់ការបានទេ ហើយពួកគេចាំបាច់ត្រូវរស់នៅក្នុងមណ្ឌលប្រមូលផ្ដុំ |
| កម្រិតធ្ងន់ធ្ងរ | - ពិន្ទុ IQ ទាបជាង ២០<br>- មានភាពយឺតយ៉ាវខ្លាំងក្នុងការលូតលាស់គ្រប់ផ្នែកទាំងអស់<br>- រាងកាយ និងបញ្ញាមានភាពមិនប្រក្រតីតាំងពីកំណើត<br>- តម្រូវឱ្យមានការថែទាំយ៉ាងជិតដល់<br>- តម្រូវឱ្យមានគ្រូមើលថែលើសកម្មភាពប្រចាំថ្ងៃ និងសកម្មភាពមើលថែខ្លួនឯង<br>- មិនអាចមានលទ្ធភាពរស់នៅដោយម្ចាស់ការទេ<br>- ជនខ្សោយបញ្ញាធ្ងន់ធ្ងរត្រូវការគាំទ្រ និងថែរក្សាទាំងយប់ថ្ងៃ ព្រោះពួកគេត្រូវពឹងផ្អែកលើអ្នកដទៃទាំងស្រុង ចំណែកឯសមត្ថភាពក្នុងការប្រាស្រ័យទាក់ទងមានកម្រិតទាបបំផុត<br>- ជាទូទៅ ជនប្រភេទនេះពិបាកធ្វើចលនាជាខ្លាំង ហើយប្រមាណជា១% ទៅ ២% ស្ថិតនៅក្នុងភាពខ្សោយសតិបញ្ញាកម្រិតធ្ងន់ធ្ងរ |

# មេរៀនទី៦៖ ប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទងល្អ

## វត្ថុបំណង

ក្នុងមេរៀននេះប្រាប់អំពីការប្រាស្រ័យទាក់ទងរវាងសារប្រើសំដី និងសារមិនប្រើសំដី និងបង្ហាញអំពីលំនាំនៃការប្រាស្រ័យទាក់ទងរវាងអ្នកបញ្ជូនសារ និងអ្នកទទួលសារ និងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព។

## ខ្លឹមសារ

### ៦.១ ការប្រាស្រ័យទាក់ទង

ការរស់នៅក្នុងសង្គមមួយមនុស្សគ្រប់រូបត្រូវការ ការប្រាស្រ័យទាក់ទង និងការចែករំលែកព័ត៌មានពីគ្នាទៅវិញទៅមកជារឿងចាំបាច់បំផុតព្រោះថាបើគ្មានការប្រាស្រ័យទាក់ទងទេគឺគ្មានសង្គមឡើយ។ ពិតប្រាកដណាស់នៅក្នុងសាលារៀនវិញ នាយកសាលាចាំបាច់ត្រូវនិយាយទៅកាន់គ្រូបង្រៀន សិស្ស និងមាតាបិតា ឬអ្នកអាណាព្យាបាលសិស្ស។ រីឯនៅក្នុងថ្នាក់រៀនវិញគ្រូបង្រៀនត្រូវការនិយាយទៅកាន់សិស្ស ឬប្រើវិធីផ្សេងៗដូចជា ការអាន ការសរសេរ ការប្រើរូបភាព ការប្រើនិមិត្តសញ្ញា ការប្រើក្រសែភ្នែក ការប្រើភាសាកាយវិការ និងទឹកមុខជាដើមដើម្បីឱ្យយល់ពីគ្នាទៅវិញទៅមកដែលជាវិធីដ៏ល្អមួយក្នុងការប្រាស្រ័យទាក់ទងដើម្បីឱ្យទទួលបានព័ត៌មាន និងការគ្រប់គ្រងថ្នាក់រៀនបានល្អ។

ជាញឹកញាប់នាយកសាលាសរសេរ និងផ្ញើសំបុត្រទៅកាន់មាតាបិតាសិស្ស និងគ្រូបង្រៀន ហើយពេលខ្លះគ្រូបង្រៀនក៏ផ្ញើសៀវភៅទំនាក់ទំនងជាមួយមាតាបិតាសិស្សដើម្បីជម្រាបជូនពីការសិក្សា ឬអាកប្បកិរិយារបស់កូនគាត់ផងដែរ។ ពិតប្រាកដណាស់ ការប្រាស្រ័យទាក់ទងគឺជាកត្តាមួយដ៏សំខាន់នៅក្នុងថ្នាក់រៀនដែលគ្រូ និងសិស្សត្រូវយល់ពីគ្នា និងសហការគ្នាទៅវិញទៅមកដើម្បីឱ្យការបង្រៀន និងរៀនប្រកបដោយ ប្រសិទ្ធភាព និងឱ្យសិស្សសម្រេចបាននូវគោលដៅនៃការសិក្សារបស់ពួកគេរួមទាំងសិស្សមានពិការភាព និងពុំមានពិការភាព។ ប៉ុន្តែពេលខ្លះ ប្រសិនបើការប្រាស្រ័យទាក់ទងរវាងគ្រូ និងសិស្សពុំបានល្អ និងដោយរលូនទេនោះ ជាពិសេសការប្រាស្រ័យទាក់ទងជាមួយសិស្សមានពិការភាព ដូច្នេះគ្រូពុំអាចជួយឱ្យពួកគេទទួលបានលទ្ធផលល្អពីការសិក្សា ឬសម្រេចបានជោគជ័យនោះឡើយពីព្រោះគ្រូពុំដឹងពីតម្រូវការពិសេសរបស់សិស្សមានពិការភាព។

#### ក) សារប្រើសំដី៖

អាចធ្វើឡើងតាមរយៈការនិយាយដើម្បីប្រាស្រ័យទាក់ទង មានដូចជា ការពន្យល់មេរៀន ការសួរសំណួរសិស្ស ការអាន ការនិយាយ ការពិភាក្សាក្រុម ការប្រជុំ សម្ភាសន៍ និងការនិយាយតាមទូរស័ព្ទ។

#### ខ) សារមិនប្រើសំដី៖

សារមិនប្រើសំដីគឺជាការប្រាស្រ័យទាក់ទងតាមរយៈមធ្យោបាយផ្សេងៗដូចជា ការចង្អុល ការធ្វើត្រាប់តាម ការបង្ហាញទឹកមុខ ការទាក់ទងតាមខ្សែភ្នែក ការធ្វើកាយវិការ ការប្រើភាសាសញ្ញា ការសរសេរសំណួរលើក្ដារខៀន ការសរសេរលិខិតឆ្លើយឆ្លង សារាចរ របាយការណ៍ ព្រឹត្តិប័ត្រព័ត៌មាន និងការផ្សាយពាណិជ្ជកម្ម។

## ៦.២ លំនាំនៃការប្រាស្រ័យទាក់ទង




ដើម្បីឱ្យការប្រាស្រ័យទាក់ទងមានប្រសិទ្ធភាពកើតឡើង ចាំបាច់ត្រូវមានកិច្ចការពីរយ៉ាង។ កិច្ចការទីមួយ ត្រូវមានភាគីចំនួនពីរ គឺ**អ្នកបញ្ជូនសារ** និង**អ្នកទទួលសារ** ពីព្រោះ**សារ** គឺជាព័ត៌មាន គោលគំនិត ដំបូន្មាន ឬក៏ជាបញ្ហា ដែលភាគីទាំងពីរត្រូវបញ្ជូន និងទទួល។ កិច្ចការទីពីរ តម្រូវឱ្យអ្នកបញ្ជូន និងអ្នកទទួលត្រូវយល់ច្បាស់អំពីសារត្រូវបញ្ជូន និងទទួល។

ក្នុងម៉ោងបង្រៀន គ្រូត្រូវធ្វើយ៉ាងណាឱ្យការប្រាស្រ័យទាក់ទងមានលក្ខណៈច្បាស់លាស់ ព្រោះថាសិស្សទាំងអស់មានរបៀបរៀនខុសប្លែកពីគ្នា។ សិស្សខ្លះរៀនចេះតាមរយៈការមើល និងសិស្សខ្លះទៀតតាមរយៈការស្តាប់ ហើយប្រសិនបើគ្រូចេះប្រើវិធីផ្សេងៗនៃការប្រាស្រ័យទាក់ទងបានល្អសម្រាប់ការបង្រៀន គឺពិតប្រាកដណាស់ សិស្សនឹងទទួលបានលទ្ធផលសិក្សាល្អ ហើយគ្រូក៏អាចជួយសិស្សឱ្យរៀនសូត្របានច្រើនទៀតផង។

## ៦.៣ ប្រសិទ្ធភាពនៃការប្រាស្រ័យទាក់ទង

ដើម្បីឱ្យការប្រាស្រ័យទាក់ទងជាមួយសិស្សប្រកបដោយប្រសិទ្ធភាព គ្រូបង្រៀនគួរអនុវត្តដូចជា ឈរកន្លែងណាដែលសិស្សទាំងអស់អាចមើលឃើញ បែរមុខទៅរកសិស្សហើយចល័តចុះឡើង និងឈរឱ្យបានច្រើនជាងអង្គុយ។ ម្យ៉ាងវិញទៀត គ្រូក៏ត្រូវអនុវត្តវិធីនៃការប្រាស្រ័យទាក់ទងទៅតាមប្រភេទពិការភាពរបស់សិស្សផងដែរ ឧទាហរណ៍ ប្រសិនបើគ្រូមានសិស្សដែលមានបញ្ហាមើលនៅក្នុងថ្នាក់រៀន គ្រូត្រូវនិយាយពន្យល់ឱ្យបានច្រើនអំពីអ្វីៗដែលគ្រូកំពុងធ្វើ ដូចជា កិច្ចការផ្ទះដែលគ្រូកត់លើក្តារខៀនហើយឱ្យសិស្សចម្លង ដូច្នេះសិស្សអាចយល់នូវអ្វីដែលកំពុងកើតឡើងនៅក្នុងថ្នាក់រៀន។ មិនតែប៉ុណ្ណោះ គ្រូត្រូវនិយាយឱ្យបានច្បាស់ៗ ចំៗ នូវចំណុចអ្វីដែលចង់និយាយដោយប្រើសំឡេងខ្លាំង (ប៉ុន្តែមិនមែនស្រែកទេ) និងល្បឿននិយាយឱ្យបានសមស្រប សម្រួលពាក្យឱ្យងាយៗស្រួលស្តាប់ ប្រើប្រយោគខ្លីៗល្មម សម្រួលការពន្យល់ណែនាំរបស់គ្រូឱ្យបានខ្លី និងងាយយល់។ គ្រូគួរសួរសិស្សឱ្យបានញឹកញាប់ដើម្បីឱ្យប្រាកដថាសិស្សយល់ដែរឬទេ ដោយឱ្យសិស្សថាតាមនូវអ្វីដែលគ្រូបានប្រាប់ ឬនិយាយតាមគំនិតរបស់គេ។

គ្រូត្រូវចេះទាញចំណាប់អារម្មណ៍ពីសិស្សឱ្យចេះស្រង់យកព័ត៌មានសំខាន់ៗ និងឱ្យពួកគេផ្ទង់អារម្មណ៍ស្តាប់ដោយយកចិត្តទុកដាក់ តាមរយៈការប្រើកាយវិការ ទឹកមុខ និងក្រសែភ្នែកពេលនិយាយ។ មិនតែប៉ុណ្ណោះ ការលើកទឹកចិត្តសិស្សឱ្យចូលរួមបញ្ចេញយោបល់ និងសកម្មភាពថ្នាក់រៀននានា ការស្វែងយល់អំពីការលំបាកក្នុងការប្រាស្រ័យទាក់ទងជាមួយសិស្សរួមថ្នាក់ ឬសិស្សដទៃទៀត ក៏ពិតជាមានសារៈសំខាន់ផងដែរ។ លើសពីនេះទៅទៀត គ្រូអាចប្រើវិធីផ្សេងៗ ក្នុងការប្រាស្រ័យទាក់ទងជាមួយសិស្សប្រកបដោយប្រសិទ្ធភាពផងដែរ មាន

ការប្រើរូបភាព គំនូរ កាយវិការ ភាសាសញ្ញា គំនូសផ្សេងៗបន្ថែមលើការនិយាយ ការអាន និងការសរសេរ។ ការប្រាស្រ័យទាក់ទងទាំងការប្រើពាក្យសំដី និងមិនប្រើពាក្យសំដី ពិតជាមានសារៈសំខាន់ណាស់ដែលគ្រូចាំបាច់ត្រូវប្រើប្រាស់គ្រប់ពេលវេលានៃការបង្រៀន។ ការប្រាស្រ័យទាក់ទងប្រកបដោយ ប្រសិទ្ធភាពអាចឱ្យសិស្សងាយទទួលយកនូវចំណេះដឹង កាត់បន្ថយជាអតិបរមា ឬលុបបំបាត់នូវបញ្ហា និងឧបសគ្គផ្សេងៗដែលធ្វើឱ្យការប្រាស្រ័យទាក់ទងគ្នាគ្មានប្រសិទ្ធភាព។

ការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពពិតជាការចាំបាច់ណាស់សម្រាប់គ្រូបង្រៀនពាក់ព័ន្ធនឹងការបង្កើនគុណភាពនៃការបង្រៀនដែលជំរុញឱ្យឆ្ពោះទៅរកទំនាក់ទំនងវិជ្ជមាន និងលើកកម្ពស់ការសិក្សារបស់សិស្សមានពិការភាពគ្រប់កម្រិត។ ដើម្បីឱ្យការប្រាស្រ័យទាក់ទងកាន់តែប្រកបទៅដោយប្រសិទ្ធភាព គ្រូបង្រៀនគួរពិចារណាលើយុទ្ធសាស្ត្រដូចខាងក្រោម៖

- ប្រើភាសា និងនិយាយទៅកាន់សិស្សឱ្យច្បាស់ៗ ទៅតាមកម្រិតអាយុ និងសមត្ថភាពរបស់សិស្ស និងមិនគួរប្រើសំនួនវោហាសព្ទ ដែលអាចធ្វើឱ្យសិស្សមានការភាន់ច្រឡំ ឬមិនយល់ ឬអាចឱ្យសិស្សអាក់អន់ស្រពន់ចិត្តក៏មាន
- ផ្ដល់មតិស្ថាបនាកែលម្អដែលជាក់លាក់ និងទាន់ពេល រួមមានការលើកសរសើរពីចំណុចខ្លាំង និងសមិទ្ធផលរបស់សិស្ស ដូចគ្នានឹងផ្ដល់យោបល់កែលម្អដោយសេចក្ដីគោរព និងការគាំទ្រ
- ស្ដាប់សិស្សដោយយកចិត្តទុកដាក់ដើម្បីឱ្យដឹងអំពី តម្រូវការ កង្វល់ និងអ្វីដែលពួកគេចង់បានពិតប្រាកដ
- បង្ហាញចំណាប់អារម្មណ៍ និងភាពចង់ដឹងដូចគ្នានឹងសួរសំណួរបើកចំហ ដើម្បីបង្ហាញពីទឹកចិត្តគាំទ្រក្នុងកិច្ចសន្ទនា និងការយល់ចិត្តគ្នាទៅវិញទៅមក
- សម្របទៅតាមបរិបទទំនាក់ទំនង និងវិធីសាស្ត្រសមស្រប ដើម្បីបំពេញចំណង់ចំណូលចិត្ត និងតម្រូវការរបស់សិស្ស ឧទាហរណ៍ សិស្សខ្លះទទួលផលពីសម្ភារៈដែលអាចមើលឃើញ ហើយយល់បានច្បាស់ពីកាយវិការ ឬភាសាសញ្ញា ខណៈដែលសិស្សផ្សេងទៀតពេញចិត្តធ្វើការទំនាក់ទំនងតាមរយៈពាក្យសំដី និងការសរសេរ
- សហការជាមួយគ្រូបង្រៀនរួមអាជីព ឪពុកម្ដាយ ឬអ្នកអាណាព្យាបាល គ្រូជំនាញឯកទេស ដទៃទៀតពាក់ព័ន្ធនឹងការអប់រំរបស់សិស្ស
- ចែករំលែកព័ត៌មាន ធនធាន និងការអនុវត្តល្អ ដើម្បីស្វែងរកមតិយោបល់ និងដំបូន្មានចាំបាច់ ដើម្បីពង្រឹងទំនាក់ទំនងល្អ

## សារគន្លឹះក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព

- ឈរឱ្យសមរម្យនៅមុខកុមារនៅពេលនិយាយទៅកាន់ពួកគេដើម្បីឱ្យកុមារទាំងអស់អាចមើលឃើញ
- និយាយឱ្យឮច្បាស់
- ប្រើប្រាស់ពាក្យសាមញ្ញ និងប្រយោគខ្លីៗ
- ផ្ដល់ការណែនាំម្ដងមួយៗ
- ប្រើប្រាស់វិធីប្រាស្រ័យទាក់ទងផ្សេងៗ
- និយាយព័ត៌មានសារឡើងវិញ
- ធ្វើការប្រាស្រ័យទាក់ទងឱ្យសាមញ្ញបំផុត ជាមួយសិស្សមានបញ្ហាសិតិបញ្ញា និងអូទីស៊ឹម
- ត្រូវអនុវត្តការនិយាយ បើទោះបីនៅក្នុងករណីកុមារនិយាយមិនច្បាស់ក៏ដោយ
- ប្រសិនបើកុមារនិយាយមិនច្បាស់ ត្រូវលើកទឹកចិត្តឱ្យកុមារប្រើប្រាស់កាយវិការ ឬសញ្ញាអមជាមួយការនិយាយ
- ប្រាប់សារៈសំខាន់ទៅកាន់កុមារ ដោយនិយាយថា "ស្ដាប់ដោយប្រុងប្រយ័ត្ន"
- ពិនិត្យការយល់ដឹងរបស់កុមារ ដោយឱ្យពួកគេនិយាយសាឡើងវិញនូវអ្វីដែលគ្រូបានពន្យល់
- លើកទឹកចិត្តកុមារឱ្យសួរ ប្រសិនបើពួកគេមិនយល់ ដោយលើកដៃសួរ
- ឱ្យមិត្តរួមថ្នាក់ និងបងប្អូនប្រុសស្រីប្រាស្រ័យទាក់ទងជាមួយកុមារ ដែលមានការពិបាកក្នុងការប្រាស្រ័យទាក់ទង
- ប្រើប្រាស់កាយវិការ ឬភាសាសញ្ញាអមនឹងការនិយាយ
- ផ្ដល់ពេលវេលាសមស្របដល់សិស្សឱ្យឆ្លើយសំណួររាល់ពេលសួរសំណួរម្ដងៗ
- សិស្សនឹងមានទំនុកចិត្តកាន់តែខ្លាំងក្នុងការឆ្លើយសំណួរ ប្រសិនបើពួកគេមិនត្រូវបានសើចចំអកដាក់ទណ្ឌកម្ម ឬធ្វើឱ្យទទួលរងនូវការអាម៉ាស់ ចំពោះសិស្សដទៃទៀតនៅក្នុងថ្នាក់រៀន
- និយាយសរសើរ និងលើកទឹកចិត្តដល់សិស្សគ្រប់ពេល
- មានមូលហេតុជាច្រើននាំឱ្យមានការប្រាស្រ័យទាក់ទង ហើយត្រូវចងចាំថាការប្រាស្រ័យទាក់ទងនេះគឺជាផ្នែកដ៏សំខាន់មួយនៃជីវិតរបស់យើង ប្រសិនបើកុមារដែលមិនយល់អាចបង្កឱ្យមានការលំបាកក្នុងការយល់មេរៀន។

# មេរៀនទី៧៖ ការគ្រប់គ្រងថ្នាក់រៀនសិស្សមានពិការភាព

## ខ្លឹមសារ

## វត្ថុបំណង

នៅក្នុងមេរៀននេះបង្ហាញអំពីរបៀបនៃការរៀបចំថ្នាក់រៀនប្រកបដោយភាពទាក់ទាញ និងប្រាប់អំពីប្រសិទ្ធភាពនៃការគ្រប់គ្រងអាកប្បកិរិយា និងការបង្រៀនតាមបែបវិជ្ជមានចំពោះសិស្សមានពិការភាព។

## ខ្លឹមសារ

### ៧.១ ថ្នាក់រៀនសិស្សពិបាកក្នុងការមើល

ការរៀបចំថ្នាក់រៀនចាំបាច់ត្រូវពិចារណាលើភាពសមស្រប ដើម្បីជួយសម្រួលដល់ការរៀនសូត្ររបស់សិស្សពិបាកក្នុងការមើល ដូចនេះសំខាន់បំផុតគ្រូបង្រៀនត្រូវធ្វើការកែសម្រួលថ្នាក់រៀនឱ្យឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សិស្ស កុំឱ្យពួកគេមានអារម្មណ៍ថា គាត់ត្រូវបានគេផាត់ចេញពីមិត្តរួមថ្នាក់ និងឱ្យពួកគេចេះបង្កើតនូវទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធជាមួយគ្នា។

- អនុវត្តប្រព័ន្ធមិត្តជួយមិត្ត ក្នុងនោះអាចឱ្យសិស្សពិបាកក្នុងការមើលអង្គុយជាដៃគូជាមួយសិស្សបាត់បង់គំហើញទាំងស្រុង ដោយថ្នាក់រៀនត្រូវតុបតែងកែលម្អ ហើយមិត្តរបស់គាត់អាចប្រាប់អំពីព័ត៌មានថ្មីៗ និងអ្វីៗដែលមាននៅក្នុងថ្នាក់រៀន
- គ្រូក៏ត្រូវបង្រៀនសិស្សផងដែរអំពីរបៀបការពារខ្លួនពាក់ព័ន្ធនឹងការសង្គ្រោះបន្ទាន់ ដូចជាករណីភ្លើងឆេះ  និងករណីអាចនឹងមានគ្រោះថ្នាក់នៅទីធ្លាលេងរបស់សិស្ស ជាដើម
- គែមជណ្តើរ និងជ្រុងណាមួយនៅក្នុងថ្នាក់រៀនត្រូវលាបពណ៌ភ្លឺល្អ
- សរសេរចំណងជើងមេរៀនធំៗ ដើម្បីឱ្យសិស្សអាចស្វែងយល់ខ្លឹមសារមេរៀន
- រៀបចំថ្នាក់រៀនឱ្យបានល្អដើម្បីបង្កភាពងាយស្រួលដល់សិស្សក្នុងការចល័ត ឬធ្វើការបំលាស់ទីបានយ៉ាងងាយស្រួល ជាពិសេសចំពោះសិស្សពិបាកក្នុងការមើល និងសិស្សពិបាកធ្វើចលនាដែលពួកគេអាចប្រើប្រាស់ឈើច្រត់ ឬរទេះរុញបាន
- ចំពោះសិស្សដែលពិបាកក្នុងការមើល គ្រូបង្រៀនអាចរៀបចំបង្គុយតាមតម្រូវរបស់សិស្ស

### ៧.២ ថ្នាក់រៀនសិស្សពិបាកក្នុងការស្តាប់

ថ្នាក់រៀនត្រូវរៀបចំឱ្យមាននូវសោភ័ណភាពទាក់ទាញ និងដាក់តាំងស្នាដៃរបស់សិស្សលើជញ្ជាំង ដើម្បីធ្វើឱ្យពួកគេមានមោទនភាព និងចង់មករៀន ក៏ដូចជាសណ្តាប់ធ្នាប់នៅក្នុងថ្នាក់រៀនផងដែរ។ ការគ្រប់គ្រងថ្នាក់រៀនសម្រាប់សិស្សពិបាកក្នុងការស្តាប់អាចមានការលំបាក ប៉ុន្តែអ្វីដែលអាចជួយសិស្សឱ្យរៀនសូត្របាននៅក្នុងថ្នាក់រៀន គ្រូគប្បីត្រូវប្រើយុទ្ធសាស្ត្រក្នុងការជួយពង្រឹងសមត្ថភាពដល់សិស្សឱ្យទទួលបានលទ្ធផលល្អពីការរៀនសូត្រ ដើម្បីធានាថាសិស្សមានទំនុកចិត្តកាន់តែខ្ពស់លើសមត្ថភាពរៀនសូត្ររបស់ពួកគេ។

**យុទ្ធសាស្ត្រដែលគ្រូបង្រៀនគួរពិចារណាក្នុងការប្រើប្រាស់**

- ប្រើប្រាស់សម្ភារៈជំនួយការស្តាប់ការបង្រៀន និងទាក់ទាញចំណាប់អារម្មណ៍
- ប្រើប្រាស់បច្ចេកវិទ្យាមានដូចជា ថាប់ប្លេត ទូរទស្សន៍ និងស្លាយ ជាដើម
- មានគ្រូជំនួយបកប្រែភាសាសញ្ញា (ភាសាសញ្ញាកម្ពុជាត្រូវបានធ្វើបច្ចុប្បន្នកម្មថ្មីៗ)
- សរសេរចំណងជើងមេរៀនធំៗ ដើម្បីឱ្យសិស្សអាចស្វែងយល់ខ្លឹមសារមេរៀន
- តម្រូវឱ្យសិស្សធ្វើការងារជាក្រុមតូច និងក្រុមធំ
- ទម្លាប់ឱ្យសិស្សរៀនសូត្រពីគ្នាទៅវិញទៅមកតាមរយៈដៃគូ
- ប្រើប្រាស់ភាសានិយាយឱ្យបានសមរម្យជាផ្នែកមួយជួយសិស្សក្នុងការរៀននិយាយ
- រៀបចំកៀន ឬជ្រុងបណ្ណាល័យសម្រាប់ដាក់សៀវភៅរឿង ទស្សនាវដ្ដីសម្រាប់អាន ឬល្បែងសាមញ្ញមួយចំនួនដែលកុមារអាចយកមកអាន និងលេងបាននៅពេលធ្វើកិច្ចការចប់សព្វគ្រប់
- ព្យួរផ្ទាំងរូបភាពស្នាដៃសិស្ស រូបមន្ត ពាក្យស្លោក និងតារាងផ្សេងៗ នៅលើជញ្ជាំងក្នុងកម្រិតកម្ពស់ដែលកុមារអាចមើលឃើញ ចៀសវាងជ្រើសរើសយកតែស្នាដៃដែលជាគំរូល្អបំផុតមកដាក់តាំងបង្ហាញ
- ឱ្យសិស្សមានតម្រូវការពិសេសអង្គុយជិតគ្រូ និងជិតក្ដារខៀន
- រៀបចំតុសិស្សតាមលទ្ធភាពដាក់ស្តែងដូចជា កន្លះរង្វង់ ឬអក្សរ (U) ឬតាមភាពបត់បែនជាក់ស្តែង

## ៧.៣ ថ្នាក់រៀនសិស្សពិការសតិបញ្ញា និងអូទីស្ស៊ីម

ការគ្រប់គ្រងអាកប្បកិរិយាគឺជាសមាសភាពមួយដ៏សំខាន់នៅក្នុងប្រសិទ្ធភាពនៃការបង្រៀន និងរៀននៅវិទ្យាល័យអប់រំពិសេស ក្នុងនោះផងដែរ សំដៅទៅលើយុទ្ធសាស្ត្រ និងបច្ចេកទេសដែលគ្រូប្រើប្រាស់ដើម្បីបង្កើត និងរក្សានូវបរិយាកាសសិក្សារៀនសូត្រប្រកបដោយភាពសប្បាយរីករាយ សម្រាប់សិស្សមានតម្រូវការពិសេស និងសមត្ថភាពផ្សេងៗគ្នា។

ការគ្រប់គ្រងអាកប្បកិរិយាអាចជួយសិស្សឱ្យចេះអភិវឌ្ឍខ្លួន ជំនាញសង្គម ជំនាញសិក្សា និងសុខុមាលភាពផ្លូវចិត្ត ហើយអត្ថប្រយោជន៍ខាងក្រោមនេះ គឺគ្រូបង្រៀនត្រូវយកចិត្តទុកដាក់មានដូចជា៖

- ត្រូវផ្តល់នូវភាពច្បាស់លាស់ និងការណែនាំច្បាស់ៗដល់សិស្សនៅក្នុងថ្នាក់រៀន
- ត្រូវកំណត់សេចក្តីរំពឹងទុកឱ្យបានច្បាស់លាស់
- ត្រូវពង្រឹងភាពវិជ្ជមានគ្រប់ពេលវេលា
- ត្រូវចេះប្រើប្រាស់ពេលវេលា និងមានវិធានការលើវិន័យ ទៅតាមតម្រូវការជាក់ស្តែង
- ឱ្យសិស្សរៀន និងលេងជាមួយគ្នាដោយភាពសប្បាយរីករាយក្នុងបរិយាកាសថ្នាក់រៀនល្អ
- នៅក្នុងថ្នាក់រៀនត្រូវរៀបចំឱ្យមានភាពទាក់ទាញ និងមានសម្ភារៈសម្រាប់លេង និងរៀនសម្បូរបែប
- ប្រើប្រាស់កម្មវិធីសិក្សារបស់កុំព្យូទ័រដើម្បីទាញចំណាប់អារម្មណ៍ពីសិស្ស
- កំណត់តុរៀនជារាងសៀគ្វី ដើម្បីឱ្យសិស្សអាចអង្គុយជុំវិញ
- បិទកាលវិភាគសកម្មភាពរបស់សិស្សដែលត្រូវធ្វើនៅក្នុងថ្នាក់រៀន ដើម្បីបង្រៀនដល់សិស្សឱ្យចេះបង្កើតទម្លាប់ប្រចាំថ្ងៃ
- បង្រៀនជំនាញសង្គមដូចជាការលើកដៃហ៊ានសួរ ហ៊ានឆ្លើយ និងដាក់វេនគ្នាម្នាក់ម្តងៗ
- ផ្តល់ឱកាសឱ្យសិស្សបានសម្រាកចេញលេង ដែលពួកគេអាចអានរឿង លេងល្បែងសប្បាយរួមគ្នា និងជជែកគ្នាលេង
- ថ្នាក់រៀនត្រូវមានពន្លឺគ្រប់គ្រាន់ ប៉ុន្តែចៀសវាងកុំឱ្យមានពន្លឺចាំងលើក្តារខៀនដែលរំខានដល់ការមើលរបស់សិស្ស និងគ្មានសំឡេងរំខានពីខាងក្រៅ
- ថ្នាក់រៀនត្រូវរៀបចំឱ្យបានស្អាត និងមានអនាម័យស្អាតជានិច្ច
- ពេលធ្វើកិច្ចការជាក្រុម ប្រសិនបើកន្លែងអង្គុយមិនអាចផ្លាស់ប្តូរបាន គ្រូគ្រាន់តែឱ្យសិស្សដែលអង្គុយតុមុខ បែរមករកសិស្សដែលអង្គុយតុក្រោយបន្ទាប់
- ការរៀនសូត្រនៅក្រៅថ្នាក់ក៏មានលក្ខណៈប្រសើរផងដែរ ព្រោះសិស្សបានឃើញជាក់ស្តែង ឧទាហរណ៍ នៅពេលបង្រៀនពីដើមឈើ គ្រូអាចនាំសិស្សទៅមើល និងស្ទាបដើមឈើ ជាដើម
- ប្រសិនបើអាចធ្វើទៅបាន គួរយកវត្ថុពិតៗមកបង្ហាញ និងឱ្យកុមារកាន់ ឬប៉ះស្ទាបដើម្បីជួយដល់កុមារដែលពិបាកក្នុងការមើល និងពិបាកក្នុងការរៀនសូត្រ
- គ្រូគប្បីឱ្យសិស្សធ្វើសកម្មភាព (ជាបុគ្គល ជាដៃគូ ឬជាក្រុម) ឱ្យបានច្រើនជាជាងឱ្យសិស្សអង្គុយស្តាប់ ឬមើលដែលនាំឱ្យគាត់ធុញទ្រាន់ក្នុងការសិក្សា
- គ្រប់សកម្មភាពសិក្សាត្រូវអមដោយសំណួរ និងសម្ភារៈឧបទេសគ្រប់គ្រាន់ ដើម្បីឈានទៅសម្រេចជោគជ័យក្នុងការពិភាក្សា និងដំណោះស្រាយបញ្ហា។

# មេរៀនទី៨៖ កម្មវិធីសិក្សាសិស្សមានពិការភាព

## ទស្សនៈ

ក្នុងមេរៀននេះប្រាប់ពីរបាយមុខវិជ្ជា និងម៉ោងសិក្សា នៅវិទ្យាល័យអប់រំពិសេស និងបង្ហាញពីគំរូលើភាពបត់បែននៃកម្មវិធីសិក្សាឱ្យបានសមស្រប ដើម្បីឆ្លើយតបតាមតម្រូវការជាក់ស្តែងរបស់សិស្ស។

## ខ្លឹមសារ

ការអប់រំនៅកម្រិតបឋមសិក្សាមានគោលបំណងបណ្តុះបណ្តាលបុគ្គលិកលក្ខណៈល្អប្រពៃ និងលើកកម្ពស់សមត្ថភាពទាំងផ្លូវកាយ ផ្លូវចិត្ត និងប្រាជ្ញាគ្រប់សិស្សទាំងអស់ ដើម្បីធានាឱ្យពួកគេទទួល និងអាចប្រើប្រាស់ចំណេះដឹងបំណិនមូលដ្ឋានដំបូងចាំបាច់ រួមមាន ការពង្រឹងនូវសេចក្តីស្រឡាញ់លើការរៀនសូត្រ ដែលពួកគេអាចនឹងបន្តការសិក្សានៅថ្នាក់បន្ទាប់។ ម៉្យាងវិញទៀត គ្រូបង្រៀនត្រូវជំរុញឱ្យសិស្សមានការរីកចម្រើនលើសេរីភាពខាងគំនិត និងការអភិវឌ្ឍព្រមៗគ្នាខាងទេពកោសល្យ ឥរិយាបថ តម្លៃ ការច្នៃប្រឌិត សីលធម៌សង្គម និងសិល្បៈសោភ័ណ។ ទន្ទឹមនឹងនេះ គ្រូបង្រៀនត្រូវតែជំរុញឱ្យមានកិច្ចសហការយ៉ាងជិតស្និទ្ធ រវាងគ្រូ និងសិស្ស រវាងសាលារៀន គ្រួសារ និងសហគមន៍ផងដែរ។ ជាក់ស្តែង ផ្អែកលើកម្មវិធីសិក្សា តម្រូវឱ្យសិស្សអាចប្រើប្រាស់ភាសាខ្មែរបានត្រឹមត្រូវ មានបំណិនមូលដ្ឋានខាងគណិតវិទ្យា និងមានសញ្ញាណដំបូងនៃជីវភាសា។ បន្ទាប់មកទៀត សិស្សក៏ត្រូវ ចេះអនុវត្តអនាម័យថែទាំសុខភាពឱ្យបានល្អ ចេះវិភាគរកហេតុផល មានទំនុកចិត្តលើខ្លួនឯង និងចូលចិត្តរៀនសូត្រជាប្រចាំ។

ក្នុងនោះគ្រូបង្រៀនក៏ត្រូវយល់ដឹងអំពីគោលការណ៍អប់រំទៅតាមកម្រិតការសិក្សារបស់សិស្ស ធ្វើយ៉ាងណាជំរុញសិស្សឱ្យចេះភាសាខ្មែរឱ្យបានត្រឹមត្រូវ មានលក្ខណៈបត់បែនក្នុងសកម្មភាពបង្រៀន និងរៀនស្របតាមបរិស្ថានសិក្សាកុមារមេត្រី ផ្តល់ឱកាសឱ្យសិស្សសម្តែងមតិយោបល់ ចំណាប់អារម្មណ៍ បំណិនជីវិត និងគំនិតច្នៃប្រឌិត ផងដែរ។ គ្រូបង្រៀនក៏ត្រូវពង្រីក និងពង្រឹងបទពិសោធ និងចំណេះដឹងដើម្បីឱ្យ សិស្សបានយល់អំពីគោលបំណងនៃភាសា និងការប្រើប្រាស់ភាសា ដើម្បីទាក់ទងតាមរយៈរបៀបផ្សេងៗ ម៉្យាងទៀតសិស្សត្រូវប្រើភាសាជាឧបករណ៍ ឬជាយានសម្រាប់ឱ្យសិស្សអាចសិក្សាមុខវិជ្ជាដទៃទៀត។ ក្នុងការស្តាប់ និងការនិយាយ គ្រូត្រូវបង្រៀនសិស្សឱ្យដឹងពីរបៀបនៃការនិយាយ នៅក្នុងស្ថានភាពនានាក្នុងសង្គម ហើយសិស្សអាចអភិវឌ្ឍបំណិនស្តាប់ និងនិយាយដោយយកចិត្តទុកដាក់ និងបានច្បាស់លាស់ ប្រកបដោយទំនុកចិត្ត និងសេចក្តីក្លាហាន។ ក្នុងអំណាន និងសំណេរ សិស្សអាចអភិវឌ្ឍការយល់ដឹងអំពីគោលបំណងផ្សេងៗនៃភាសាក្នុងសំណេរ ដើម្បីឱ្យសិស្សអាចរៀនអានអត្ថបទងាយៗ និងអត្ថបទដែលអាចស្មានបាននូវការវិវត្តនៃដំណើររឿងនៅក្នុងខ្លឹមសារដែលធ្លាប់ដឹង។ សិស្សក៏អាចភ្ជាប់ពាក្យសំណេរ និងពាក្យក្នុងការនិយាយបាននៅពេលអានអត្ថបទងាយៗ ដោយឱ្យសិស្សរៀនជ្រើសរើសអត្ថបទសម្រាប់អានដោយខ្លួនឯងផ្តើមចេញពីអត្ថបទខ្លីៗដែលធ្លាប់ដឹង។

តាមរយៈការបង្រៀនសំណេរ និងអំណាន គ្រូត្រូវណែនាំសិស្សក្នុងការហាត់ធ្វើចលនាដៃ ហាត់កាន់វត្ថុផ្សេងៗ ចាប់កាន់ខ្មៅដៃ ឬស្តែឡាស់ សរសេរតាមរបៀបត្រឹមត្រូវ ដូចជា ហាត់សរសេរអក្សរផ្ចង់ និងសរសេរតាមអាន ដើម្បីឱ្យសិស្សអាចតាក់តែង និងកត់ត្រាអត្ថបទងាយៗស្តីពីអ្វីៗដែលគេធ្លាប់ឃើញ។ នៅពេលផ្គុំពាក្យ គ្រូត្រូវបង្រៀនសិស្សឱ្យចេះសរសេរអក្សរឱ្យត្រូវតាមអក្ខរក្រម អក្ខរាវិរុទ្ធ និងក្បួនខ្នាតវេយ្យាករណ៍ និងទំនាក់ទំនងនៃស្វរសំឡេង សញ្ញា ក្រុមនៃតួអក្សរ និងការប្រើប្រាស់សញ្ញាសម្ព័ន្ធងាយៗមួយចំនួន ដើម្បីបញ្ជាក់ន័យសេចក្តី។

| សមត្ថភាពសំខាន់ៗទាំងបួន | | កំណត់សម្គាល់ |
|---|---|---|
| **ការស្ដាប់** | សមត្ថភាពស្ដាប់ | - ដាក់ស្ដែងគ្រូឱ្យសិស្សគថ្លង់ អាន មើលវីដេអូ និងមើលរូបភាព |
| **ការនិយាយ** | សមត្ថភាពនិយាយ | - សម្រាប់សិស្សគថ្លង់ប្រើភាសាសញ្ញាជំនួសឱ្យការនិយាយ |
| **អំណាន** | សមត្ថភាពអាន | - សម្រាប់សិស្សគថ្លង់ប្រើភាសាសញ្ញា និងមើលជំនួសឱ្យការអាន<br>- សម្រាប់សិស្សពិការភ្នែកប្រើប្រាស់ការស្ទាបដើម្បីអាន |
| **សំណេរ** | សមត្ថភាពសរសេរ | - សិស្សគថ្លង់គឺអាចសរសេរជាអក្សរបាន |

ដើម្បីឱ្យការបង្រៀន និងរៀននៅវិទ្យាល័យអប់រំពិសេសទទួលបានការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា លើវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា និងគុណសម្បទាពេញលេញ តម្រូវឱ្យការរៀនសូត្ររបស់សិស្សដែលមានពិការភាពរៀនទាន់កម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំជារបាយម៉ោងកំណត់ច្បាស់លាស់លើមុខវិជ្ជាសម្រាប់ការបង្រៀន និងរៀនដូចខាងក្រោម៖

### ៨.១ កម្មវិធីសិក្សាសិស្សពិបាកក្នុងការមើល

*របាយមុខវិជ្ជា និងម៉ោងសិក្សា ផ្នែកពិការភ្នែក*

| ល.រ | មុខវិជ្ជា | ថ្នាក់ទី | | | | | |
|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១ | ភាសាខ្មែរ | ១៧ | ១៩ | ៩ | ៩ | ៩ | ៩ |
| ២ | គណិតវិទ្យា | ៩ | ១១ | ៦ | ៦ | ៦ | ៦ |
| ៣ | វិទ្យាសាស្ត្រ | ៤ | ៤ | ២ | ២ | ២ | ២ |
| ៤ | កុំព្យូទ័រ | ១ | ១ | ១ | ២ | ២ | ២ |
| ៥ | សិក្សាសង្គម | ៤ | ៤ | ២ | ២ | ២ | ២ |
| ៦ | អប់រំសិល្បៈ/ភ្លេង | ១ | ១ | ១ | ១ | ១ | ១ |
| ៧ | អប់រំកាយ និងកីឡា | ២ | ២ | ១ | ១ | ១ | ១ |
| ៨ | ភាសាបរទេស | ២ | ២ | ២ | ២ | ២ | ២ |
| ៩ | បំណិនជីវិតតាមមូលដ្ឋាន | ០ | ០ | ០ | ០ | ០ | ០ |
| ១០ | តម្រង់ទិស | ២ | ០ | ០ | ០ | ០ | ០ |
| ១១ | ស្លេត/ស្ដៃយ៍ឡាស់ | ២ | ០ | ០ | ០ | ០ | ០ |
| ១២ | បណ្ណាល័យ | ១ | ១ | ១ | ០ | ០ | ០ |
| **សរុបម៉ោងប្រចាំសប្ដាហ៍** | | **៤៥** | **៤៥** | **២៥** | **២៥** | **២៥** | **២៥** |

- ✓ *សិស្សចាប់ពីថ្នាក់ទី១ ដល់ទី២ ត្រូវរៀនពេញ១ថ្ងៃ នៅវិទ្យាល័យអប់រំពិសេស ចំណែកឯសិស្សចាប់ពីថ្នាក់ទី៣ ដល់ទី៦ តម្រូវឱ្យរៀន ១ពេលនៅវិទ្យាល័យអប់រំពិសេសផ្ទាល់ និង ១ពេលទៀតរៀននៅថ្នាក់អប់រំបរិយាបន្ន។*
- ✓ *១សប្តាហ៍មាន៥ថ្ងៃ ក្នុង១ថ្ងៃមាន៩ម៉ោង ហើយក្នុង១ម៉ោងមានរយៈពេល៤០នាទី។*

## ៨.២ កម្មវិធីសិក្សាសិស្សពិបាកក្នុងការស្តាប់

*របាយមុខវិជ្ជា និងម៉ោងសិក្សា ផ្នែកគថ្លង់*

| ល.រ | មុខវិជ្ជា | ថ្នាក់ទី | | | | | |
|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១ | ភាសាខ្មែរ | ២០ | ១៨ | ១៨ | ១៨ | ៨ | ៨ |
| ២ | គណិតវិទ្យា | ១២ | ១២ | ១២ | ១២ | ៥ | ៥ |
| ៣ | វិទ្យាសាស្ត្រ | ៣ | ៤ | ៤ | ៤ | ៣ | ៣ |
| ៤ | កុំព្យូទ័រ | ០ | ០ | ១ | ១ | ១ | ១ |
| ៥ | សិក្សាសង្គម | ៣ | ៤ | ៤ | ៤ | ៣ | ៣ |
| ៦ | អប់រំសិល្បៈ | ១ | ១ | ១ | ១ | ១ | ១ |
| ៧ | អប់រំកាយ និងកីឡា | ១ | ១ | ១ | ១ | ១ | ១ |
| ៨ | ភាសាបរទេស | ០ | ០ | ១ | ១ | ២ | ២ |
| ៩ | បំណិនជីវិតតាមមូលដ្ឋាន | ០ | ០ | ០ | ០ | ១ | ១ |
| ១០ | សញ្ញា | ២ | ២ | ០ | ០ | ០ | ០ |
| ១១ | ស្តាប់/និយាយ | ២ | ២ | ២ | ២ | ០ | ០ |
| ១២ | បណ្ណាល័យ | ១ | ១ | ១ | ១ | ០ | ០ |
| សរុបម៉ោងប្រចាំសប្តាហ៍ | | ៤៥ | ៤៥ | ៤៥ | ៤៥ | ២៥ | ២៥ |

- ✓ *សិស្សចាប់ពីថ្នាក់ទី១ ដល់ទី៤ ត្រូវរៀនពេញ១ថ្ងៃ នៅវិទ្យាល័យអប់រំពិសេស ចំណែកឯសិស្សចាប់ពីថ្នាក់ទី៥ ដល់ទី៦ តម្រូវឱ្យរៀន ១ពេលនៅវិទ្យាល័យអប់រំពិសេសផ្ទាល់ និង១ពេលទៀតរៀននៅថ្នាក់អប់រំបរិយាបន្ន។*
- ✓ *១សប្តាហ៍មាន៥ថ្ងៃ ក្នុង១ថ្ងៃមាន៩ម៉ោង ហើយក្នុង១ម៉ោងមានរយៈពេល៤០នាទី។*

## ៨.៣ កម្មវិធីសិក្សាសិស្សពិការសតិបញ្ញា និងអូទីស្សឹម

*របាយមុខវិជ្ជា និងម៉ោងសិក្សា ផ្នែកសតិបញ្ញា និងអូទីស្សឹម*

| ល.រ | មុខវិជ្ជា | ថ្នាក់ទី | | | | | |
|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១ | ភាសាខ្មែរ | ៦ | ៦ | ៦ | ៨ | ៨ | ៨ |
| ២ | គណិតវិទ្យា | ៦ | ៦ | ៦ | ៨ | ៨ | ៨ |
| ៣ | វិទ្យាសាស្ត្រ | ៥ | ៥ | ៥ | ៥ | ៥ | ២ |
| ៤ | កុំព្យូទ័រ | ១ | ១ | ១ | ១ | ១ | ១ |
| ៥ | សិក្សាសង្គម | ៥ | ៥ | ៥ | ៥ | ៥ | ៤ |
| ៦ | អប់រំសិល្បៈ/ភ្លេង | ១ | ១ | ១ | ១ | ១ | ១ |
| ៧ | អប់រំកាយ និងកីឡា | ២ | ២ | ២ | ១ | ១ | ១ |
| ៨ | អប់រំសុខភាព | ១ | ១ | ១ | ១ | ១ | ០ |
| ៩ | បំណិនជីវិតតាមមូលដ្ឋាន | ២ | ២ | ២ | ៣ | ៣ | ៤ |
| ១០ | ហ្វឹកហាត់និយាយ | ៥ | ៥ | ៥ | ៣ | ៣ | ៣ |
| ១១ | គ្រប់គ្រងអាកប្បកិរិយា | ៥ | ៥ | ៥ | ២ | ២ | ២ |
| ១២ | តម្រង់ទិសវិជ្ជាជីវៈ | ០ | ០ | ០ | ១ | ១ | ៥ |
| ១៣ | បណ្ណាល័យ | ១ | ១ | ១ | ១ | ១ | ១ |
| **សរុបម៉ោងប្រចាំសប្តាហ៍** | | ៤០ | ៤០ | ៤០ | ៤០ | ៤០ | ៤០ |

*១សប្តាហ៍មាន៥ថ្ងៃ ក្នុង១ថ្ងៃមាន៨ម៉ោង ហើយក្នុង១ម៉ោងមានរយៈពេល៤០នាទី*

## ៨.៤ ឧទាហរណ៍កម្មវិធីសិក្សាលម្អិតភាសាខ្មែរ ថ្នាក់ទី១

មានកត្តាជាច្រើនដែលគ្រូបង្រៀនត្រូវពិចារណាក្នុងការសម្របសម្រួលលើកម្មវិធីសិក្សាឱ្យបានសមស្រប ដោយផ្អែកតាមឯកសារណែនាំប្រតិបត្តិកម្មវិធីសិក្សាអប់រំពិសេសក្នុងន័យជួយបំពេញនូវតម្រូវការរៀនសូត្រជាពិសេសឱ្យឆ្លើយតបទៅនឹងប្រភេទពិការភាពផ្សេងៗគ្នារបស់សិស្ស (ពិការភ្នែក គថ្លង់ និងពិការសតិបញ្ញា និងអូទីស្សឹម)។ ដើម្បីអនុវត្តកម្មវិធីសិក្សាឱ្យមានប្រសិទ្ធភាពគ្រូត្រូវដឹងពីខ្លឹមសារទាំងមូលរបស់កម្មវិធី ខ្លឹមសារគន្លឹះសំខាន់ៗ វិធីសាស្ត្រ ម៉ោងសិក្សា សម្ភារៈឧបទេស ការវាយតម្លៃ និងតម្រូវការពិសេសជាក់ស្តែងរបស់សិស្សមានពិការភាព ផ្សារភ្ជាប់ទៅនឹងភាពច្នៃប្រឌិតលើការអនុវត្តម៉ោងសិក្សាឱ្យមានភាពបត់បែន និងត្រឹមត្រូវច្បាស់លាស់ ទើបការបង្រៀនប្រកបដោយប្រសិទ្ធភាព។

ខាងក្រោមនេះ ជាឧទាហរណ៍ពាក់ព័ន្ធនឹងកម្មវិធីបង្រៀនដើម្បីបំពេញទៅតាមតម្រូវការជាក់ស្តែងរបស់សិស្សមានពិការភាព៖

| មុខវិជ្ជា៖ ភាសាខ្មែរ ថ្នាក់ទី១៖ | | |
|---|---|---|
| **ចំនួនម៉ោង** | **ប្រចាំសប្ដាហ៍** | **ប្រចាំឆ្នាំ** |
| ពិការភ្នែក | ១៧ ម៉ោង | ៥៩៥ ម៉ោង |
| គថ្លង់ | ២០ ម៉ោង | ៧០០ ម៉ោង |
| ពិការសតិបញ្ញា និងអូទីស្សឹម | ៦ ម៉ោង | ២១០ ម៉ោង |

*កម្មវិធីសិក្សាត្រូវកំណត់មួយឆ្នាំសិក្សាមាន ៣៥ សប្ដាហ៍*

## ខ្លឹមសារមេរៀន

| សិស្សមិនមានពិការភាព (ម៉ោងសរុបប្រចាំឆ្នាំ ៤៩៤ ម៉ោង) | សិស្សពិការភ្នែក (ម៉ោងសរុបប្រចាំឆ្នាំ ៥៩៥ ម៉ោង) | សិស្សគថ្លង់ (ម៉ោងសរុបប្រចាំឆ្នាំ ៧០០ម៉ោង) | សិស្សពិការសតិបញ្ញា និងអូទីស្សឹម (ម៉ោងសរុបប្រចាំឆ្នាំ ២១០ ម៉ោង) |
|---|---|---|---|
| មេរៀនទី១៖ រៀនគូសបន្ទាត់ និងខ្សែកោង | • ឱ្យស្គាល់ដូមីណូ (មានប្រាំមួយចំណុច) តាមរយៈការប្រើប្រាស់ ឧបករណ៍ស្លេត និងស្ដែយ៍ឡាស់ | • ចេះប្រើចលនាដៃបានត្រឹមត្រូវក្នុងការប្រើប្រាស់សម្ភារៈសរសេរនានាដើម្បីចម្លង និងគូសរូបភាព<br>• ចេះគូសបន្ទាត់តាមទិសដៅនីមួយៗ ដោយនិយាយបណ្ដោយគូសបណ្ដោយ<br>• ចេះប្រើចលនាដៃគូសខ្សែកោងពីឆ្វេងទៅស្ដាំ ពីលើចុះក្រោម ឬឡើងចុះ | • មិនទាន់ប្រើប្រាស់ឯកសារគោលរបស់ក្រសួងអប់រំ យុវជន និងកីឡានៅឡើយ<br>• សម្ភារៈផលិតផ្ទាល់និងទិញ ដូចជា ខ្មៅដៃ ប៊ិក ហ្វឺត<br>• ប្រើប្រាស់កាលវិភាគសកម្មភាព៖ ការផ្ទង់អារម្មណ៍ ការប្រើភាសា និងការបញ្ចេញសំឡេង និងពាក្យ<br>• ភាសាខ្មែរ៖ បង្រៀនសិស្សឱ្យចេះសរសេរព្យញ្ជនៈ និងស្រៈ<br>• រូបភាពជំនួយសម្រាប់ចំណាំ |
| មេរៀនទី២៖ ចម្រៀងស្រៈ (លំនាំបទសត្វទីទុយ) | • ឱ្យស្គាល់ពីចំណុចតួអក្សរនីមួយៗ<br>• ហាត់ច្រៀងចម្រៀងស្រៈនិស្ស័យ | • ឱ្យសិស្សស្គាល់ទីតាំងនៃសញ្ញា<br>• គ្រាន់តែរំឭកឡើងវិញតាមស្ថានភាពសិស្ស និងឱ្យសិស្សស្គាល់ទីតាំងនៃសញ្ញា | |

| | | | |
|---|---|---|---|
| | | • រំឭកមេរៀនទី១ ឡើងវិញ | • គ្រូបង្រៀនសិស្សត្រូវផ្តោតលើ៖<br>១. ទំនាក់ទំនងភាសា<br>២. ការយល់ដឹង<br>៣. ជំនាញសង្គម<br>៤. ចលនានៃរូបរាងកាយ និងញាណ<br>៥. សកម្មភាពរស់នៅប្រចាំថ្ងៃ |
| មេរៀនទី៣៖ ស្រៈនិស្ស័យចម្រៀងអក្ខរក្រម៤វគ្គ (លំនាំបទតាចាស់ចង់បានប្រពន្ធក្មេង) | • ប្រើប្រាស់ឧបករណ៍ស្លេត និងស្លេយ៍ឡាស់<br>• ស្គាល់ចំណុចស្រៈនិស្ស័យ | • អាច និងសរសេរស្រៈនិស្ស័យបានបន្តិចបន្តួច | |
| មេរៀនទី៤៖ ព្យញ្ជនៈ ៣៣តួ | • ឱ្យសិស្សស្គាល់ពីចំណុចតួអក្សរទាំង៣៣តួ<br>• សិស្សរៀនច្រៀងចម្រៀងអក្ខរក្រម ៤វគ្គ | • សិស្សស្គាល់តួព្យញ្ជនៈ៣៣តួ ដោយប្រើសញ្ញា និងរូបរាង<br>• សិស្សពុំអាចច្រៀងបានប៉ុន្តែសិស្សដឹងក្រុមព្យញ្ជនៈនៃអក្ខរក្រម៤វគ្គ | |
| មេរៀនទី៥៖ ព្យញ្ជនៈ ក ផ្សំស្រៈ | • ឱ្យសិស្សស្គាល់ពីចំណុចនៃ ព្យញ្ជនៈ ក ខ ច ឆ ផ្សំស្រៈ<br>• ឱ្យសិស្សរៀនប្រកប និងញែកសូរស្រៈ និងព្យញ្ជនៈ<br>• ឱ្យសិស្សរៀនប្រកប អាន និងសរសេរជាព្យាង្គ ពាក្យ និងឈ្មោះនៃសូរពួក "អ"<br>• ឱ្យសិស្សចេះរំលង និងដកឃ្លា ចន្លោះនៃបន្ទប់ចំណុចអក្សរប្រៃយ៍ (ឧទាហរណ៍ អក្សរ "ក" មានចំណុច ១២៣៤ ដូច្នេះសិស្ស | • សិស្សចេះពីរបៀបសរសេរព្យញ្ជនៈ និងស្រៈតាមលំដាប់លំដោយនៃចលនានីមួយៗ<br>• សិស្សចេះសញ្ញាពាក្យដែលមានព្យញ្ជនៈពួក អ ផ្សំ ស្រៈតាមរយៈ បណ្ណពាក្យ រូបភាព និងអក្ខរវិទ្យាបានដែលមានព្យញ្ជនៈផ្សំស្រៈ<br>• ចេះកំណត់បានរូបរាង និងទំហំតួអក្សរដែលត្រូវសរសេរ<br>• មានទម្លាប់សរសេរអក្សរតាមទម្រង់អក្សរ | |
| មេរៀនទី៦៖ ព្យញ្ជនៈ ខ ផ្សំស្រៈ | | | |
| មេរៀនទី៧៖ ព្យញ្ជនៈ ច ផ្សំស្រៈ | | | |
| មេរៀនទី៨៖ ព្យញ្ជនៈ ឆ ផ្សំស្រៈ<br>រៀនសារឡើងវិញ៖<br>ក ខ ច ឆ<br>អក្សរផ្ទង់អំពីព្យញ្ជនៈ "ក" | | | |

| | | | |
|---|---|---|---|
| | ត្រូវរំលង ១ ឬ២ បន្ទប់ ) | ផ្ទង់ដោយផ្ចិតផ្ចង់ បានស្អាត និង ត្រឹមត្រូវ | |
| មេរៀនទី៩៖ ព្យញ្ជនៈ ដ ផ្សំស្រៈ<br>មេរៀនទី១០៖ ព្យញ្ជនៈ ឋ ផ្សំស្រៈ<br>មេរៀនទី១១៖ ព្យញ្ជនៈ ណ ផ្សំស្រៈ រៀនសារឡើងវិញ៖ ដ ឋ ណ អក្សរផ្ចង់អំពីព្យញ្ជនៈ "ដ" | • ឱ្យសិស្សស្គាល់ពី ចំណុចនៃ ព្យញ្ជនៈ ដ ឋ ណ ផ្សំស្រៈ<br>• ឱ្យសិស្សរៀនប្រកប និងញែកសូរស្រៈ និង ព្យញ្ជនៈ<br>• ឱ្យសិស្សរៀនប្រកប អាន និងសរសេរជា ព្យាង្គ ពាក្យ និងល្បះ នៃសូរពួក "អ"<br>• ឱ្យសិស្សចេះរំលង និង ដកឃ្លា ចន្លោះនៃ បន្ទប់ចំណុចអក្សរ ប្រៃយ៍ (ឧទាហរណ៍ អក្សរ "ដ" មានចំណុច ១៤៥ ដូច្នេះសិស្សត្រូវ រំលង ១បន្ទប់ ឬ២ បន្ទប់ ) | • សិស្សចេះពីរបៀប សរសេរព្យញ្ជនៈ និង ស្រៈតាមលំដាប់ លំដោយនៃចលនា នីមួយៗ<br>• សិស្សចេះសញ្ញាពាក្យ ដែលមានព្យញ្ជនៈ ពួក អ ផ្សំស្រៈតាម រយៈបណ្ណពាក្យរូបភាព និងអក្ខរវិទ្យាបាន ដែលមានព្យញ្ជនៈផ្សំ ស្រៈបានត្រឹមត្រូវ<br>• ចេះកំណត់បានរូប រាង និងទំហំតួអក្សរ ដែលត្រូវសរសេរ<br>• មានទម្លាប់សរសេរ អក្សរតាមទម្រង់អក្សរ ផ្ចង់ដោយផ្ចិតផ្ចង់ ស្អាត និងត្រឹមត្រូវ | |
| មេរៀនទី១២៖ ព្យញ្ជនៈ ត ថ ផ្សំស្រៈ<br>មេរៀនទី១៣៖ ព្យញ្ជនៈ ប ផ ផ្សំស្រៈ រៀនសាឡើងវិញ៖ ត ថ ប ផ<br>មេរៀនទី១៤៖ ព្យញ្ជនៈ ស ហ ផ្សំស្រៈ | • ឱ្យសិស្សស្គាល់ពី ចំណុចនៃព្យញ្ជនៈ ត ថ ប ផ ស ហ ឡ អ ផ្សំស្រៈ<br>• ឱ្យសិស្សរៀនប្រកប និងញែកសូរស្រៈ និង ព្យញ្ជនៈ | • ចេះសរសេរអក្សរនៃ អក្ខរក្រម<br>• ចេះសញ្ញាតួអក្សរ និងពាក្យបានតាមរយៈ បណ្ណរូបភាព បណ្ណពាក្យ និងវត្ថុ ជាក់ស្តែងបាន ត្រឹមត្រូវ | |

| | | | |
|---|---|---|---|
| មេរៀនទី១៥៖<br>ព្យញ្ជនៈឡ អ ផ្សំស្រៈ<br>រៀនសាឡើងវិញ៖ ក ខ ច ឆ ជ ឋ ណ ត ថ ប ផ ស ហ ឡ អ | • ឱ្យសិស្សរៀនប្រកប អាន និងសរសេរជា ព្យាង្គ ពាក្យ និងល្បះ នៃសូរពួក "អ" | | |
| មេរៀនទី១៦៖<br>ព្យញ្ជនៈ គ ផ្សំស្រៈ និស្ស័យទាំង២៣តួ | • ឱ្យសិស្សស្គាល់ចំណុច<br>• ឱ្យសិស្សស្គាល់សូរពួក "អ៊"<br>• ឱ្យសិស្សស្គាល់ការផ្សំស្រៈជាមួយពួក "អ៊" ដោយប្តូរសំឡេងស្រៈ លើកលែងតែស្រៈ ូ ឿ ៀ និង េ ដែលមិនប្តូរសូរ<br>• ឱ្យសិស្សចេះអាន ប្រកប សរសេរ ព្យាង្គ ពាក្យ និងល្បះ នៃសូរពួក "អ៊" | • ស្គាល់ក្រុមពួកអ៊ និង ពួក អ និងអាចធ្វើ សញ្ញា និងសរសេរ ព្យញ្ជនៈផ្សំស្រៈបាន តាមរយៈបណ្ណរូបភាព បណ្ណពាក្យ វត្ថុ ជាក់ស្តែង និងអាចធ្វើ អក្ខរាវិរុទ្ធបានត្រឹមត្រូវ | |
| មេរៀនទី១៧៖<br>ព្យញ្ជនៈ ឃ ផ្សំស្រៈ និស្ស័យទាំង២៣តួ | | • សិស្សអាចស្គាល់ក្រុម ពួកអ៊ និងពួកអ និងអាច ធ្វើសញ្ញា និងសរសេរ ព្យញ្ជនៈផ្សំស្រៈបាន តាមរយៈបណ្ណរូបភាព បណ្ណពាក្យ និង វត្ថុជាក់ស្តែង<br>• សិស្សអាចធ្វើសញ្ញា និងអាចធ្វើអក្ខរាវិរុទ្ធ បានត្រឹមត្រូវ | |
| មេរៀនទី១៨៖<br>ព្យញ្ជនៈ ង ផ្សំស្រៈ និស្ស័យទាំង២៣តួ | | | |
| មេរៀនទី១៩៖<br>ព្យញ្ជនៈ ជ ផ្សំស្រៈ និស្ស័យទាំង២៣តួ | | | |
| មេរៀនទី២០៖<br>ព្យញ្ជនៈ ឈ ផ្សំស្រៈ និស្ស័យទាំង២៣តួ | | | |
| មេរៀនទី២១៖<br>ព្យញ្ជនៈ ញ ផ្សំស្រៈ និស្ស័យទាំង២៣តួ<br>រៀនសាឡើងវិញ៖<br>គ ឃ ង ជ ឈ ញ | | | |
| មេរៀនទី២២៖<br>ព្យញ្ជនៈ ឌ ផ្សំស្រៈ | | | |

| | | | |
|---|---|---|---|
| និស្ស័យទាំង២៣តួ | | | |
| មេរៀនទី២៣៖<br>ព្យញ្ជនៈ ឍ ផ្សំស្រៈ<br>និស្ស័យទាំង២៣តួ | | | |
| មេរៀនទី២៤៖<br>ព្យញ្ជនៈ ទ ធ អំណាន<br>និងសំណេរផ្សំស្រៈ<br>និស្ស័យទាំង២៣តួ<br>រៀនសាឡើងវិញ៖<br>ឌ ឍ ទ ធ | | | |
| មេរៀនទី២៥៖<br>ព្យញ្ជនៈ ន ព ផ្សំស្រៈ | • ឱ្យសិស្សស្គាល់ចំណុច<br>• ឱ្យសិស្សស្គាល់សូរពួក “អ៊”<br>• ឱ្យសិស្សស្គាល់ការផ្សំស្រៈជាមួយពួក “អ៊” ដោយប្តូរសំឡេងស្រៈ លើកលែងតែស្រៈ ូ ឿ ៀ និង េ ដែលមិនប្តូរសូរ<br>• ឱ្យសិស្សចេះអានប្រកប សរសេរ ព្យាង្គ ពាក្យ និងល្បះ នៃសូរពួក “អ៊”<br>• ឱ្យសិស្សប្រាប់ពីចំណុចនៃតួអក្សរ ព្យាង្គ ពាក្យ និងល្បះ<br>• រំឭកការប្រកប អាន និងសរសេរ ព្យាង្គ ពាក្យ និងល្បះ | • សិស្សអាចស្គាល់ក្រុមពួកអ៊ និងពួកអ និងអាចធ្វើសញ្ញាពាក្យ និងសរសេរបំពេញពាក្យក្រោមរូបភាពនីមួយៗបាន<br>• សិស្សអាចសរសេរពាក្យក្រោមរូបភាពបានត្រឹមត្រូវតាមរយៈបណ្ណពាក្យ រូបភាព និងវត្ថុជាក់ស្តែង | |
| មេរៀនទី២៦៖<br>ព្យញ្ជនៈ ភ ម ផ្សំស្រៈ<br>រៀនសាឡើងវិញ៖<br>ន ព ភ ម | | | |
| មេរៀនទី២៧៖<br>ព្យញ្ជនៈ យ រ ផ្សំស្រៈ | | | |
| មេរៀនទី២៨៖<br>ព្យញ្ជនៈ ល វ ផ្សំស្រៈ<br>រៀនសាឡើងវិញ៖ ព្យញ្ជនៈពួក អ៊<br>រៀនសាឡើងវិញ៖ ព្យញ្ជនៈពួក អ និងពួក អ៊<br>អក្សរផ្ទង់ “យ”<br>អក្សរផ្ទង់ “ទ” | | • សិស្សអាចស្គាល់ពីក្រុមពួកអ៊ និងពួកអ និងអាចធ្វើសញ្ញា និងសរសេរពាក្យបាន<br>• សិស្សអាចសរសេរពាក្យ និងសញ្ញាព្យញ្ជនៈ និងអាចធ្វើអក្ខរវិទ្យាបានត្រឹមត្រូវ | |

| | | | |
|---|---|---|---|
| | • ឱ្យសិស្សប្រាប់ពីចំណុចនៃតួអក្សរ ព្យាង្គ ពាក្យ និងឈ្មោះនៃស្វរពួក "អ" និង ពួក "អ៊"<br>• រំឭកការប្រកប អាន និងសរសេរ ព្យាង្គ ពាក្យ និងឈ្មោះនៃស្វរ ពួក "អ" និង ពួក "អ៊"<br>• ឱ្យសិស្សចេះរំលង និង ដកឃ្លា ចន្លោះនៃបន្ទប់ចំណុចអក្សរ ប្រៃយ៍ (ឧទាហរណ៍ អក្សរ "ឃ" មាន ចំណុច៦១៣៤៥៦ ដូច្នេះសិស្សត្រូវរំលង ១បន្ទប់ ឬ២បន្ទប់)<br>• ឱ្យសិស្សចេះរំលង និង ដកឃ្លាចន្លោះនៃបន្ទប់ចំណុចអក្សរប្រៃយ៍ (ឧទាហរណ៍ អក្សរ "ទ" មានចំណុច ៦២៣៤៥ ដូច្នេះ សិស្សត្រូវរំលង ១ បន្ទប់ ឬ២បន្ទប់) | • ស្គាល់ក្រុមព្យញ្ជនៈពួកអ និងពួកអ៊<br>• ចេះធ្វើសញ្ញា សរសេរ ពាក្យ និងចេះព្យញ្ជនៈ ៣៣តួ<br>• សិស្សអាចធ្វើសញ្ញា បានតាមអក្ខរក្រមនៃព្យញ្ជនៈបានត្រឹមត្រូវ<br>• សិស្សចេះកំណត់ បានរូបរាង និងទំហំតួ អក្សរនិងទីតាំង ចលនាដែលត្រូវ សរសេរ<br>• សិស្សមានទម្លាប់ សរសេរអក្សរតាម ទម្រង់អក្សរផ្ចង់ដោយ ផ្ចិតផ្ចង់បានស្អាត និង ត្រឹមត្រូវ<br>• ចេះកំណត់បានរូបរាង និងទំហំតួអក្សរ និងទីតាំងដែលត្រូវ សរសេរ<br>• មានទម្លាប់សរសេរ អក្សរតាមទម្រង់អក្សរ ផ្ចង់ដោយផ្ចិតផ្ចង់ បានស្អាត និង ត្រឹមត្រូវ | |

| | | | |
|---|---|---|---|
| មេរៀនទី២៩៖ បទចម្រៀង "សារិកាកែវអើយ" | • ឱ្យសិស្សរៀនទន្ទេញចម្រៀងម្តងមួយល្បះរហូតចាំស្ទាត់<br>• ឱ្យសិស្សរៀនធ្វើបទម្តងមួយល្បះៗ<br>• ឱ្យសិស្សរៀនច្រៀងរហូតដល់ចប់ | • សិស្សអាចធ្វើសញ្ញា និងស្គាល់សត្វតាមរយៈរូបភាព និងការពន្យល់របស់គ្រូ | |
| មេរៀនទី៣០៖ ង៉ ផ្សំស្រៈ<br>មេរៀនទី៣១៖ ញ៉ ផ្សំស្រៈ<br>មេរៀនទី៣២៖ ប៉ ផ្សំស្រៈ<br>មេរៀនទី៣៣៖ ម៉ ផ្សំស្រៈ<br>មេរៀនទី៣៤៖ យ៉ ផ្សំស្រៈ<br>មេរៀនទី៣៥៖ រ៉ ផ្សំស្រៈ<br>មេរៀនទី៣៦៖ វ៉ ផ្សំស្រៈ<br><br>រៀនសាឡើងវិញ ង៉ ញ៉ ប៉ ម៉ យ៉ រ៉ វ៉ | • ឱ្យសិស្សស្គាល់ពីចំណុចតួអក្សរ និងសញ្ញាធ្មេញកណ្តុរ (ចំណុច ៤)<br>• ប្រាប់ពីសញ្ញាធ្មេញកណ្តុរហៅថាសញ្ញាសម្លាប់ពីរប្តូរពីពួក "អ៊" ទៅសំឡេង "អ" លើកលែងតែអក្សរ "ប" សូរ "អ" ដដែល<br>• ឱ្យសិស្សរៀនប្រកបអាន និងសរសេរជាមួយនឹងតួអក្សរផ្សំនឹងសញ្ញាធ្មេញកណ្តុរ ឬមូសិកទន្ត<br>• ឱ្យសិស្សប្រាប់ពីចំណុចនៃតួអក្សរព្យាង្គ ពាក្យ និងល្បះផ្សំនឹងសញ្ញាធ្មេញកណ្តុរ ឬមូសិកទន្ត ពួក "អ៊" មកសូរពួក "អ" លើកលែងអក្សរ "ប" សូរ "អ" ដដែល<br>• រំឭកការប្រកប អាន និងសរសេរ ព្យាង្គ | • សិស្សចេះសញ្ញាពាក្យផ្សំជាមួយស្រៈនិងមូលសិកទន្ត ឬធ្មេញកណ្តុរ ( ៉ ) បានត្រឹមត្រូវ<br>• សិស្សអាចសរសេរ និងធ្វើអក្ខរវិរុទ្ធបានត្រឹមត្រូវ<br>• សិស្សចេះសញ្ញាពាក្យផ្សំជាមួយស្រៈនិងមូសិកទន្ត ឬធ្មេញកណ្តុរ ( ៉ )<br>• សិស្សអាចសរសេរ និងធ្វើអក្ខរវិរុទ្ធបានត្រឹមត្រូវ | |

| | | | |
|---|---|---|---|
| | ពាក្យ និងល្បះនៃសូរ ពួក "អ៊" និង ពួក "អ" | | |
| មេរៀនទី៣៧៖ ប៊ ផ្សំស្រៈ<br>មេរៀនទី៣៨៖ ស៊ ផ្សំស្រៈ<br>មេរៀនទី៣៩៖ ហ៊ ផ្សំស្រៈ<br>មេរៀនទី៤០៖ អ៊ ផ្សំស្រៈ រៀនសាឡើងវិញ ប៊ ស៊ ហ៊ អ៊ | • ឱ្យសិស្សស្គាល់ពីចំណុចតួអក្សរ និងសញ្ញាត្រីស័ព្ទ (ចំណុច ៣ ៦)<br>• ប្រាប់ពីសញ្ញាត្រីស័ព្ទប្តូរពីពួក "អ" ទៅសំឡេង "អ៊"<br>• ឱ្យសិស្សរៀនប្រកប អាន និងសរសេរជាមួយនឹងតួអក្សរផ្សំនឹងសញ្ញាត្រីស័ព្ទ<br>• ឱ្យសិស្សប្រាប់ពីចំណុចនៃតួអក្សរ ព្យាង្គ ពាក្យ និងល្បះផ្សំនឹងសញ្ញាត្រីស័ព្ទ ពួក "អ" មកសូរពួក "អ៊"<br>• រំឭកការប្រកប អាន និងសរសេរ ព្យាង្គ ពាក្យ និងល្បះនៃសូរ ពួក "អ" និង ពួក "អ៊" | • សិស្សអាចស្គាល់ត្រីស័ព្ទជាវណ្ណយុត្តសម្រាប់ប្រើលើព្យញ្ជនៈ៤តួ គឺ ប ស ហ អ<br>• សិស្សអាចធ្វើអក្ខរវិទ្យាបានត្រឹមត្រូវ<br>• សិស្សអាចសញ្ញានិងសរសេរព្យញ្ជនៈផ្សំស្រៈបានត្រឹមត្រូវ<br>• សិស្សប្រាប់បានពីសញ្ញាត្រីស័ព្ទ និង<br>• អាចបំពេញស្រៈ ឬវណ្ណយុត្តបានត្រឹមត្រូវ និងអាចធ្វើសញ្ញាពាក្យបាន | |
| មេរៀនទី៤១៖ ម៉ែឪមានគុណ | • ឱ្យសិស្សរៀនទន្ទេញចម្រៀងម្តងមួយល្បះ រហូតចាំស្ទាត់<br>• ឱ្យសិស្សរៀនធ្វើបទម្តងមួយល្បះៗ<br>• ឱ្យសិស្សរៀនច្រៀងរហូតដល់ចប់ | • សិស្សអាចធ្វើសញ្ញាបាន និងយល់ន័យបទចម្រៀងតាមរយៈគ្រូពន្យល់ | |

| | | | |
|---|---|---|---|
| មេរៀនទី៤២៖ ប្រកប នឹង ក ក់ | • ឱ្យសិស្សស្គាល់ចំណុច តួអក្សរ និងបន្តក់ (ចំណុច ៣ ៥)<br>• ឱ្យសិស្សស្គាល់សញ្ញាបន្តក់ដែលសង្កត់សូរព្យាង្គ (ឧទាហរណ៍ "ក" និង "ក់" ទៅជា "កក់")<br>• ឱ្យសិស្សរៀនប្រកប អាន និងសរសេរពាក្យ ព្យាង្គ និងល្បះ ផ្សំនឹងសញ្ញាបន្តក់ | • សិស្សអាចស្គាល់សញ្ញាបន្តក់( ់ ) សិស្សអាចសរសេរ និង សញ្ញាជាពាក្យដែលមានសញ្ញាបន្តក់បានត្រឹមត្រូវតាមរយៈ គ្រូបង្ហាញ អក្សរចល័ត រូបភាព និងបណ្ណពាក្យ<br>• សិស្សអាចធ្វើអក្ខរវិទ្យាបានត្រឹមត្រូវ | |
| មេរៀនទី៤៣៖ ប្រកប នឹង ក ក់ (ត) | | | |
| មេរៀនទី៤៤៖ ប្រកប នឹង ង ង់ | | | |
| មេរៀនទី៤៥៖ ប្រកប នឹង ង ង់ (ត) | | | |
| មេរៀនទី៤៦៖ ប្រកប នឹង ច ច់ | | | |
| មេរៀនទី៤៧៖ ប្រកប នឹង ច ច់ (ត)<br>➢ រៀនសាឡើងវិញ៖ ក ក់ ង ង់ | | | |
| មេរៀនទី៤៨៖ ប្រកប នឹង ញ ញ់ | | | |
| មេរៀនទី៤៩៖ ប្រកប នឹង ញ ញ់ (ត) | | | |
| មេរៀនទី៥០៖ ប្រកប នឹង ត ត់ | | | |
| មេរៀនទី៥១៖ ប្រកប នឹង ត ត់ (ត) | | | |
| មេរៀនទី៥២៖ ប្រកប នឹង ន ន់ | | • សិស្សអាចស្គាល់សញ្ញាបន្តក់ ( ់ ) សិស្សអាចសរសេរ និង ធ្វើសញ្ញាជាពាក្យដែលមានសញ្ញាបន្តក់បានត្រឹមត្រូវតាមរយៈ គ្រូបង្ហាញ<br>• អក្សរចល័ត រូបភាព និងបណ្ណពាក្យ | |
| មេរៀនទី៥៣៖ ប្រកប នឹង ន ន់ (ត) | | | |

| | | | |
|---|---|---|---|
| រៀនសាឡើងវិញ៖ ញ ញ់ ត ត់ ន ន់<br>មេរៀនទី៥៤៖ ប្រកប នឹង ប ប់<br>មេរៀនទី៥៥៖ ប្រកប នឹង ប ប់ (ត) | | • សិស្សអាចធ្វើអក្ខរវិទ្យាបាន | |
| មេរៀនទី៥៦៖ ប្រកប នឹង ម<br>មេរៀនទី៥៧៖ ប្រកប នឹង ម (ត)<br>មេរៀនទី៥៨៖ ប្រកប នឹង យ<br>មេរៀនទី៥៩៖ ប្រកប នឹង យ (ត)<br>រៀនសាឡើងវិញ៖ ប ប់ ម យ | • ឱ្យសិស្សស្គាល់ចំណុចនៃតួអក្សរ<br>• ឱ្យសិស្សប្រកប អាន និងសរសេរ ប្រកបជាមួយអក្សរ "ម" និង "យ" (ឧទាហរណ៍ ចោមពោម និងបាយ)<br>• ការប្រកបនឹងអក្សរ ម និង យ មិនអាចប្រើជាមួយសញ្ញាបន្តក់បានទេ | • សិស្សអាចរកពាក្យដែលបញ្ចប់ដោយព្យញ្ជនៈ ម និងយ បានត្រឹមត្រូវ និងអាចធ្វើសញ្ញាពាក្យ និងសរសេរបានតាមរយៈគ្រូបង្ហាញ អក្សរចល័ត បណ្ណពាក្យ និងរូបភាព | |
| មេរៀនទី៦០៖ ប្រកប នឹង ល ល់ | • ឱ្យសិស្សស្គាល់ចំណុចតួអក្សរ និងបន្តក់ (ចំណុច ៣ ៥)<br>• ឱ្យសិស្សស្គាល់សញ្ញាបន្តក់ដែលសង្កត់សូរព្យាង្គ<br>• ឱ្យសិស្សរៀនប្រកប អាន និងសរសេរពាក្យព្យាង្គ និងល្បះ ផ្សំនឹងសញ្ញាបន្តក់ ឧទាហរណ៍ កល ---> កល់ | • សិស្សអាចស្គាល់ព្យញ្ជនៈដែលនៅក្រុមពួក អ បាន<br>• សិស្សអាចសរសេរ និងធ្វើសញ្ញាពាក្យបានត្រឹមត្រូវនិងធ្វើអក្ខរវិទ្យាបាន | |

| | | | |
|---|---|---|---|
| មេរៀនទី៦១៖ ប្រកប នឹង ល ល់ | • សិស្សស្គាល់ចំណុចតួអក្សរ និងបន្តក់ (ចំណុច ៣ ៥)<br>• ឱ្យសិស្សស្គាល់សញ្ញាបន្តក់ដែលសង្កត់សូរព្យាង្គ<br>• ឱ្យសិស្សរៀនប្រកប អាន និងសរសេរពាក្យព្យាង្គ និងល្បះ ផ្សំនឹងសញ្ញាបន្តក់ ឧទាហរណ៍ គល -> គល់ | • សិស្សអាចស្គាល់ព្យញ្ជនៈដែលនៅក្រុមពួក អ បាន<br>• សិស្សអាចសរសេរ និងធ្វើសញ្ញាពាក្យបានត្រឹមត្រូវនិងធ្វើអក្ខរវិទ្យាបាន | |
| មេរៀនទី៦២៖ ប្រកប នឹង វ | • ឱ្យសិស្សស្គាល់ចំណុចតួអក្សរ<br>• ឱ្យសិស្សស្គាល់ពីការប្រកបសូរពួក “អ” ផ្សំនឹងអក្សរ “វ”<br>• ឱ្យសិស្សរៀនប្រកប អាន និងសរសេរពាក្យព្យាង្គ និងល្បះ ផ្សំនឹងអក្សរ “វ” ឧទាហរណ៍ កែវ | • សិស្សស្គាល់ព្យញ្ជនៈដែលនៅក្រុមពួក<br>• សិស្សអាចធ្វើអក្ខរវិទ្យាបានត្រឹមត្រូវ និងអាចសរសេរ សញ្ញាពាក្យនិងបង្កើតល្បះតាមរយៈគ្រូ បង្ហាញរូបភាព អក្សរចល័ត បណ្ណពាក្យ | |
| មេរៀនទី៦៣៖ ប្រកប នឹង ស ស់ | • ឱ្យសិស្សស្គាល់ចំណុចតួអក្សរ<br>• ឱ្យសិស្សស្គាល់ពីការប្រកបសូរពួក “អ” ផ្សំនឹងអក្សរ “ស”<br>• ឱ្យសិស្សរៀនប្រកប អាន និងសរសេរពាក្យព្យាង្គ និងល្បះ ផ្សំនឹង | | |

| | | | |
|---|---|---|---|
| | អក្សរ "ស"<br>ឧទាហរណ៍ ចាស | | |
| មេរៀនទី៦៤៖ ប្រកប នឹង ស ស់ (ត)<br>រៀនសាឡើងវិញ៖ ល ល់ វ ស ស់ | • សិស្សស្គាល់ចំណុចតួអក្សរ និងបន្តក់ (ចំណុច ៣ ៥)<br>• ឱ្យសិស្សស្គាល់សញ្ញាបន្តក់ដែលសង្កត់សូរព្យាង្គ<br>• ឱ្យសិស្សរៀនប្រកប អាន និងសរសេរពាក្យ ព្យាង្គ និងល្បះ ផ្សំនឹងសញ្ញាបន្តក់<br>ឧទាហរណ៍ រស់ | • សិស្សស្គាល់ព្យញ្ជនៈដែលនៅក្រុមពួក (អ៊ិ)<br>• សិស្សអាចធ្វើអត្ថវិទ្យាបានត្រឹមត្រូវនិងអាចសរសេរពាក្យ អាចធ្វើសញ្ញា និងបង្កើតល្បះតាមរយៈគ្រូ បង្ហាញ រូបភាព អក្សរចល័ត បណ្ណពាក្យ និងវត្ថុជាក់ស្តែង | |
| មេរៀនទី៦៥៖ ស្រៈពេញតួ អ អា ឥ ឦ ឧ ឩ ឪ | • ឱ្យសិស្សស្គាល់ចំណុចស្រៈពេញតួ<br>• ឱ្យសិស្សប្រកប អាន និងសរសេរ ផ្សំជាមួយស្រៈពេញតួ | • សិស្សចេះសញ្ញា សរសេរពាក្យ និងស្គាល់ស្រៈពេញតួបានត្រឹមត្រូវតាមរយៈបណ្ណពាក្យ រូបភាពដែលគ្រូបង្ហាញ | |
| មេរៀនទី៦៦៖ ស្រៈពេញតួ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ<br>➢ រៀនសាឡើងវិញ៖ អ អា ឥ ឦ ឧ ឩ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ ឳ | | • សិស្សចេះសញ្ញា និងសរសេរពាក្យដែលមានស្រៈពេញតួ ឫ ឬឭ ឮ ឯ ឰ ឱ ឳ ដែលមានបានត្រឹមត្រូវតាមរយៈបណ្ណពាក្យ រូបភាពតាមរយៈគ្រូ | |
| មេរៀនទី៦៧៖ ព្យញ្ជនៈ និងជើងព្យញ្ជនៈ | • ឱ្យសិស្សរៀនស្គាល់ពីចំណុចនៃសញ្ញាជើងព្យញ្ជនៈ<br>• ឱ្យសិស្សរៀនអាន | • សិស្សអាចសរសេរសញ្ញាព្យញ្ជនៈ និងជើងជើងព្យញ្ជនៈ | |

| | | | |
|---|---|---|---|
| | | បានត្រឹមត្រូវតាមរយៈអក្សរចល័ត ប័ណ្ណព្យញ្ជនៈ<br>• សិស្សដឹងពីជើងព្យញ្ជនៈ ញ គឺ ្ញ និង ញ<br>• ចំពោះជើងឡមិនមានជើងទេ<br>• សិស្សអាចគូសភ្ជាប់តួព្យញ្ជនៈ នឹងជើងព្យញ្ជនៈបានត្រឹមត្រូវ | |
| មេរៀនទី៦៨៖ ផ្ញើជើង ក្ត ក្ប ក្ស ក្អ | • សិស្សស្គាល់ចំណុចតួអក្សរ និងសញ្ញាជើង<br>• ឱ្យសិស្សរៀនប្រកបអាន និងសរសេរពាក្យព្យាង្គ និងល្បះ ផ្សំនឹងសញ្ញាជើង<br>ឧទាហរណ៍ ក្ងាន ក្បែរ<br>• តួអក្សរពួក អ ផ្សំសញ្ញាជើងពួក អ៊ ប្តូរទៅជា សូរ ពួក អ | • សិស្សអាចសរសេរពាក្យ និងសញ្ញាពាក្យដែលមានជើងព្យញ្ជនៈបានត្រឹមត្រូវតាមរយៈអក្សរចល័តបណ្ណរូបភាពបណ្ណពាក្យ និងសិស្សអាចធ្វើអក្ខរវិទ្យាបាន<br>• សិស្សអាចបំពេញជើងព្យញ្ជនៈពីក្រោម<br>• សិស្សអាចរៀបពាក្យបង្កើតជាល្បះបានត្រឹមត្រូវ | |
| មេរៀនទី៦៩៖ ផ្ញើជើង ក្ង ក្ន ក្ម ក្រ ក្ល<br>➢ រៀនសាឡើងវិញ | | | |
| មេរៀនទី៧០៖ ផ្ញើជើង ខ្ជ ខ្ច ខ្ត ខ្ន | | | |
| មេរៀនទី៧១៖ ផ្ញើជើង ខ្ម ខ្យ ខ្ល ខ្វ ខ្ស | | | |
| មេរៀនទី៧២៖ ផ្ញើជើង គ្ន គ្ម គ្រ | • សិស្សស្គាល់ចំណុចតួអក្សរ និងសញ្ញាជើង<br>• ឱ្យសិស្សរៀនប្រកបអាន និងសរសេរពាក្យព្យាង្គ និងល្បះ ផ្សំនឹងសញ្ញាជើង<br>ឧទាហរណ៍ គ្រែ ្នំ<br>• តួអក្សរពួក អ៊ ផ្សំសញ្ញាជើងពួក អ៊ នៅតែសូរពួក អ៊ ដដែល | | |
| មេរៀនទី៧៣៖ ផ្ញើជើង ឃ្ល ឃ្ន ្ន ្ល ្វ<br>រៀនសាឡើងវិញ | | | |

<table>
<tr><td>មេរៀនទី៧៤៖<br>ចម្រៀង ពេលដើរទៅសាលា</td><td>• ឱ្យសិស្សរៀនទន្ទេញចម្រៀងម្ដងមួយល្បះរហូតចាំស្ទាត់<br>• ឱ្យសិស្សរៀនធ្វើបទម្ដងមួយល្បះៗ<br>• ឱ្យសិស្សរៀនច្រៀងរហូតដល់ចប់</td><td>• សិស្សអាចចេះសញ្ញា និងយល់ពីន័យបទចម្រៀងតាមរយៈគ្រូពន្យល់ណែនាំ</td><td rowspan="12"></td></tr>
<tr><td>មេរៀនទី៧៥៖ ផ្ញើជើង ប្ប ប្ន ប្យ ប្រ</td><td rowspan="11">• សិស្សស្គាល់ចំណុចតួអក្សរ និងសញ្ញាជើង<br>• ឱ្យសិស្សរៀនប្រកបអាន និងសរសេរពាក្យព្យាង្គ និងល្បះ ផ្សំនឹងសញ្ញាជើង<br>• តួអក្សរពួក អ ផ្សំសញ្ញាជើងពួក អ៊ ប្ដូរទៅជា សូរ ពួក អ<br>• តួអក្សរពួក អ៊ ផ្សំសញ្ញាជើងពួក អ៊ នៅសូរពួក អ៊ ដដែល</td><td rowspan="11">• សិស្សចេះ សរសេរ និងសញ្ញា ពាក្យតាមរយៈអក្សរចល័តបណ្ណពាក្យរូបភាព<br>• សិស្សអាចស្គាល់ពីព្យញ្ជនៈ ជើងព្យញ្ជនៈ និងស្រៈ បានត្រឹមត្រូវ<br>• សិស្សអាចសរសេរពាក្យផ្សំដែលមានព្យញ្ជនៈ ជើងព្យញ្ជនៈ ផ្សំជាមួយស្រៈបានត្រឹមត្រូវ<br>• សិស្សអាចធ្វើអក្ខរវិទ្យាបានត្រឹមត្រូវ<br>• សិស្សអាចសរសេរបំពេញពាក្យបានត្រឹមត្រូវ<br>• សិស្សអាចបង្កើតល្បះដែលមានពាក្យផ្ញើជើងបានត្រឹមត្រូវ</td></tr>
<tr><td>មេរៀនទី៧៦៖ ផ្ញើជើង ឆ្ក ឆ្ង ឆ្ព ឆ្ន</td></tr>
<tr><td>មេរៀនទី៧៧៖ ផ្ញើជើង ឆ្ម ឆ្ល ឆ្វ ឆ្អ<br>រៀនសាឡើងវិញ</td></tr>
<tr><td>មេរៀនទី៧៨៖ ផ្ញើជើង ជ្រ ជ្វ</td></tr>
<tr><td>មេរៀនទី៧៩៖ ផ្ញើជើង ឈ្ង ឈ្ន ឈ្ម ឈ្វ</td></tr>
<tr><td>មេរៀនទី៨០៖ ផ្ញើជើង ត្ប ត្ន ត្រ<br>រៀនសាឡើងវិញ</td></tr>
<tr><td>មេរៀនទី៨១៖ ផ្ញើជើង ថ្ក ថ្ង ថ្ន ថ្ម ថ្ល ថ្វ</td></tr>
<tr><td>មេរៀនទី៨២៖ ផ្ញើជើង ទ្រ ទ្វ<br>រៀនសាឡើងវិញ</td></tr>
<tr><td>មេរៀនទី៨៣៖ ធ្វ ធ្ន ធ្ម</td></tr>
<tr><td>មេរៀនទី៨៤៖ ប្ដ ប្រ ប្ល ប្អ</td></tr>
<tr><td>មេរៀនទី៨៥៖<br>ផ្ក ផ្ង ផ្ទ ផ្ល<br>រៀនសាឡើងវិញ</td></tr>
</table>

| | | | |
|---|---|---|---|
| មេរៀនទី៨៦៖ ផ្ញើជើង<br>ផ្គ ផ្ន ផ្ល ផ្ស ផ្អ | | • សិស្សអាចបំពេញពាក្យពីក្រោមរូបភាពបាន | |
| មេរៀនទី៨៧៖ ផ្ញើជើង ព្ន ព្យ ព្រ ព្ល | | | |
| មេរៀនទី៨៨៖ ផ្ញើជើង<br>ភ្ទ ភ្ជ ភ្ព ភ្ន ភ្ល<br>រៀនសាឡើងវិញ | | | |
| មេរៀនទី៨៩៖ ផ្ញើជើង<br>ម្ក ម្ខ ម្ច ម្គ | | | |
| មេរៀនទី៩០៖ ផ្ញើជើង<br>ម្ទ ម្ជ ម្ព ម្ភ | | | |
| មេរៀនទី៩១៖ ផ្ញើជើង<br>ម្ន ម្ក ម្យ ម្រ ម្ល<br>រៀនសាឡើងវិញ | | | |
| មេរៀនទី៩២៖ ផ្ញើជើង<br>ល្ខ ល្ប ល្ហ ល្អ | | | |
| មេរៀនទី៩៣៖ ផ្ញើជើង ស្ក ស្គ ស្ដ ស្ប<br>ស្រ | | | |
| មេរៀនទី៩៤៖ ផ្ញើជើង<br>ស្ទ ស្ន ស្ម ស្ល ស្វ ស្អ<br>រៀនសាឡើងវិញ | | | |
| មេរៀនទី៩៥៖ ព្យាង្គតម្រួត ង្ក ង្ខ ង្វ ង្ស ង្ហ<br>ង្អ | | • សិស្សអាចសរសេរ និងចេះសញ្ញាបានពីព្យាង្គតម្រួត ង្ក ង្ខ ង្វ<br>• សិស្សអាចសរសេរពាក្យក្រោមរូបភាពបានត្រឹមត្រូវតាមរយៈបណ្ណពាក្យ អក្សរចល័ត វត្ថុជាក់ស្តែង និងរូបភាព | |
| មេរៀនទី៩៦៖ ព្យាង្គតម្រួត ង្គ ង្ឃ ង្រ<br>រៀនសាឡើងវិញ | | | |
| មេរៀនទី៩៧៖ ព្យាង្គតម្រួត ញ្ច ញ្ជ ញ្ឆ ញ្ឈ<br>ញ្ញ | | | |

| | | | |
|---|---|---|---|
| មេរៀនទី៩៨៖ ព្យាង្គតម្រួត ណ្ដ ណ្ណ ណ្ឋ | | | |
| មេរៀនទី៩៩៖ ព្យាង្គតម្រួត ន្យ ន្ទ ន្ល ន្ស | | | |
| មេរៀនទី១០០៖ ព្យាង្គតម្រួត ម្ត ម្ភ ម្ន ម្រ ម្ល រៀនសាឡើងវិញ | | | |
| មេរៀនទី១០១៖ ព្យាង្គតម្រួត ង្ក្រ ង្គ្រ | | • សិស្សអាចសរសេរ និងសញ្ញាបានត្រឹមត្រូវតាមរយៈ អក្សរចល័ត បណ្ណពាក្យ រូបភាព វត្ថុជាក់ស្តែង<br>• សិស្សអាចសរសេរតាមអានត្រួតពិនិត្យបានត្រឹមត្រូវ | |
| មេរៀនព្យាង្គតម្រួតទី១០២៖ ញ្ច្រ ញ្ជ្រ រៀនសាឡើងវិញ៖ ចង្ក្រាន សង្គ្រាម សង្គ្រោះ បង្ក្រាប កញ្ច្រែង កញ្ជ្រោង | | | |
| មេរៀនទី១០៣៖ អ្នកគ្រូខ្ញុំ | • គ្រូអានអត្ថបទឱ្យសិស្សស្តាប់ បន្ទាប់មកសួរសំណួរទៅកាន់សិស្ស<br>• ឱ្យសិស្សស្គាល់ពីចំណុចនៃពាក្យសំខាន់ៗនៅក្នុងអត្ថបទ<br>• ឱ្យសិស្សរៀនប្រកប អាន និងសរសេរពាក្យសំខាន់ៗនៅក្នុងអត្ថបទ | • សិស្សអាចធ្វើសញ្ញាអត្ថបទ មេរៀន និងយល់ន័យមេរៀនបានតាមរយៈគ្រូបង្ហាញរូបភាព និងសញ្ញាពន្យល់អត្ថន័យមេរៀន<br>• សិស្សចេះគោរព ស្រឡាញ់ និងដឹងគុណចំពោះគ្រូ<br>• សិស្សចេះ ជួយបោសសំអាតថ្នាក់រៀន និងថែទាំបរិស្ថានសាលារៀន | |
| មេរៀនទី១០៤៖ សាលារៀនខ្ញុំ | | | |

# មេរៀនទី៩៖ វិធីបង្រៀនសិស្សមានពិការភាព

## វត្ថុបំណង

នៅក្នុងមេរៀននេះប្រាប់ពី វិធីបង្រៀន និងរៀនបែបសកល វិធីបង្រៀនសិស្សពិបាកក្នុងការមើល វិធីបង្រៀនសិស្សពិបាកក្នុងការស្ដាប់ វិធីបង្រៀនសិស្សពិការសតិបញ្ញា និងអូទីស្សឹម និងបង្ហាញពីការផលិតសម្ភារៈបង្រៀន និងរៀនតាមប្រព័ន្ធឌីជីថល។

## ខ្លឹមសារ

### ៩.១ វិធីបង្រៀន និងរៀនបែបសកល សម្រាប់ការអប់រំបរិយាបន្ន

#### ក) ការយល់ដឹងអំពីការប្រើប្រាស់ខួរក្បាល និងវិធីបង្រៀន

យោងតាមការស្រាវជ្រាវផ្នែកបញ្ញា បានបង្ហាញថា មនុស្សម្នាក់ៗប្រើខួរក្បាលខុសៗគ្នា នៅពេលកំពុងរៀន។ ប្រភពដដែលបង្ហាញថា សិស្សត្រូវការយល់ដឹងច្រើន ជាងអ្វីដែលពួកគេរៀននៅក្នុងថ្នាក់ ដើម្បីទទួលបានភាពជោគជ័យនៅក្នុងជីវិត។ ប្រសិនបើសិស្សអាចជ្រើសរើសរបៀបរៀនដែលល្អសម្រាប់គេ នោះដំណើរការសិក្សាកាន់តែមានប្រសិទ្ធភាព។ វិទ្យាសាស្ត្រផ្នែកបញ្ញា ក៏ប្រាប់យើងផងដែរអំពី មូលហេតុដែលគ្រូ ត្រូវផ្ដល់ឱ្យសិស្សនូវវិធីផ្សេងៗគ្នា ក្នុងការកំណត់គោលដៅនៃការសិក្សា ការទទួលបាននូវព័ត៌មាន បំណិន និងការប្រើប្រាស់ចំណេះដឹងថ្មីៗ។ ដូចបានបញ្ជាក់ខាងលើ គ្រូបង្រៀនប្រហែលគិតថាវាហាក់ដូចជាកិច្ចការច្រើនសន្ធឹកសន្ធាប់ ព្រោះថាគ្រូមានសិស្សជាច្រើននៅក្នុងថ្នាក់។ ក៏ប៉ុន្តែមានក្របខណ្ឌមួយ ដែលហៅថា វិធីបង្រៀន និងរៀនបែបសកល (Universal Design for Learning) ដែលអាចជួយគ្រូក្នុងការអនុវត្តការបង្រៀនឆ្លើយតបទៅនឹងកម្រិតបញ្ញារបស់សិស្ស។

ការបង្រៀន និងរៀនបែបសកល (UDL) គឺជាក្របខណ្ឌមួយ ដែលគេប្រើសម្រាប់រៀបចំកិច្ចតែងការបង្រៀន រៀបចំ ឬបង្កើតបរិស្ថានសិក្សា និងអនុវត្តការបង្រៀន ដើម្បីធានាថាសិស្សគ្រប់រូប ទទួលបានការគាំទ្រផ្នែកអារម្មណ៍ ផ្នែករាងកាយ និងការសិក្សារៀនសូត្រ និងទទួលបានឱកាសជាបន្តបន្ទាប់ ហើយដើម្បីឱ្យសិស្សបានចូលរួមក្នុងដំណើរការរៀនប្រកបដោយបរិយាបន្ន។ គោលការណ៍ណែនាំអំពី UDL ត្រូវបានបង្កើតឡើងដើម្បីផ្ដល់ការណែនាំដល់គ្រូបង្រៀន។ គោលការណ៍នីមួយៗមានព័ត៌មានអំពីអ្វីដែលគ្រូអាចអនុវត្តក្នុងការបង្រៀនដើម្បីជួយសិស្សម្នាក់ៗដែលមានតម្រូវការសិក្សាផ្សេងៗគ្នា។ គោលបំណងដើម្បីជួយសិស្សឱ្យទទួលបាននូវចំណេះដឹង និងបំណិនផ្សេងៗក្រៅពីខ្លឹមសារមេរៀនដែលបានរៀន។

- <u>គោលការណ៍ទី១៖ ការចូលរួម</u>

គោលការណ៍នេះ ផ្ដោតទៅលើការទាក់ទាញចំណាប់អារម្មណ៍ និងការផ្ទង់អារម្មណ៍របស់សិស្ស ក្នុងការជួយពួកគេឱ្យចេះផ្ដោតការយកចិត្តទុកដាក់ និងរៀននូវរបៀបដែលពួកគេគ្រប់គ្រងអារម្មណ៍ ដើម្បីផ្ដោតលើការសិក្សាបានល្អ។ ហេតុផលដែលគ្រូផ្ដល់នូវជម្រើសផ្សេងៗគ្នាក្នុងការរៀនសូត្រដើម្បីជួយសិស្សឱ្យចេះផ្សារភ្ជាប់នូវគោលបំណង និងការលើកទឹកចិត្តសម្រាប់ការសិក្សា។ តើជម្រើសផ្សេងៗទាំងនេះមានលក្ខណៈដូចម្ដេច? ឧទាហរណ៍មួយចំនួននៃគោលការណ៍ក្នុងការចូលរួម៖

- ពេលលើកឧទាហរណ៍ និងនិយាយរឿងរ៉ាវ ដែលផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅរបស់សិស្ស គឺជួយសិស្សឱ្យរកឃើញនូវគោលបំណង និងការលើកទឹកចិត្ត។
- នៅពេលដែលសិស្សមានជម្រើសជាច្រើន ដូចជា ការជ្រើសរើសសៀវភៅរឿងដែលត្រូវអាន ប្រធានបទដែលត្រូវសរសេរ ឬដៃគូមួយណាដែលពួកគេត្រូវធ្វើការជាមួយដោយខ្លួនឯង វាបានជួយឱ្យពួកគេរកឃើញគោលបំណង និងការលើកទឹកចិត្តសម្រាប់ការសិក្សា។
- នៅពេលដែលគ្រូបង្ហាញជាគំរូមួយថា ការប្រព្រឹត្តខុស គឺជាសកម្មភាពមួយនៃការរៀនសូត្រ។
- លើកទឹកចិត្តសិស្សឱ្យចេះតាមដានការរីកចម្រើននៃការរៀនសូត្រ កំណត់គោលដៅ និងតាមដាននូវការរីកចម្រើនដើម្បីសម្រេចគោលដៅ។
- ណែនាំសិស្សឱ្យចេះអត់ធ្មត់ នៅពេលប្រឈមនឹងការលំបាកក្នុងការធ្វើកិច្ចការ។
- ការផ្ដល់ព័ត៌មានត្រឡប់បែបស្ថាបនា ដោយប្រាប់នូវចំណុចដែលគេធ្វើបានល្អ បន្ទាប់មក ប្រាប់ពីចំណុចដែលត្រូវកែលម្អ និងចុងក្រោយ ប្រាប់ពីវិធីក្នុងការកែលម្អឱ្យបានជាក់លាក់។

❖ <u>គោលការណ៍ទី២៖ ការផ្ទេរចំណេះដឹង</u>

គោលការណ៍នេះផ្ដោតទៅលើការផ្ដល់ចំណេះដឹងតាមរយៈការស្ដាប់ និងការមើលឃើញដើម្បីឱ្យសិស្សងាយយល់ ហើយនឹងការផ្ដល់វិធី និងជម្រើសផ្សេងៗដើម្បីជួយឱ្យសិស្សយល់ពីខ្លឹមសារផងដែរ។ ហេតុផលដែលយើងផ្ដល់ជម្រើសផ្សេងៗក្នុងការរៀនសូត្រ ដើម្បីជួយសិស្សប្រើប្រាស់ចំណេះដឹងថ្មី ក៏ដូចជាចំណេះដឹងមានស្រាប់ និងចេះប្រើធនធាននៅជុំវិញពួកគេ ដើម្បីសម្រេចវត្ថុបំណងមេរៀន។ តើជម្រើសផ្សេងៗទាំងនេះមានលក្ខណៈដូចម្ដេច? ឧទាហរណ៍មួយចំនួននៃគោលការណ៍នៃការផ្ទេរចំណេះដឹង៖

- ពេលសិស្សរៀនពីផ្កា យើងឱ្យសិស្សចង្អុលរូបភាពផ្កានៅលើជញ្ជាំង ឬសិស្សយកផ្កាពីខាងក្រៅមកចូលក្នុងថ្នាក់ ឬសិស្សចេញទៅមើលផ្កានៅខាងក្រៅថ្នាក់ នោះយើងបានជួយពួកគេឱ្យបង្កើនចំណេះដឹង និងចេះប្រើប្រាស់ធនធាននៅជុំវិញខ្លួន
- ពេលសិស្សធ្វើលំហាត់គណិតវិទ្យាដោយប្រើក្រដាស ខ្មៅដៃ ចង្កឹះ ឬធ្វើការជាមួយដៃគូ គ្រូឱ្យសិស្សជ្រើសរើសវិធីផ្សេងៗដែលគេចូលចិត្តក្នុងការដោះស្រាយលំហាត់
- ពេលគ្រូឱ្យសិស្សផ្សារភ្ជាប់នូវមុខវិជ្ជាដែលគេកំពុងរៀនឧទាហរណ៍មុខវិជ្ជាវិទ្យាសាស្ត្រ និងមុខវិជ្ជាគណិតវិទ្យា ដូចជាមេរៀនអំពីការលូតលាស់នៃរុក្ខជាតិ ផ្សារភ្ជាប់នឹងការវាស់កម្ពស់រុក្ខជាតិ
- គ្រូអាចទាញចំណាប់អារម្មណ៍សិស្សគឺការប្រើសញ្ញាជាសូរសំឡេង ឧទាហរណ៍សូរសំឡេងនាឡិការោទិ៍ លើកក្រដាស ញាក់ភ្លើង ចុចកុងតាក់ភ្លើងបិទ ឬបើកធ្វើជាសញ្ញា ឬធ្វើសូរសញ្ញាផ្សេងៗបីនាទីមុនម៉ោងកំណត់ដើម្បីឱ្យសិស្សត្រៀមបញ្ចប់កិច្ចការតាមសម្រួល
- ពេលសិស្សរៀនកំណាព្យឬមេសូត្រ គ្រូអាចលើកទឹកចិត្តសិស្សឱ្យគោះតុតិចៗ (ឬទះដៃ) នៅពេលដែលឮពាក្យចុងចួនម្ដងៗ ជាការសង្កត់ទៅលើបែបបទនៃកំណាព្យឬមេសូត្រ
- គ្រូបង្រៀនមេរៀនមួយដែលចាប់ផ្ដើមដោយបំផុសសិស្សចែករំលែកអ្វីដែលបានដឹងទាក់ទងនឹងប្រធានបទរួចផ្សារភ្ជាប់ទៅនឹងមេរៀនថ្មី (ដូចជាការបង្កើតផែនទីពាក្យទៅនឹងការនេសាទ ឬសាលាកុមារមេត្រី)

❖ គោលការណ៍ទី៣៖ ការធ្វើសកម្មភាព និងការបង្ហាញ

គោលការណ៍នេះផ្តោតទៅលើវិធីផ្សេងៗ ដើម្បីឱ្យសិស្សបង្ហាញនូវអ្វីដែលពួកគេបានដឹង និងជួយពួកគេឱ្យចេះកំណត់គោលដៅ ចេះធ្វើផែនការ និងតាមដានការរីកចម្រើន។ ហេតុផលដែលគ្រូផ្តល់នូវជម្រើសផ្សេងៗគ្នាក្នុងការរៀនសូត្រដើម្បីជួយសិស្សឱ្យក្លាយទៅជាគ្រូមានយុទ្ធវិធី និងមានគោលដៅនៅពេលសិក្សា ក៏ដូចជានៅក្នុងជីវិតផ្ទាល់ខ្លួន។ តើវាមានលក្ខណៈដូចម្តេច? ឧទាហរណ៍មួយចំនួននៃគោលការណ៍ក្នុងការធ្វើសកម្មភាព និងការបង្ហាញ៖

- ពេលសិស្សត្រូវសរសេរអត្ថបទ ហើយឱ្យសិស្សជ្រើសរើសការធ្វើការជាដៃគូ ឬធ្វើការជាបុគ្គល។ ពួកគេត្រូវគិតថា តើជម្រើសមួយណាល្អ ដើម្បីសម្រេចគោលដៅ
- ពេលគ្រូឱ្យសិស្សធ្វើផែនការកំណត់គោលដៅ ហើយគ្រូជួយពួកគេរក និងប្រើប្រាស់ធនធាន ដែលនៅជុំវិញខ្លួន
- ពេលគ្រូឱ្យសិស្សព្រាងគំនិតរកវិធីផ្សេងៗ ដូចជាការតែងកំណាព្យ ការច្រៀងចម្រៀង គូររូបភាព ឬការកសាងរបស់អ្វីមួយជាគំរូ ដើម្បីបង្ហាញប្រធានបទណាមួយដែលពួកគេបានយល់
- គ្រូឱ្យសិស្សអានអត្ថបទ រួចធ្វើការសង្ខេប ហើយកត់ត្រាចូលក្នុងសៀវភៅកិច្ចការរបស់ខ្លួន។
- ឱ្យសិស្សគិតនូវជម្រើសផ្សេងៗគ្នាក្នុងការបង្ហាញចំណេះដឹង និងផ្តល់ចម្លើយដូចជាប្រើប្រាស់រូបភាព ធ្វើការពន្យល់ ឬសង្ខេបដោយផ្ទាល់មាត់ បង្ហាញកិច្ចការនោះ ប្រាប់ទៅសិស្សដទៃទៀត។ អ្វីដែលសំខាន់នោះគឺគ្រូឱ្យសិស្សឆ្លុះបញ្ចាំង ថាតើហេតុអ្វីបានជាយកជម្រើសនោះ
- ពេលរៀនបំណិនថ្មីគ្រូផ្តល់ការគាំទ្រជាជំហានខ្លីៗ ឬជាផ្នែកខ្លីៗ (ហៅថាការឈានឡើងជាដំណាក់ៗ) ឧទាហរណ៍៖ ការបង្រៀនបូកលេខ គឺត្រូវចាប់ផ្តើមពីរូបី ពាក់កណ្តាលរូបី និងអរូបី។ សិស្សពូកែអាចចាប់ផ្តើមពីអរូបី សិស្សមធ្យមចាប់ផ្តើមពីពាក់កណ្តាលរូបី ហើយសិស្សខ្សោយគឺចាប់ផ្តើមពីរូបីរហូតដល់អរូបី
- ឧទាហរណ៍៖ ការសរសេរកថាខណ្ឌ ដំបូងឡើយគ្រូជួយសិស្សក្នុងការបង្កើតផែនទីពាក្យ បន្ទាប់មកគ្រូជួយសិស្សក្នុងការសរសេរឃ្លាខ្លីៗ រួចចុងក្រោយជួយសិស្សក្នុងការសរសេរជាកថាខណ្ឌ។

## ខ) ធាតុផ្សំគោលការណ៍បង្រៀន និងរៀនបែបសកល

**មានធាតុផ្សំ៤ រួមមានគោលដៅ វិធីសាស្ត្រ ឯកសារ និងការវាយតម្លៃ**

| | |
|---|---|
| គោលដៅ | • ការរំពឹងទុកនូវចំណេះដឹង បំណិន និងទស្សនទាន ដើម្បីឱ្យសិស្សគ្រប់រូបសម្រេចបាននូវលទ្ធផលរៀនសូត្រ<br>• ការផ្តោតលើការបង្កើតខ្លឹមសារ ឬការរៀនសូត្ររបស់សិស្សដោយមានការកំណត់នូវសេចក្តីរំពឹងទុកខ្ពស់របស់សិស្ស គ្រប់រូបសម្រេចបាន<br>• ការដាក់បញ្ចូលនូវលក្ខណៈផ្សេងៗគ្នារបស់សិស្ស និងរបៀប ឬមធ្យោបាយញែកគោលដៅចេញ<br>• គ្រូបង្រៀនចេះផ្តល់ជម្រើសកាន់តែច្រើនមានគោលវិធី ឧបករណ៍ និងការគាំទ្រផ្សេងៗ ដើម្បីបង្កើនការយល់ដឹងដល់សិស្ស។ |

| | |
|---|---|
| វិធីសាស្ត្រ | • សំដៅលើការសម្រេចចិត្ត គោលវិធី គោលការណ៍ ឬទម្លាប់ក្នុងការបង្រៀនរបស់គ្រូដើម្បីពន្លឿន ឬជំរុញការរៀនសូត្ររបស់សិស្ស<br>• គ្រូប្រើប្រាស់វិធីសាស្ត្រផ្អែកលើបេកគំហើញដើម្បីឱ្យសម្រេចគោលដៅនៃការបង្រៀន<br>• ការដាក់បញ្ចូលវិធីសាស្ត្រចម្រុះផ្អែកតាមលក្ខណៈរបស់សិស្សក្នុងបរិបទ កិច្ចការធនធាន ចិត្តសង្គម និងបរិយាកាសក្នុងថ្នាក់រៀន<br>• ការរៀបចំគោលការណ៍បង្រៀន និងរៀនមានលក្ខណៈបត់បែន និងចម្រុះដែលអាចកែសម្រួលបានទៅតាមការពិនិត្យតាមដានជាប្រចាំលើវឌ្ឍនភាពរបស់សិស្ស<br>ឧទាហរណ៍ក្នុងមេរៀនស្ដីពីការវិវត្តរបស់ សកម្មភាពរៀនសូត្ររួមមាន៖<br>➢ គ្រូបង្រៀនបង្ហាញឃ្លីបវីដេអូដែលរៀបរាប់ពីដំណាក់កាល ផ្សេងៗនៃការវិវត្តរបស់មេអំបៅ<br>➢ សិស្សគិត ធ្វើកិច្ចការជាដៃគូ និងចែករំលែកគំនិតស្ដីពីពេលវេលាចុងក្រោយដែលពួកគេបានឃើញមេអំបៅ ឬដង្កូវមេអំបៅ<br>➢ សិស្សអានអត្ថបទខ្លីដែលរៀបរាប់ពីដំណាក់កាលនីមួយៗនៃការវិវត្តរបស់មេអំបៅ<br>➢ សិស្សអានកម្រងអត្ថបទដែលបំបែកដោយផ្អែកស្ដីពីការវិវត្ត ហើយធ្វើការកត់ត្រា<br>➢ សិស្សបង្ហាញពីការយល់ដឹងរបស់ខ្លួនដោយសរសេរកថាខណ្ឌ រៀបរាប់ពីជំហាននីមួយៗ<br>➢ រៀបចំប្លង់សកលសម្រាប់ការរៀនបន្ថែមដើម្បីដោះស្រាយឧបសគ្គក្នុងការរៀនសូត្ររបស់សិស្ស<br>➢ បង្ហាញពីចំណេះដឹងដែលមានលក្ខណៈចម្រុះ និងបត់បែន។ |
| ឯកសារ | • គោលការណ៍បង្រៀន និងរៀនបែបសកលត្រូវបានប្រើប្រាស់ជាឧបករណ៍ផ្សេងៗគ្នាសម្រាប់បង្ហាញនូវចំណេះដឹង និងទស្សនទាន<br>• ចំណេះដឹង និងមេរៀនបទពិសោធន៍ត្រូវបានប្រើប្រាស់សម្រាប់ការវិភាគ និងសំយោគព័ត៌មានពាក់ព័ន្ធនឹងគោលវិធីជួយសិស្ស និងការរៀនសូត្ររបស់សិស្សត្រូវបានយកមកប្រើប្រាស់សម្រាប់ការវាយតម្លៃដើម្បីកំណត់លើកម្រិតចំណេះដឹង បំណិន និងការជំរុញលើកទឹកចិត្តដល់សិស្ស<br>• គ្រូបង្រៀនប្រើប្រាស់ការវាយតម្លៃ ដើម្បីធ្វើការសម្រេចចិត្តគ្រប់ជ្រុងជ្រោយពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀន។ |
| ការវាយតម្លៃ | • ការផ្ដោតលើលក្ខណៈគ្រប់ជ្រុងជ្រោយ និងច្បាស់លាស់សម្រាប់ជួយដល់ការបង្រៀនសិស្សទាំងអស់<br>• ការវាយតម្លៃជួយកាត់បន្ថយឧបសគ្គជាមធ្យោបាយវាស់វែងត្រឹមត្រូវលើចំណេះដឹង បំណិន និងការចូលរួមរបស់សិស្សដែលមានលក្ខណៈផ្សេងៗគ្នា។ |

## ៩.២ វិធីបង្រៀនសិស្សពិបាកក្នុងការមើល

ដំបូងសិស្សត្រូវរៀនធ្វើចលនា និងបំលាស់ទីជាមុន បន្ទាប់មកទើបចាប់ផ្តើមរៀនស្គាល់ឧបករណ៍ប្រើប្រាស់ក្នុងការរៀនសរសេរ និងអាន។ ជំហានដំបូងការចល័តពិតជាមានសារៈសំខាន់ណាស់សម្រាប់សិស្សពិបាកក្នុងការមើលព្រោះថាកុមារដែលមកសាលារៀនជាលើកដំបូងគឺមិនអាចស្គាល់ទីតាំង និងដើរបាននោះទេ ដោយសារតែពួកគេស៊ាំនឹងទីកន្លែងនៅផ្ទះសូម្បីតែការងូតទឹកក៏ជាបញ្ហាប្រឈមសម្រាប់ពួកគេដែរ ហើយនៅពេលដែលពួកគេរៀនពីរបៀបផ្លាស់ទីដោយខ្លួនឯងវាគឺជាជោគជ័យដ៏អស្ចារ្យរួចទៅហើយ។ ដំបូងគ្រូបង្រៀនធ្វើតាមពួកគេ និងបង្រៀនពួកគេឱ្យចេះថែរក្សាគ្នា ដើម្បីឱ្យកុមារបង្ហាញពីសាមគ្គីភាពពិតប្រាកដចំពោះគ្នាទៅវិញទៅមក។

ក្នុងពេលជាមួយគ្នានេះ គ្រូបង្រៀនពីរបៀបអាន និងសរសេរជាភាសាខ្មែរដោយប្រើប្រាស់អក្សរប្រៃយ៍ជាមួយនឹងឧបករណ៍ស្លេត ស្លៃយ៍ឡាស់ និងសម្ភារៈសិក្សាផ្សេងទៀតដែលសមស្របដើម្បីជួយដល់ការរៀនសូត្ររបស់ពួកគេបាន។ កុមារពិបាកក្នុងការមើលអាចទទួលបានព័ត៌មានតាមរយៈការស្តាប់ ប៉ះ ឬស្ទាប និងមើលឃើញដោយប្រើឧបករណ៍ជំនួយ។ ដូចនេះគ្រូចាំបាច់ត្រូវផលិតសម្ភារៈបង្រៀន និងរៀនឱ្យបានច្រើន។ ក្នុងនោះម៉ាស៊ីនបោះពុម្ពអក្សរប្រៃយ៍ត្រូវបានប្រើប្រាស់ជាប្រយោជន៍សម្រាប់ធ្វើការចងក្រងនូវឯកសារពាក់ព័ន្ធជាពិសេសស្របទៅនឹងសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងនាមជាគ្រូបង្រៀន អាទិភាពចម្បងគឺធានាថាសិស្សទាំងអស់មានឱកាសស្មើគ្នាក្នុងការទទួលបានសម្ភារៈសិក្សា និងជោគជ័យលើការរៀនសូត្រ។ ដើម្បីបង្រៀនសិស្សពិបាកក្នុងការមើល គ្រូគួរតែកែប្រែវិធីបង្រៀន និងអនុញ្ញាតឱ្យមានការប្រើប្រាស់ឧបករណ៍ជំនួយ បច្ចេកវិទ្យាជំនួយ និងបង្កើតបរិយាកាសសិក្សាប្រកបដោយសុវត្ថិភាព។

### ៩.២.១ វិធីសាស្ត្រទី១៖ យុទ្ធវិធីបង្រៀន

| | |
|---|---|
| ក) ការពន្យល់អំពីរូបភាព | • ពិតជាសំខាន់ណាស់ក្នុងអំឡុងពេលកំពុងបង្រៀនគ្រូ ត្រូវពន្យល់ឱ្យបានច្បាស់នូវគ្រប់សម្ភារៈទាំងអស់ដែលមានទៅកាន់សិស្ស<br>• ឧទាហរណ៍គ្រូបង្រៀនមេរៀនពណ៌នាអំពីរូបភាព គ្រូអាចនិយាយថា ខ្ញុំបានដាក់រូបភាពម្ចាស់ក្សត្រី Elizabeth I នៅលើក្តារខៀន គាត់ស្លៀកឈុតធំដែលមានប៉ាក់ឱន និងត្បូង៖<br>➢ ត្រង់នេះគឺបង្ហាញពីទ្រព្យសម្បត្តិ និងអំណាចរបស់ម្ចាស់ក្សត្រី ហើយបន្ទាប់មកគ្រូឱ្យសិស្សពណ៌នាឡើងវិញ នូវអ្វីដែលគ្រូកំពុងសរសេរ ឬនិយាយ<br>➢ វិធីនេះជួយសិស្សពិបាកក្នុងការមើល ដឹងអំពីរូបភាពតាមរយៈការពណ៌នារបស់គ្រូ និងអាចកត់ត្រាបាន។ |
| ខ) ការណែនាំផ្ទាល់មាត់ | • គ្រូអាចផ្តល់ការណែនាំផ្ទាល់មាត់គ្រប់កិច្ចការ និងសកម្មភាពទាំងអស់។ |
| គ) ការសុំឱ្យសិស្សទះដៃ ឬលើកដៃសួរសំណួរ | • ដើម្បីសួរសំណួរ ឬទទួលបានការចាប់អារម្មណ៍ពីគ្រូសិស្សត្រូវលើកដៃឡើងប្រសិនបើពួកគេចង់និយាយ ឬសួរសំណួរក្នុងពេលរៀន |

| | |
|---|---|
| | • សម្រាប់សិស្សពិបាកក្នុងការមើលគ្រូគួរតែជំនួសសញ្ញាដែលមើលឃើញដោយសញ្ញាជាសំឡេង ឧទាហរណ៍ គ្រូអាចឱ្យសិស្សទះដៃពីរដង ឬលើកដៃជាសញ្ញា ប្រសិនបើពួកគេចង់សួរសំណួរ។ |
| **ឃ) ការផ្តល់បទពិសោធន៍នៃការរៀនដោយប្រើកាយវិញ្ញាណ** | • គ្រូព្យាយាមប្រើមធ្យោបាយណាមួយដែលអាចធ្វើទៅបាន ដើម្បីឱ្យសិស្សទទួលបានបទពិសោធន៍ដឹងដោយការប្រើកាយវិញ្ញាណ<br>• ឧទាហរណ៍ថាគ្រូបង្រៀនមេរៀនអំពីដុំថ្មៈ<br>➢ គ្រូត្រូវបង្ហាញរូបភាពដុំថ្ម ដែលមានរូបរាងជាដុំថ្មជារូបភាពពក ឱ្យសិស្សកាន់ ឬស្ទាបក្នុងន័យឱ្យសិស្សទទួលអារម្មណ៍ដឹងពីរូបរាងរបស់ដុំថ្ម<br>➢ គ្រូអាចប្រើប្រាស់ដុំថ្មពិតប្រាកដឱ្យសិស្សកាន់ ឬប៉ះស្ទាប ដើម្បីឱ្យសិស្សស្វែងយល់ពីរូបរាងតាមរយៈកាយវិញ្ញាណថា ដុំថ្មមានរូបរាងបែបហ្នឹង។ |
| **ង) ការប្រាប់សិស្សដោយនិយាយឈ្មោះ** | • គ្រូត្រូវហៅឈ្មោះសិស្សជានិច្ចគ្រប់ការទំនាក់ទំនងជាមួយសិស្ស ព្រោះតាមវិធីនេះសិស្សដែលពិបាកក្នុងការមើល អាចកំណត់អត្តសញ្ញាណមិត្តភក្តិរបស់ពួកគេដោយផ្អែកលើសំឡេង។ |
| **ច) ការផ្តល់ពេលបន្ថែមដើម្បីបំពេញការងារ** | • ក្នុងករណីខ្លះសិស្សអាចត្រូវការពេលវេលាបន្ថែម ដើម្បីបំពេញកិច្ចការ ឬធ្វើតេស្តប្រឡង ព្រោះពួកគេត្រូវការពេលអាន ឬសរសេរជាអក្សរប្រែយ៍ ឬប្រើជំនួយបច្ចេកវិទ្យាណាមួយ<br>• បើទោះបីជាគ្រូចង់បញ្ចប់កិច្ចការណាមួយជាមួយសិស្ស ដូច្នេះគ្រូគួរតែផ្តល់ពេលវេលាសមរម្យសម្រាប់ពួកគេ។ |
| **ឆ) ការប្រព្រឹត្តចំពោះសិស្សដោយស្មើភាពគ្នា** | • គ្រូត្រូវអនុវត្តគ្រប់សិស្សទាំងអស់ ដោយឈរលើអព្យាក្រឹតរួមទាំងការបង្រៀន រចនាសម្ព័ន្ធថ្នាក់រៀន និងវិន័យថ្នាក់រៀនជាដើម ដោយមិនមានការរើសអើង<br>• លើកទឹកចិត្តសិស្សទាំងអស់ឱ្យរាប់អានគ្នាជាមិត្តភក្តិ និងចេះជួយគ្នាដោយមិនប្រកាន់ថាមាន ឬក្រ និងការរៀនឆាប់ចេះ និងរៀនយឺត<br>• គ្រូបង្រៀនត្រូវជៀសវាងការផ្តោត ឬយកចិត្តទុកដាក់ទៅលើសិស្សណាម្នាក់ដែលខ្លួនពេញចិត្តជាង។ |

### ៩.២.២ វិធីសាស្ត្រទី២៖ ការផ្តល់បរិយាកាសសិក្សាសមស្រប

| | |
|---|---|
| **ក) ការរៀបចំបង្គុយសិស្ស** | • គ្រូបង្រៀនរៀបចំបង្គុយសិស្សឱ្យនៅខាងមុខងាយស្រួលស្តាប់គ្រូពន្យល់មេរៀន<br>• អំឡុងពេលបង្រៀនគ្រូគួរតែឈរក្បែរសិស្ស និងចាំជួយសិស្ស ឬអាចឱ្យសិស្សផ្សេងទៀតអង្គុយក្បែរ |

| | |
|---|---|
| | • គ្រូអាចប្រើប្រាស់ក្តារខៀនចល័ត |
| ខ) ការរៀបចំសិស្សនៅក្បែរពន្លឺ | • គ្រូរៀបចំសិស្សឱ្យអង្គុយនៅក្បែរបង្អួច ដើម្បីឱ្យមានពន្លឺគ្រប់គ្រាន់ដែលផ្តល់ជាប្រយោជន៍សម្រាប់ការរៀនសូត្រ<br>• គ្រូត្រូវរៀបចំតាមប្រភេទពិការ និងតម្រូវការជាក់ស្តែងរបស់សិស្ស |
| គ) ការរៀបចំទីកន្លែងសមស្របក្នុងថ្នាក់រៀន | • គ្រូត្រូវរៀបចំតុ កៅអី ទូ និងធ្វើឱ្យបានសមស្រប និងត្រឹមត្រូវនៅក្នុងថ្នាក់រៀន ព្រោះការធ្វើបែបនេះបង្កនូវភាពងាយស្រួលក្នុងការបំលាស់ទីរបស់សិស្សដោយមិនប៉ះទង្គិច ឬបុកវត្ថុផ្សេងៗ<br>• គ្រូត្រូវបិទរុំព័ទ្ធជ្រុងណាមួយ ដែលអាចនាំឱ្យគ្រោះថ្នាក់ដល់សិស្សលើទ្វារ ទូដាក់អីវ៉ាន់ តុ និងកៅអីជាដើមឱ្យបានស្អាត<br>• គ្រូត្រូវផ្តល់ការណែនាំគ្រប់សម្ភារៈទាំងអស់នៅក្នុងថ្នាក់រៀន និងពន្យល់ពីទីកន្លែងដែលត្រូវផ្លាស់ប្តូរដល់សិស្ស ហើយប្រសិនបើមានឧបករណ៍មុតស្រួចនៅទីតាំងណាមួយគ្រូត្រូវតែប្រាប់ពីទីតាំងច្បាស់លាស់ដល់សិស្ស<br>• គ្រូត្រូវប្រាប់ពីទីតាំងទុកសម្ភារៈ ហើយលើកទឹកចិត្តសិស្សឱ្យទុកនៅកន្លែងដដែលវិញក្រោយពួកគេប្រើប្រាស់រួច ដើម្បីកុំឱ្យមានការភ័ន្តច្រឡំនូវរាល់ការផ្លាស់ប្តូរទីតាំង |

### ៩.៣ វិធីបង្រៀនសិស្សពិបាកក្នុងការស្តាប់

ប្រសិទ្ធភាពនៃការបង្រៀនសិស្សពិបាកក្នុងការស្តាប់គឺអាស្រ័យលើតម្រូវការជាក់ស្តែង សេវាកម្ម និងបរិស្ថានសិក្សារបស់សិស្សម្នាក់ៗ ហើយគ្រូបង្រៀនចាំបាច់ត្រូវបំពេញតម្រូវការរបស់ពួកគេឱ្យបានល្អបំផុតតាមលទ្ធភាពដែលអាចធ្វើទៅបាន។ បញ្ហាប្រឈមលើការអប់រំសិស្សពិបាកក្នុងការស្តាប់ គឺពាក់ព័ន្ធទៅនឹងវិធីសាស្ត្រទំនាក់ទំនងជាមួយសិស្សដើម្បីឱ្យគ្រូងាយស្រួលក្នុងការផ្ទេរចំណេះដឹង។

ភាសាសញ្ញា គឺជាភាសាមួយប្រភេទដែលប្រើកាយវិការដៃ និងទឹកមុខតំណាងឱ្យទាំងអក្សរ និងពាក្យដើម្បីឱ្យសិស្សពិបាកក្នុងការស្តាប់អាចទំនាក់ទំនងបាន។ សិស្សអាចចូលចិត្តប្រើភាសាសញ្ញាជាមធ្យោបាយចម្បងក្នុងការប្រាស្រ័យទាក់ទងគ្នាជំនួសឱ្យការនិយាយ ឬការសរសេរដើម្បីប្រាស្រ័យទាក់ទងគ្នា។




### ៩.៣.១ វិធីសាស្ត្រទី១៖ ទំនាក់ទំនងរវាងគ្រូ និងសិស្ស

| | |
|---|---|
| **ក) ការជៀសវាងការសន្មត** | • សិស្សត្រូវពាក់ឧបករណ៍ជំនួយការស្តាប់ ដើម្បីទំនាក់ទំនងតាមរយៈការនិយាយ ប្រើភាសាសញ្ញា គ្រូបកប្រែដើម្បីងាយស្រួលក្នុងការទាក់ទង<br>• សួរសិស្សពីរបៀបដែលពួកគេចង់ប្រាស្រ័យទាក់ទងជាមួយគ្រូ<br>• គ្រូត្រូវគិតថាសិស្សអាចនឹងចូលចិត្តរបៀបទំនាក់ទំនងផ្សេងគ្នា នៅក្នុងស្ថានភាពខុសគ្នា |
| **ខ) ការនិយាយដោយ ផ្ទាល់ទៅកាន់សិស្ស** | • គ្រូត្រូវឈរនៅទល់មុខសិស្សដើម្បីឱ្យសិស្សមើលឃើញបបូរមាត់គ្រូ និងមិនមានសំឡេងរំខាន<br>• ការផ្លាស់ប្តូរកម្រិតសំឡេងរបស់គ្រូអាចមានប្រយោជន៍<br>• ការបាត់បង់ការស្តាប់មានកម្រិតផ្សេងៗគ្នា<br>➢ បញ្ចេញសម្លេង និងធ្វើឱ្យចលនាបបូរមាត់របស់គ្រូដើម្បីឱ្យសិស្សងាយស្រួលកត់សម្គាល់៖ កុំឈរនៅមុខប្រភពពន្លឺព្រោះវានឹងធ្វើឱ្យពិបាកមើលបបូរមាត់របស់គ្រូ<br>➢ គ្រូត្រូវចងសក់មុខឱ្យបានត្រឹមត្រូវ<br>➢ កុំបិទ ឬខ្ទប់មាត់ |
| **គ) ជំនួយរបស់គ្រូបកប្រែ** | • គ្រូបកប្រែនឹងជួយសិស្សឱ្យយល់ពីអ្វីដែលកំពុងរៀននៅក្នុងថ្នាក់<br>• គ្រូបកប្រែត្រូវធ្វើសញ្ញាទៅតាមអ្វីដែលគ្រូបង្រៀនកំពុងនិយាយនៅក្នុងថ្នាក់រៀន<br>• គ្រូបកប្រែត្រូវឈរចំមុខសិស្ស ដើម្បីឱ្យសិស្សងាយស្រួលមើលសញ្ញាទុកពេលសម្រាប់គ្រូបកប្រែដើម្បីបញ្ចប់ការបកប្រែអ្វីដែលគ្រូបាននិយាយ |

| | |
|---|---|
| ឃ) ការប្រើប្រាស់សម្ភារៈជំនួយបន្សុីទៅនឹងមេរៀន | • សម្ភារៈបង្រៀន និងរៀនមានប័ណ្ណពាក្យ ស្រៈ រូបភាពភាសាសញ្ញាជាដើម<br>• សម្ភារៈបច្ចេកវិទ្យាមានទូរទស្សន៍ ម៉ាស៊ីនបញ្ចាំងស្លាយ ថាប់ប្លេត ជាដើម |
| ង) ការប្រើប្រាស់វីដេអូ | • មុនពេលគ្រូបង្ហាញវីដេអូក្នុងថ្នាក់ សូមពិនិត្យមើលឱ្យប្រាកដថាវាមានចំណងជើង<br>• សូមពិនិត្យមើលវីដេអូ មុនពេលចូលរៀន ដើម្បីកុំឱ្យសិស្សមានអារម្មណ៍ឯកោ ប្រសិនបើគ្រូមិនអាចបង្ហាញវីដេអូបានទេ ព្រោះវាមិនមានចំណងជើង |
| ច) ការប្រាប់ពីការផ្លាស់ប្តូរមេរៀន សកម្មភាព និងទីកន្លែង | • ប្រាប់សិស្សពីការផ្លាស់ប្តូរមេរៀន សកម្មភាពដែលត្រូវធ្វើ ឬការផ្លាស់ប្តូរថ្នាក់រៀន ដើម្បីឱ្យសិស្សដឹងពីការផ្លាស់ជាមុន និងប្រាប់ព័ត៌មាននៃការផ្លាស់ប្តូរទៅកាន់សិស្សផ្សេងៗទៀត |
| ឆ) ការជៀសវាងការបង្កើតសញ្ញាក្រៅផ្លូវការ | • គ្រូត្រូវប្រើប្រាស់ភាសាសញ្ញាកម្ពុជា<br>• លើសពីនេះទៀត គ្រូគ្រប់គ្នាដែលធ្វើការជាមួយសិស្សគួរតែប្រើសញ្ញាដូចគ្នាសម្រាប់ពាក្យ និងគោលគំនិតដូចគ្នា<br>• នៅពេលសិស្សប្រកបពាក្យដោយម្រាមដៃ ពួកគេទំនងជាមិនយល់ពាក្យនោះ ហើយត្រូវការជំនួយបន្ថែមជាមួយវា |

### ៩.៣.២ វិធីសាស្ត្រទី២៖ ទំនាក់ទំនងជាមួយមិត្តរួមថ្នាក់

| | |
|---|---|
| ក) ការចាប់ដៃគូសិស្សដើម្បីជួយសិស្ស | • សិស្សនឹងទទួលបានអត្ថប្រយោជន៍ពីមិត្តភក្តិ ដែលពួកគេអាចនិយាយជាមួយគ្នាបានពេញមួយថ្ងៃ<br>• ដៃគូរបស់ពួកគេអាចជួយពង្រឹងភាសាប្រចាំថ្ងៃ និងការលំបាកក្នុងការយល់មេរៀនរបស់សិស្ស |
| ខ) ការលើកទឹកចិត្តសិស្សឱ្យប្រាស្រ័យទាក់ទងជាមួយក្រុមធំ | • ការប្រាស្រ័យទាក់ទងនៅក្នុងក្រុមធំជួយដល់សិស្សទាំងអស់ឱ្យរៀនកាន់តែប្រសើរ<br>• សិស្សខ្លះដែលមិនសូវយល់អាចសុំជំនួយពីគ្រូដើម្បីឱ្យជួយពន្យល់បន្ថែម និងមិត្តរួមថ្នាក់ ឬគ្រូជំនួយនៅក្នុងថ្នាក់ |

### ៩.៣.៣ វិធីសាស្ត្រទី៣៖ ការបង្រៀនភាសា និងការអាន

| | |
|---|---|
| ក) ការរៀនភាសាតាមរយៈការនិទានរឿង | • សិស្សទទួលបាននូវអត្ថប្រយោជន៍តាមរយៈការនិទានរឿង ដោយប្រើភាសាសញ្ញាព្រោះពួកគេអាចមើលឃើញពីរបៀបដែលគ្រូនិទាន ឬពន្យល់សាច់រឿងទាំងមូលរួមបញ្ចូលទាំងកាយវិការផងដែរ<br>• គ្រូអាចលើកទឹកចិត្ត និងណែនាំដល់ឪពុកម្តាយជួយបង្រៀនកូនបន្ថែមនៅផ្ទះ |

| | |
|---|---|
| ខ) ការបំបែកពាក្យទៅជាព្យាង្គ៖ | • ការបំបែកពាក្យទៅជាព្យាង្គអាចជួយសិស្សឱ្យយល់ពីរបៀបនៃការផ្សំពាក្យ ទៅនឹងអត្ថន័យទាំងមូល ហើយគ្រូអាចបង្ហាញព្យាង្គដោយប្រើចង្វាក់ ចលនាមាត់ និងប្រើសញ្ញាលើម្រាមដៃ |
| គ) ការប្រើវិធីពីរភាសា | • គ្រូបង្រៀនត្រូវជួយសិស្សឱ្យស្ទាត់ជំនាញទាំងភាសាសញ្ញា និងភាសាសរសេរ ដែលជាភាសាពីរផ្សេងគ្នា<br>• សិស្សអាចរៀនភាសាសញ្ញាជាពាក្យ និងសរសេរតាមអ្វីដែលពួកគេបានមើលឃើញ<br>• គ្រូបង្រៀនត្រូវនិយាយស្របគ្នានឹងការបង្ហាញជាភាសាសញ្ញា<br>• គ្រូត្រូវទុកពេលឱ្យសិស្សធ្វើឡើងវិញឱ្យបានច្រើនដង |

## ៩.៨ វិធីបង្រៀនសិស្សពិការសតិបញ្ញា និងអូទីស្សឹម

វិធីសាស្ត្របង្រៀនសិស្សពិការសតិបញ្ញា និងអូទីស្សឹម ពិតជាមានសារៈសំខាន់ណាស់ ទោះបីបរិស្ថាននៃការរៀនសូត្រលំបាកក៏ពិតមែន ក៏កុមារនៅតែអាចរៀនចេះ ព្រមទាំងមានសមត្ថភាពទទួលបាន និងប្រើប្រាស់ព័ត៌មានថ្មីៗផងដែរ តាមរយៈវិធីសាស្ត្របង្រៀនតាមបែបអប់រំបរិយាបន្ន។

| វិធីសាស្ត្របង្រៀនសិស្សពិការសតិបញ្ញា |
|---|
| • បង្ហាញអំពីខ្លឹមសារសំខាន់ៗតាមលំដាប់លំដោយនៃមេរៀនដែលត្រូវរៀន និងបង្រៀនដោយបញ្ជាក់ពីគោលគំនិតសំខាន់ និងផ្តល់ឱកាសសម្រាប់ការអនុវត្តជាក់ស្តែងនូវជំនាញ និងគោលគំនិតថ្មីៗ<br>• ផ្តល់ឯកសារ ឬមេរៀនឱ្យបានច្បាស់លាស់មុនពេលចាប់ផ្តើមបង្រៀនដើម្បីឱ្យពួកគេបានអានជាមុន<br>• ផ្តល់ឯកសារ ឬមេរៀនជាផ្នែកៗ និងណែនាំដល់សិស្សពីរបៀបអានឯកសារ ឬមេរៀនគន្លឹះបានស៊ីជម្រៅប្រសើរជាងពួកគេសិក្សាឯកសារ ឬមេរៀនទូទៅច្រើន<br>• គ្រូត្រូវណែនាំសិស្សឱ្យបានច្បាស់ តាមលំដាប់លំដោយ ទាំងការនិយាយពន្យល់ ការសរសេរ និងការអនុវត្ត។ ឧទាហរណ៍ ពេលធ្វើលំហាត់ ធ្វើពិសោធន៍ ឬប្រើប្រាស់កុំព្យូទ័រ<br>• សិស្សអាចរៀនបានច្រើន និងទទួលបានលទ្ធផលកាន់តែល្អប្រសិនបើមានការប្រើប្រាស់បច្ចេកវិទ្យាជំនួយ<br>• ពិពណ៌នាជាពាក្យសម្តីឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដើម្បីបន្ថែមទៅលើខ្លឹមសារឯកសារ ឬមេរៀននានាដែលបានបង្ហាញនៅលើក្តារខៀន ឬផ្ទាំងរូបភាព<br>• ប្រើភាសាដែលមានលក្ខណៈខ្លីច្បាស់ និងងាយយល់<br>• ពង្រឹងការរៀនសូត្រ ដោយប្រើប្រាស់ឧទាហរណ៍ជាក់ស្តែង និងផ្សារភ្ជាប់ទៅនឹងជីវិតរស់នៅប្រចាំថ្ងៃ<br>• បង្ហាញព័ត៌មានទៅតាមទម្រង់ផ្សេងៗដូចជាឯកសារ សន្លឹកកិច្ចការផ្ទាំងរូបភាព និងវីដេអូដើម្បីឱ្យឆ្លើយតបទៅនឹងរបៀបនៃការរៀនខុសៗគ្នារបស់កុមារ<br>• ប្រើប្រាស់វិធីបង្រៀនផ្សេងៗដើម្បីឱ្យសិស្សទទួលបានព័ត៌មានដោយមិនចាំបាច់តែតាមរយៈការអានតែមួយមុខប៉ុណ្ណោះ មានដូចជាការប្រើប្រាស់ តារាង ដ្យាក្រាម បញ្ជីក្រាប និងគោលគំនិតជាដើម សម្រាប់បង្ហាញខ្លឹមសារមេរៀនដល់សិស្ស |

- រៀបចំដ្យាក្រាមឱ្យមានរបៀបរៀបរយ និងប្រើប្រាស់ពណ៌ដែលសមស្របដើម្បីបង្ហាញពីភាពខុសគ្នា និងបញ្ជាក់ពីចំណុចសំខាន់ៗ
- ត្រូវប្រាកដថា មានបញ្ជីពាក្យបច្ចេកទេសដែលសិស្សចាំបាច់ត្រូវរៀនមុនពេលបង្រៀន
- គ្រូត្រូវមានកំណត់ត្រា និងផែនការជួយសិស្សទាំងឡាយដែលមានបញ្ហាក្នុងការសរសេរ ការស្តាប់ និងការផ្ទង់អារម្មណ៍
- សិស្សអាចចាប់បានខ្លឹមសារមេរៀនត្រឹមត្រូវតាមលំដាប់លំដោយ ប្រសិនបើពួកគេបានអាន និងសិក្សាមេរៀននោះ លើសពី១ដង
- បញ្ជាក់សារឡើងវិញចំពោះឃ្លា និងការណែនាំសំខាន់ៗក្នុងពេលបង្រៀន
- ការបង្រៀនជាលក្ខណៈបុគ្គលមានសារៈសំខាន់ រួមទាំងមិត្តអប់រំមិត្តផងដែរ
- សិស្សអាចផ្តល់ចម្លើយតាមរយៈពាក្យសំដីជាជាងជាលាយលក្ខណ៍អក្សរសម្រាប់កិច្ចការសំណេររបស់ពួកគេ
- ការណែនាំជាលក្ខណៈបុគ្គលមានប្រយោជន៍សម្រាប់សិស្សពិការសតិបញ្ញា និងអូទីស្សឹមអំពីការប្រើឧបករណ៍ក្នុងមន្ទីរពិសោធន៍ឬកុំព្យូទ័រ ដើម្បីកាត់បន្ថយការព្រួយបារម្ភរបស់កុមារ។

## វិធីសាស្ត្របង្រៀនសិស្សពិបាកសិក្សាមុខវិជ្ជា

- ចែកជូនឯកសារ ឬមេរៀនសម្រាប់អានឱ្យបានច្បាស់លាស់មុនពេលចាប់ផ្តើមបង្រៀនដើម្បីឱ្យសិស្សបានអានជាមុន
- ផ្តល់ការណែនាំដល់សិស្សអាននូវចំណុចសំខាន់ៗនៃឯកសារ ឬរៀនប្រសើរជាជាងការអានអត្ថបទទាំងស្រុង
- គ្រូត្រូវណែនាំ ឬពន្យល់សិស្សឱ្យបានច្បាស់អំពីនីតិវិធី និងជំហាននីមួយៗ តាមរយៈការនិយាយ និងការសរសេរ ឧទាហរណ៍នៅពេលធ្វើលំហាត់នៅក្នុងបន្ទប់ពិសោធន៍ ឬធ្វើកិច្ចការនៅក្នុងកុំព្យូទ័រ
- សិស្សអាចទទួលផលប្រយោជន៍ច្រើនពីការប្រើប្រាស់បច្ចេកវិទ្យាជំនួយ
- ប្រើប្រាស់ការពិពណ៌នាជាពាក្យសម្តីឱ្យបានច្រើនតាមដែលអាចធ្វើទៅបានដើម្បីបំពេញបន្ថែមទៅលើខ្លឹមសារឯកសារ ឬមេរៀនដែលបានបង្ហាញនៅលើក្តារខៀន ឬផ្ទាំងរូបភាព។ សិស្សលំបាកក្នុងការសិក្សាមុខវិជ្ជា តែងចូលចិត្តរៀនតាមរយៈការស្តាប់
- បង្ហាញព័ត៌មានទៅតាមទម្រង់ផ្សេងៗដូចជាឯកសារ សន្លឹកកិច្ចការ ផ្ទាំងរូបភាព វីដេអូ ដើម្បីឱ្យឆ្លើយតបទៅនឹងរបៀបនៃការរៀនខុសៗគ្នារបស់កុមារ
- ពន្យល់សារឡើងវិញពិតជាមានសារៈសំខាន់ណាស់សម្រាប់សិស្សពិបាកក្នុងការសិក្សាមុខវិជ្ជាដែលគ្រូត្រូវតែរំឭក និងណែនាំពីចំណុចសំខាន់ៗតាមមធ្យោបាយផ្សេងៗ
- បង្រៀនបំប៉នបន្ថែម ជាតម្រូវការចាំបាច់របស់កុមារពិបាកក្នុងការសិក្សាមុខវិជ្ជា
- សិស្សពិបាកក្នុងការសិក្សាមុខវិជ្ជាអាចផ្តល់ចម្លើយតាមរយៈពាក្យសំដីជាជាងលាយលក្ខណ៍អក្សរសម្រាប់កិច្ចការសំណេររបស់ពួកគេ
- កុំធ្វើឱ្យសិស្សមានការបារម្ភពីការធ្វើខុសឆ្គង ការសួរសំណួរ ឬការធ្វើកិច្ចការ ជាដើម

- ណែនាំជាលក្ខណៈបុគ្គលមានប្រយោជន៍សម្រាប់សិស្សពិបាកសិក្សាមុខវិជ្ជាអំពីការប្រើប្រាស់ឧបករណ៍ក្នុងមន្ទីរពិសោធន៍ឬកុំព្យូទ័រ ដើម្បីកាត់បន្ថយការព្រួយបារម្ភរបស់កុមារ

| វិធីសាស្ត្របង្រៀនកុមារអូទីស្សឹម |
|---|
| |

- **កុមារអូទីស្សឹមត្រូវការធ្វើកិច្ចការដែលជាទម្លាប់ដដែលៗ និងមានរបៀបរៀបរយតាមលំដាប់លំដោយ៖** កិច្ចការដែលជាទម្លាប់ដដែលៗ និងមានរបៀបរៀបរយតាមលំដាប់លំដោយប្រៀប បីដូចជាកញ្ចក់មួយសម្រាប់កុមារអូទីស្សឹមដែលមានបញ្ហាពិបាកក្នុងការមើល ឬហាក់បីដូចជា ឧបករណ៍ជំនួយស្ដាប់សម្រាប់កុមារអូទីស្សឹមដែលមានបញ្ហាខ្សោយក្នុងការស្ដាប់ វាមានសារៈសំខាន់ណាស់នៅពេលដែលបរិស្ថានសិក្សា និងរបៀបបង្រៀនមានការរៀបចំ និងស៊ីសង្វាក់គ្នាល្អធ្វើឱ្យការសិក្សារបស់កុមារកាន់តែប្រសើរ
- **ការរៀបចំតាមលំដាប់លំដោយនៃពេលវេលាសម្រាប់កុមារអូទីស្សឹម៖**
  - កាលវិភាគប្រចាំថ្ងៃគឺជាឧបករណ៍មួយសម្រាប់ការរៀបចំពេលវេលាសម្រាប់កុមារអូទីស្សឹម
  - គ្រូបង្រៀនត្រូវមានកាលវិភាគប្រចាំថ្ងៃរបស់ខ្លួននៅលើក្ដារខៀន ប៉ុន្តែវាមិនទាន់គ្រប់គ្រាន់ទេសម្រាប់ជួយកុមារអូទីស្សឹម
  - កុមារទាំងនេះភាគច្រើនទាមទារឱ្យមានកម្មវិធីប្រចាំថ្ងៃផ្ទាល់ខ្លួនដោយមានលក្ខណៈលម្អិត
  - ជាទូទៅពួកគេត្រូវការការវិភាគខ្លីៗសម្រាប់រយៈពេលជាក់លាក់
- **ការរៀបចំទីកន្លែងសម្រាប់កុមារអូទីស្សឹម៖**
  - កុមារអូទីស្សឹមអាចរៀនបានប្រសើរនៅក្នុងថ្នាក់ដែលមានការរៀបចំតុបតែង និងកំណត់ទីកន្លែងឱ្យបានច្បាស់លាស់ដោយបិតសញ្ញាសម្គាល់លើគ្រឿងសង្ហារឹម សម្ភារៈ និងកម្រាល
  - គ្រូត្រូវរៀបចំឱ្យមានកន្លែងសម្រាប់សិស្សធ្វើកិច្ចការជាបុគ្គល ដៃគូ និងក្រុម
  - គ្រូត្រូវរៀបចំកិច្ចការសិស្សដាក់តាមប្រភេទ និងទីកន្លែងដាច់ពីគ្នាចំពោះកិច្ចការដែលត្រូវធ្វើ និងកិច្ចការដែលបានធ្វើរួចហើយ
- **រៀបចំកុមារអូទីស្សឹមឱ្យផ្លាស់ប្ដូរទម្លាប់ប្រចាំថ្ងៃ ទោះបីជាការរៀបចំថ្នាក់រៀនភាគច្រើនពុំមានការផ្លាស់ប្ដូរក៏ដោយ ក៏ប៉ុន្តែកាលវិភាគត្រូវតែមានការផ្លាស់ប្ដូរជានិច្ច**
- **គ្រូត្រូវគិតពីព្រឹត្តិការណ៍ទាំងអស់ដែលអាចកើតមាន ហើយដែលអាចប៉ះពាល់ទៅលើសកម្មភាពប្រចាំថ្ងៃនៅក្នុងថ្នាក់រៀន ឧទាហរណ៍៖ ការប្រមូលផ្ដុំគ្នា និងការប្រកាសអាសន្នពេលមានអគ្គីភ័យ វាតែងតែបង្កឱ្យមានភាពភ័យខ្លាចសម្រាប់កុមារអូទីស្សឹម**
- **ប្រើប្រាស់កាលវិភាគប្រចាំថ្ងៃ ឬការបង្កើតជាសាច់រឿងនិទានបែបសង្គមអាចមានប្រយោជន៍ក្នុងការកាត់បន្ថយភាពភ័យខ្លាចរបស់កុមារអូទីស្សឹម**
- **កុមារអូទីស្សឹមមានការលំបាកក្នុងការយល់ភាសា៖**
  - ការលំបាកផ្នែកភាសាគឺជាសញ្ញាសម្គាល់របស់កុមារអូទីស្សឹម
  - កុមារអូទីស្សឹមមានការលំបាកក្នុងការយល់ពាក្យពេចន៍ដែលវែង
  - គ្រូផ្ដល់ការណែនាំមួយ ឬពីរចំណុចម្ដងច្បាស់ៗ និងសាមញ្ញ
  - កុមារលំបាកខ្លាំង បើសិនជាគ្រូផ្ដល់ការណែនាំច្រើនដងក្នុងពេលតែមួយ

- ជាធម្មតា បរិមាណព័ត៌មានដែលគេអាចវិភាគបានមានលក្ខណៈខុសគ្នាពីកុមារម្នាក់ទៅកុមារម្នាក់ទៀត ប៉ុន្តែចូរចងចាំថាកុមារអូទីស្សឹមមានការលំបាកក្នុងការវិភាគភាសានិយាយ

- **កុមារអូទីស្សឹមប្រើចក្ខុវិញ្ញាណក្នុងការយល់ភាសា៖**
  - ទោះបីជាផ្នែកភាសារបស់ខួរក្បាលទទួលរងផលប៉ះពាល់ក៏ដោយ ក៏ផ្នែកចក្ខុវិញ្ញាណនៅធម្មតា ឬមានករណីជាច្រើនអាចមានការលូតលាស់ល្អទៀតផង
  - កុមារអូទីស្សឹមវិភាគព័ត៌មានតាមរយៈចក្ខុវិញ្ញាណបានល្អប្រសើរជាងតាមការនិយាយផ្ទាល់មាត់
  - ខ្លឹមសារព័ត៌មានត្រូវអមជាមួយការបង្ហាញដោយរូបភាព
- **កុមារអូទីស្សឹមមានការលំបាកក្នុងការយល់ភាសាសញ្ញា៖**
  - គ្រូបង្រៀនត្រូវដឹងពីការអនុញ្ញាត ឬមិនអនុញ្ញាតនៅពេលដែលថ្នាក់រៀនមានការឡូឡាខ្លាំងពេក
  - គ្រូចាំថា សិស្សអូទីស្សឹមទំនងជាមិនយល់ពីការក្រឡេកមើលរបស់គ្រូក្នុងន័យចង់ឱ្យសិស្សរក្សាភាពស្ងៀមស្ងាត់
  - ក្នុងពេលដែលសិស្សផ្សេងយល់ និងឈប់ជជែកគ្នា កុមារអូទីស្សឹមនៅតែបន្តជជែកគ្នា ហើយពេលនោះពួកគេនឹងមានការងឿងឆ្ងល់ថាហេតុអ្វីបានជាពួកគេមានបញ្ហា
  - គ្រូចាំបាច់ត្រូវនិយាយត្រង់ៗប្រាប់កុមារអំពីអ្វីដែលគ្រូចង់ឱ្យគេធ្វើ
- **កុមារអូទីស្សឹមមានការពិបាកក្នុងការយល់ទំនាក់ទំនងសង្គមមនុស្ស៖**
  - ពិបាកយល់ពីគំនិតមនុស្សម្នាក់ផ្សេងទៀត
  - ពួកគេប្រហែលជាមិនយល់ថាតើយោបល់ ឬសកម្មភាពអាចប៉ះពាល់ទៅលើអារម្មណ៍របស់អ្នកដទៃយ៉ាងដូចម្ដេចទេ
  - បង្រៀនបំណិនផ្នែកសង្គមដល់កុមារអូទីស្សឹម ដូចជា ការស្វាគមន៍ ការប្តូរវេនរង់ចាំ និងការចែករំលែកគំនិតយោបល់ជាដើម
- **កុមារអូទីស្សឹមជាទូទៅត្រូវគោរពច្បាប់ទម្លាប់៖**
  - សិស្សអូទីស្សឹមដែលមានសមត្ថភាពខ្ពស់ ជាធម្មតាគ្រូតែងតាំងជាប្រធានថ្នាក់ព្រោះគេជាគំរូល្អក្នុងការពង្រឹងច្បាប់ទម្លាប់ ឬវិន័យដែលតែងតែអនុវត្តតាមជារឿយៗ
  - បើមិនមានការគោរពច្បាប់ទម្លាប់ទេនឹងបង្កឱ្យមានជម្លោះជាមួយមិត្តភក្តិដោយសារកុមារអូទីស្សឹមជាមនុស្សពូកែទូលពិត ( និយាយរអេចរអូច ឬរាយការណ៍ )
- **កុមារអូទីស្សឹមជាច្រើនមានបញ្ហាទាក់ទងនឹងញាណ៖**
  - កុមារអូទីស្សឹមជាច្រើនធាប់មានរំញោចទាក់ទងនឹងការប៉ះ ការមើល ឬការស្តាប់សំឡេង
  - ពួកគេប្រហែលជាធាប់បានរំញោច (លើសញ្ញាណ) ចំពោះពន្លឺនៅក្នុងបន្ទប់រៀន ឬកន្លែងផ្សេងៗនៅក្នុងសាលារៀន
  - ញាណដែលទាក់ទងនឹងបញ្ហាខាងលើអាចមានលក្ខណៈធ្ងន់ធ្ងរខ្លាំងដែលបណ្ដាលឱ្យកុមាររគេចេញពីស្ថានភាពទាំងនោះ ឬអាចនឹងបង្កឱ្យមានអាកប្បកិរិយាមិនល្អកាន់តែខ្លាំងឡើងថែមទៀត

- ការព្យាបាលដោយឱ្យកុមារអូទីស្សឹមធ្វើសកម្មភាពនៅក្នុងសាលារៀនអាចមានប្រយោជន៍ក្នុងការកំណត់ពីគន្លឹះនានាដែលទាក់ទងនឹងញាណរបស់ពួកគេ
    - ឪពុកម្តាយរបស់កុមារអាចផ្តល់នូវព័ត៌មានសំខាន់ៗ ថាតើកូនរបស់ខ្លួនមានការយល់ឃើញដូចម្តេចចំពោះបរិស្ថានជាក់លាក់នានា
- **កុមារអូទីស្សឹមផ្តោតលើចំណុចលម្អិតជាជាងចំណុចរួម៖**
    - កុមារអូទីស្សឹមមានទំនោរផ្តោតទៅលើចំណុចលម្អិតជាក់លាក់ជាជាងទៅលើរូបភាពធំទូលាយ ឧទាហរណ៍ ការពិភាក្សាពីគំនិតសំខាន់ៗរបស់សាច់រឿង វាមានការលំបាកសម្រាប់កុមារ
    - នៅពេលបង្រៀនអក្សរ ឬពាក្យ គឺគ្រាន់តែប្រើបណ្ណអក្សរ ឬបណ្ណពាក្យធម្មតាដោយមិនចាំបាច់មានស៊ុមក្បាច់ក្បូររចនាព័ទ្ធជុំវិញទេ
- **កុមារអូទីស្សឹមមានការលំបាកយ៉ាងខ្លាំងក្នុងការវិភាគព័ត៌មានទូទៅ៖**
    - បំណិនក្នុងការរៀនសូត្រនៅក្នុងស្ថានភាពមួយមិនទំនងជាអាចអនុវត្តបាន ដូចនេះគ្រូត្រូវបង្រៀនបំណិនច្រើនដែលអាចយកទៅអនុវត្តបាន ដូចជាបំណិនសង្គម ភាសា និងការសិក្សា
- **គ្រូវគិត និងនិយាយត្រង់ៗចំពោះកុមារអូទីស្សឹម៖**
    - ភាសាប្រៀបធៀបដូចជា "ភ្លៀងដូចគេចាក់ទឹក" គឺមិនអាចស្តាប់យល់ទេសម្រាប់កុមារអូទីស្សឹម ដូចនេះគ្រូចាំបាច់ត្រូវបង្រៀនកុមារពីន័យត្រង់របស់ប្រយោគដែលមិត្តរួមថ្នាក់ និងគ្រូប្រើប្រាស់ជាទូទៅដូចជា "ភ្លៀងដូចគេចាក់ទឹក" ទៅជា "ភ្លៀងខ្លាំង" វិញ
- **កុមារអូទីស្សឹមជាទូទៅគឺជាជនរងគ្រោះតាមរយៈការសម្លុតធ្វើបាបពីកុមារដទៃដើម្បីជាការលេងសើចសប្បាយ**
- **កុមារអូទីស្សឹមគឺជាកុមារដែលមានលក្ខណៈពិសេស និងអស្ចារ្យ៖**
    - កុមារអូទីស្សឹមគឺជាប្រភេទកុមារតែមួយគត់ដែលគិត និងយល់ឃើញថាពិភពលោកមានលក្ខណៈដាច់ដោយឡែកជាងកុមារភាគច្រើន

### គោលការណ៍គ្រឹះទាំង៤ ដែលគ្រូបង្រៀនត្រូវចងចាំ

| | |
|---|---|
| ពីងាយទៅពិបាក | ការចាប់ផ្តើមពីជំហានមួយដែលនាំកុមារឆ្ពោះទៅរកភាពជោគជ័យ គឺការលើកទឹកចិត្តឱ្យកុមារខំប្រឹងរៀនបន្ថែមទៀត។ គ្រូបង្រៀនត្រូវជៀសវាងការកំណត់គោលដៅខ្ពស់ពេកសម្រាប់កុមារ។ នៅពេលដែលកុមាររៀនពីជំហានសាមញ្ញៗ ហើយត្រូវណែនាំពី ជំហានដែលមានលក្ខណៈស្មុគស្មាញ ឬពិបាកៗ បន្តិចម្តងៗ។ ឧទាហរណ៍ នៅពេលបង្រៀន ពីរបៀបដុសធ្មេញ ត្រូវចាប់ផ្តើមពីធ្មេញមុខហើយបន្តយឺតៗទៅធ្មេញនៅផ្នែកម្ខាងទៀត និងបន្ទាប់មកទៅធ្មេញផ្នែកខាងក្នុង។ |
| ពីអ្វីដែលដឹងទៅអ្វីដែលមិនធ្លាប់ដឹង | ចំណេះដឹងមានស្រាប់របស់កុមារជាចំណុចចាប់ផ្តើមសម្រាប់ការបង្រៀនបំណិនផ្សេងៗ ឧទាហណ៍ គ្រូបង្រៀនត្រូវបង្រៀនកុមារ ឱ្យអានពាក្យ "ឆ្កែ" ត្រូវចាប់ផ្តើមដោយការសម្គាល់រូបភាពរបស់សត្វឆ្កែដោយផ្ទួរផ្គងជាមួយពាក្យ "ឆ្កែ" ហើយបន្ទាប់មកឱ្យមានកុមាររកពាក្យដែលសរសេរថា "ឆ្កែ" ដោយធ្វើការជ្រើសរើសក្នុងចំណោមពាក្យពីរ និងច្រើនជាងពីរ។ |
| ពីរូបីទៅអរូបី | កុមារមានការលំបាកក្នុងការធ្វើតាមគោលគំនិតអរូបី។ ការបង្រៀនត្រូវមានឧទាហរណ៍ជាក់ស្តែងអមជាមួយ។ ឧទាហរណ៍ដើម្បីឱ្យកុមារយល់ពីគោលគំនិតរបស់ "ថ្ងៃអាទិត្យ" ដែលមានលក្ខណៈអរូបី សូមភ្ជាប់ជាមួយសកម្មភាពផ្សេងៗដែលគេធ្វើនៅថ្ងៃអាទិត្យ ដូចជា "ប៉ាមិនទៅធ្វើការទេ" ដូច្នេះកូននឹងមិនចាំបាច់ទៅសាលារៀនដែរ។ |
| ពីចំណុចរួមទៅជាចំណុចជាក់លាក់ | គោលគំនិតនៃការបង្រៀន គ្រូត្រូវតែណែនាំជារួមសិន។ ឧទាហរណ៍មុនពេលបង្រៀនពីផ្នែកផ្សេងៗនៃរាងកាយរបស់មនុស្ស គ្រូបង្រៀនត្រូវណែនាំពីរាងកាយទាំងមូលជាមុនសិន "នេះគឺជាមនុស្ស" "នេះគឺជាភ្នែករបស់គាត់"។ល។ ដូចគ្នានេះដែរគ្រូបង្រៀនត្រូវតែបង្ហាញពាក្យទាំងមូលសិនមុនពេលបង្ហាញអក្សរផ្សេងៗ ដែលផ្សំបានជាពាក្យដែលត្រូវបង្រៀន (ករណីបង្រៀនអំពីវាក្យសព្ទ ការញែកព្យាង្គ និងសូររបស់ពាក្យ)។ |

### ៩.៨ ការផលិតសម្ភារៈបង្រៀន និងរៀន

សម្ភារៈបង្រៀន និងរៀនជាផ្នែកមួយដ៏សំខាន់ដែលអាចជួយដោះស្រាយលើតម្រូវការសិក្សាពិសេសស្របតាមកម្រិតពិការភាពរបស់សិស្ស។ ដើម្បីជាជំនួយដល់ប្រសិទ្ធភាពនៃកាបង្រៀន និងរៀនសម្រាប់សិស្សមានពិការភាព លោកគ្រូអ្នកគ្រូក៏ត្រូវចេះផលិតសម្ភារៈងាយៗផងដែរ ហើយវិធីដ៏ល្អបំផុតក្នុងការអភិវឌ្ឍសម្ភារៈបង្រៀនគឺត្រូវចាប់ផ្តើមដោយការពិនិត្យមើលផែនការបណ្តុះបណ្តាល និងធនធានដែលមានស្រាប់ដូចជា សៀវភៅការងារ សៀវភៅណែនាំ បណ្តុះបណ្តាល បណ្តុំរូបភាពផ្អែកលើមេរៀនជាក់ស្តែងជាក្រដាស ឬនៅក្នុងកុំព្យូទ័រ ឬប្រព័ន្ធអនឡាញក្តី និងជំនួយផ្នែកសោតទស្សន៍។

សម្ភារៈបង្រៀន និងរៀន

| ពិបាកក្នុងការមើល | ពិបាកក្នុងការស្ដាប់ | ពិការសតិបញ្ញា និងអូទីស្សឹម |
|---|---|---|
| • រូបភាពផុសសម្រាប់សិស្សប៉ះស្ទាប<br>• អក្សរប្រៃយ៍បិទលើរូបភាព<br>• សម្រាប់សិស្សខ្សោយគំហើញមានពណ៌ឆ្អាស់ (ខៀវ លឿង ក្រហម)<br>• វត្ថុពិតជាក់ស្ដែង (ឆ្នាំង ចាន កែវ)<br>• រូបតំណាងសត្វ រុក្ខជាតិ បន្លែ និងផ្លែឈើជាដើម | • សម្ភារៈរូបី (វត្ថុជាក់ស្ដែង)<br>• សម្ភារៈពាក់កណ្ដាលរូបីមានរូបភាពតំណាងសត្វ រុក្ខជាតិ និងបន្លែផ្លែឈើជាដើម<br>• សម្ភារៈរូបី មានបណ្ណពាក្យ បណ្ណលេខ និងបណ្ណល្បះ | • កាលវិភាគរូបភាពអំពីសកម្មភាពប្រចាំថ្ងៃ<br>• បណ្ណរូបភាព<br>• បណ្ណព្យញ្ជនៈ<br>• បណ្ណស្រៈ |

## ៩.៦ ការប្រើប្រាស់សម្ភារៈការបង្រៀន និងរៀនតាមប្រព័ន្ធឌីជីថល

ការបង្រៀនសិស្សតម្រូវឱ្យប្រើប្រាស់សម្ភារៈបង្រៀនដើម្បីបំពេញតម្រូវការរៀនសូត្ររបស់ពួកគេ ព្រោះសម្ភារៈបង្រៀន និងរៀនអាចផ្ដល់ជាបទពិសោធន៍ដ៏មានអត្ថន័យ និងឱ្យសិស្សរៀនបានល្អបំផុតតាមរយៈការយល់ដឹងដោយផ្ទាល់អំពីអ្វីមួយ ហើយមិនមែនគ្រាន់តែជាការពន្យល់ដោយពាក្យសំដី ឬភាសាសញ្ញាប៉ុណ្ណោះទេ។

- គ្រូបង្រៀនប្រើកម្រងវីដេអូមេរៀនបន្ស៊ីគ្នាទៅនឹងចំណងជើងមេរៀន
- គ្រូបង្រៀនប្រើប្រាស់រូបភាព ឬសញ្ញាសម្គាល់ណាដូចជាបណ្ណពាក្យ បណ្ណស្រៈ និងបណ្ណរូបភាព ដែលមាននៅក្នុងទូរស័ព្ទ ឬថាប់ប្លែត
- គ្រូបង្រៀនអាចប្រើម៉ាស៊ីនស្កេនឆ្លាតវៃសម្រាប់ជំនួយដល់ការរៀនអាន
- គ្រូបង្រៀនលើកទឹកចិត្តឱ្យប្រើឧបករណ៍ពង្រីកទំព័រ

សម្ភារៈឌីជីថល

| សិស្សពិបាកក្នុងការមើល | សិស្សពិបាកក្នុងការស្ដាប់ | សិស្សពិការសតិបញ្ញា និងអូទីស្សឹម |
|---|---|---|
| • ខ្សែអាត់សំឡេង<br>• ម៉ាស៊ីនបោះពុម្ពអក្សរប្រៃយ៍<br>• កុំព្យូទ័រកម្មវិធី Jaw សម្រាប់សិស្សពិការភ្នែក<br>• ម៉ាស៊ីនពង្រីកអក្សរ<br>• ទូរស័ព្ទ/ថាប់ប្លែត/ទូរទស្សន៍ ឆ្លាតវៃ<br>• អង្គចងចាំសម្រាប់ផ្ទុកឯកសារសម្ភារៈបង្រៀន និងរៀន | • ទូរស័ព្ទ/ថាប់ប្លែត/ទូរទស្សន៍ ឆ្លាតវៃ<br>• ស្លាយបញ្ចាំងរូបភាព និងខ្សែវីដេអូ<br>• អង្គចងចាំសម្រាប់ផ្ទុកឯកសារសម្ភារៈបង្រៀន និងរៀន | • ទូរស័ព្ទ/ថាប់ប្លែត/ទូរទស្សន៍ឆ្លាតវៃ |

# មេរៀនទី១០៖ តេស្តវាយតម្លៃការសិក្សា

## វត្ថុបំណង

ក្នុងមេរៀននេះ បង្ហាញអំពីកំណត់ត្រាភាពខុសគ្នាក្នុងកម្រងភារកិច្ចអនុរក្សតេស្ត និងប្រាប់អំពីខ្លឹមសារដែលមានក្នុងឧបករណ៍តេស្តវង្វាយតម្លៃអំណាន។

## ខ្លឹមសារ

### ១០.១ តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងតាមដំណាក់

នីតិវិធីនៃការអនុវត្តតេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងតាមដំណាក់ ដែលជាមូលដ្ឋានក្នុងការកែលម្អការបង្រៀន និងរៀនទាន់ពេលវេលា នៅកម្រិតបឋមសិក្សា តាមគ្រឹះស្ថានសិក្សាអប់រំពិសេសសាធារណៈ ដូចខាងក្រោម៖

- គាំទ្រ និងជំរុញការអនុវត្តតេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងតាមដំណាក់ ប្រចាំខែ ត្រីមាស និងឆមាស ឱ្យបានទៀងទាត់
- ផ្សព្វផ្សាយផែនការធ្វើតេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងតាមដំណាក់ឱ្យបានច្បាស់លាស់ និងទូលំទូលាយ
- ប្រើប្រាស់ថវិកាដំណើរការសាសារៀន ដើម្បីជួយគាំទ្រដល់ការរៀបចំអនុវត្ត និងគ្រប់គ្រងដំណើរការតេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងតាមដំណាក់
- រៀបចំសន្លឹកកិច្ចការ និងឧបករណ៍តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងតាមដំណាក់ ឱ្យបានរួចរាល់មុនថ្ងៃធ្វើតេស្ត
- អនុវត្តតេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងតាមដំណាក់ ទៅតាមការណែនាំដែលមាននៅក្នុងឧបករណ៍តេស្តវង្វាយតម្លៃដោយត្រូវធ្វើតេស្តសិស្សម្តងម្នាក់ៗក្នុង រយៈពេលចន្លោះ៣០ ទៅ៤០នាទី
- វិភាគលទ្ធផលតេស្ត តាមកិច្ចការវងនីមួយៗរបស់សិស្សម្នាក់ៗ តាមកម្រិតថ្នាក់
- បូកសរុប និងផ្សព្វផ្សាយលទ្ធផលតេស្តវង្វាយតម្លៃ នៅរាល់ការប្រជុំប្រចាំខែ
- ប្រើប្រាស់លទ្ធផលតេស្តវង្វាយតម្លៃ ជាមូលដ្ឋានដើម្បីកែលម្អការបង្រៀន និងរៀន និងរៀបចំផែនការសាលារៀន
- រៀបចំ ចងក្រង រក្សាទុកឯកសារ និងលទ្ធផលនៃតេស្តវង្វាយតម្លៃប្រចាំខែ ត្រីមាស ឆមាស ដើម្បីទុកជាភស្តុតាងក្នុងការពិនិត្យតាមដាន និងវាយតម្លៃ
- ពិភាក្សាជាមួយមាតាបិតា និងគ្រូពាក់ព័ន្ធ ដើម្បីកៀរគរធនធាន សម្ភារៈ និងថវិកាបន្ថែម សម្រាប់គាំទ្រដំណើរការតេស្តវង្វាយតម្លៃ និងរៀបចំផែនការសកម្មភាពអន្តរាគមន៍ជួយសិស្ស ជាពិសេសសិស្សរៀនយឺត
- ធ្វើបច្ចុប្បន្នកម្មឧបករណ៍តេស្តវង្វាយតម្លៃអំណានថ្នាក់ដំបូងតាមដំណាក់ ស្របតាមស្ថានភាពជាក់ស្តែងឱ្យឆ្លើយតបនឹងការអប់រំបរិយាបន្ន។

## ១០.២ កិច្ចការរងតេស្តរង្វាយតម្លៃអំណានថ្នាក់ដំបូងតាមដំណាក់

| ថ្នាក់មត្តេយ្យកម្រិតខ្ពស់ | ថ្នាក់ទី១ | ថ្នាក់ទី២ | ថ្នាក់ទី៣ |
|---|---|---|---|
| **កិច្ចការរងទី១៖ ការប្រាប់ពាក្យភាសាសញ្ញាដែលធ្លាប់ស្គាល់** (មិនកំណត់ម៉ោង) ១០វិនាទីធ្វើសញ្ញាបន្តទៀត | **កិច្ចការរងទី១៖ ការប្រាប់ពាក្យភាសាសញ្ញាដែលធ្លាប់ស្គាល់** (មិនកំណត់ម៉ោង) ប្រសិនកុមារមិនអាចប្រាប់បានឈ្មោះសត្វ ឬសកម្មភាពដំបូងក្នុងរយៈពេល១០វិនាទី អ្នកអាចឱ្យតម្រុយម្តង ដោយធ្វើសញ្ញា **មានទៀតទេ?** | **កិច្ចការរងទី១៖ ការប្រាប់ពាក្យភាសាសញ្ញាដែលធ្លាប់ស្គាល់** (មិនកំណត់ម៉ោង) ប្រសិនកុមារមិនអាចប្រាប់បាន ឈ្មោះ ផ្លែឈើ ឬសកម្មភាពដំបូង ក្នុងរយៈពេល១០ វិនាទី អ្នកអាចឱ្យតម្រុយម្តង ដោយធ្វើសញ្ញា **មានទៀតទេ?** | **កិច្ចការរងទី១៖ ការប្រាប់ពាក្យភាសាសញ្ញាដែលធ្លាប់ស្គាល់** (មិនកំណត់ម៉ោង) ប្រសិនកុមារមិនអាចប្រាប់បាន ឈ្មោះអាហារចូលចិត្ត ឬសកម្មភាពដំបូងក្នុងរយៈពេល១០វិនាទី អ្នកអាចឱ្យតម្រុយម្តង ដោយធ្វើសញ្ញា **មានទៀតទេ?** |
| **កិច្ចការរងទី២៖ ការកំណត់ពាក្យភាសាសញ្ញាតំណាងរូបភាព** (៤៥វិនាទី)១៥វិនាទីធ្វើសញ្ញាបន្តទៀត<br>• ៣ពាក្យជាភាសាសញ្ញា | **កិច្ចការរងទី២៖ ការកំណត់ពាក្យភាសាសញ្ញាតំណាងរូបភាព** (៦០វិនាទី) ប្រសិនបើសិស្សមិនអាចឆ្លើយបានក្នុងរយៈពេល១០វិនាទី បន្ទាប់ពីអនុរក្សតេស្តធ្វើសញ្ញាបង្ហាញពាក្យនីមួយៗរួចរាល់ អនុរក្សតេស្តត្រូវបើករូបភាពបន្ទាប់ក្នុងសន្លឹកកិច្ចការ<br>• ៥ពាក្យជាភាសាសញ្ញា | **កិច្ចការរងទី២៖ ការកំណត់ពាក្យភាសាសញ្ញាតំណាងរូបភាព** (៨០វិនាទី) ប្រសិនបើសិស្ស មិនអាចឆ្លើយបានក្នុងរយៈពេល៥វិនាទីបន្ទាប់ពីអនុរក្សតេស្តធ្វើសញ្ញាបង្ហាញពាក្យនីមួយៗរួចរាល់ អនុរក្សតេស្តត្រូវបើករូបភាពបន្ទាប់ក្នុងសន្លឹកកិច្ចការ<br>• ៨ពាក្យជាភាសាសញ្ញា | **កិច្ចការរងទី២៖ ការកំណត់ពាក្យភាសាសញ្ញាតំណាងរូបភាព** (១២០វិនាទី) ប្រសិនបើសិស្សមិនអាចឆ្លើយបានក្នុងរយៈពេល៥វិនាទី បន្ទាប់ពីអនុរក្សតេស្តធ្វើសញ្ញាបង្ហាញពាក្យនីមួយៗរួចរាល់ អនុរក្សតេស្តត្រូវបើករូបភាពបន្ទាប់ក្នុងសន្លឹកកិច្ចការ<br>• ១០ពាក្យជាភាសាសញ្ញា |
| **កិច្ចការរងទី៣៖ ការកំណត់រូបភាពជាពាក្យភាសាសញ្ញា** (មិនកំណត់ម៉ោង) ១០វិនាទី ចង្អុលរូបភាពនីមួយៗ<br>• ៥ រូបភាព | **កិច្ចការរងទី៣៖ ការកំណត់រូបភាពជាពាក្យភាសាសញ្ញា** (មិនកំណត់ម៉ោង) ប្រសិនបើសិស្សមិនអាចធ្វើសញ្ញាបានក្នុងរយៈពេល១០វិនាទី បន្ទាប់ពីអនុរក្សតេស្តចង្អុលរូបភាពនីមួយៗរួចរាល់ អនុរក្សតេស្តត្រូវចង្អុលរូបភាពបន្ទាប់ក្នុងសន្លឹកកិច្ចការ<br>• ១០ រូបភាព | **កិច្ចការរងទី៣៖ ការកំណត់រូបភាពជាពាក្យភាសាសញ្ញា** (មិនកំណត់ម៉ោង) ប្រសិនបើសិស្សមិនអាចធ្វើសញ្ញាបានក្នុងរយៈពេល១០វិនាទី បន្ទាប់ពីអនុរក្សតេស្តចង្អុលរូបភាពនីមួយៗរួចរាល់ អនុរក្សតេស្តត្រូវចង្អុលរូបភាពបន្ទាប់ក្នុងសន្លឹកកិច្ចការ<br>• ១០ រូបភាព | **កិច្ចការរងទី៣៖ ការកំណត់រូបភាពជាពាក្យភាសាសញ្ញា** (មិនកំណត់ម៉ោង) ប្រសិនបើសិស្សមិនអាចធ្វើសញ្ញាបានក្នុងរយៈពេល១០វិនាទី បន្ទាប់ពីអនុរក្សតេស្តចង្អុលរូបភាពនីមួយៗរួចរាល់ អនុរក្សតេស្តត្រូវចង្អុលរូបភាពបន្ទាប់ ក្នុងសន្លឹកកិច្ចការ<br>• ១០ រូបភាព |

| | | | |
|---|---|---|---|
| **កិច្ចការរងទី៤៖ ការអានយល់ន័យ**<br>មិនកំណត់ម៉ោង ស្ទាក់ស្ទើរ ឬឈប់ ក្នុងរយៈពេល ១០ វិនាទីនៅសំណួរ | **កិច្ចការរងទី៤៖ ការអានយល់ន័យ**<br>មិនកំណត់ម៉ោង ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់ក្នុងរយពេល ១០វិនាទី ចំពោះសំណួរណាមួយដែលអនុរក្សតេស្ត អាចធ្វើសញ្ញាសំណួរឡើងវិញ (បានតែម្តងគត់ក្នុងមួយសំណួរ) | **កិច្ចការរងទី៤៖ ការអានយល់ន័យ**<br>មិនកំណត់ម៉ោង ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់ក្នុងរយៈពេល ១០វិនាទីនៅសំណួរណាមួយដែលអនុរក្សតេស្ស អាចធ្វើសញ្ញាសំណួរឡើងវិញ (បានតែម្តងគត់ក្នុងមួយសំណួរ) | **កិច្ចការរងទី៤៖ ការអានយល់ន័យ**<br>មិនកំណត់ម៉ោង ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់ក្នុងរយៈពេល ១០វិនាទីនៅសំណួរណាមួយដែលអនុរក្សតេស្ស អាចធ្វើសញ្ញាសំណួរឡើងវិញ (បានតែម្តងគត់ក្នុងមួយសំណួរ) |
| **កិច្ចការរងទី៥៖ ការកំណត់ឈ្មោះតួអក្សរ**<br>កិច្ចការរងទី៥.១.៖ ការកំណត់ឈ្មោះតួព្យញ្ជនៈ<br>⏱ មិនកំណត់ម៉ោង ក្នុងរយៈពេល ៨ វិនាទីសូមចង្អុលតួអក្សរបន្ទាប់<br>• ១០ (ព្យញ្ជនៈ) | **កិច្ចការរងទី៥៖ ការកំណត់ឈ្មោះតួអក្សរ**<br>កិច្ចការរងទី៥.១.៖ ការកំណត់ឈ្មោះតួព្យញ្ជនៈ<br>⏱(១៤៥វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅតួអក្សរណាមួយ ក្នុងរយៈពេល ៥វិនាទីសូមចង្អុលតួអក្សរបន្ទាប់ ហើយធ្វើសញ្ញា "**ទៅមុខទៀត**"<br>• ២៩ (ព្យញ្ជនៈ) | **កិច្ចការរងទី៥៖ ការកំណត់ឈ្មោះតួអក្សរ**<br>កិច្ចការរងទី៥.១៖ ការកំណត់ឈ្មោះព្យញ្ជនៈ<br>⏱(១៤៥ វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅតួអក្សរណាមួយ ក្នុងរយៈពេល ៥ វិនាទីសូមចង្អុលតួអក្សរបន្ទាប់ ហើយធ្វើសញ្ញា "ទៅមុខទៀត"<br>• ២៩ (ព្យញ្ជនៈ) | **កិច្ចការរងទី៥៖ ការកំណត់ឈ្មោះតួអក្សរ**<br>កិច្ចការរង ទី៥.១៖ ការកំណត់ឈ្មោះព្យញ្ជនៈ<br>⏱(១៦៥វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅតួអក្សរណាមួយ ក្នុងរយៈពេល ៥វិនាទីសូមចង្អុលតួអក្សរបន្ទាប់ ហើយធ្វើសញ្ញា "**ទៅមុខទៀត**"<br>• ៣៣ (ព្យញ្ជនៈ) |
| កិច្ចការរងទី៥.២៖<br>ការកំណត់ឈ្មោះស្រៈនិស្ស័យ<br>⏱ មិនកំណត់ម៉ោង ក្នុងរយៈពេល ៨ វិនាទីសូមចង្អុលតួអក្សរបន្ទាប់<br>• ៥ស្រៈ | កិច្ចការរងទី៥.២៖<br>ការកំណត់ឈ្មោះជើងព្យញ្ជនៈ<br>⏱(១៣៥វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅជើងព្យញ្ជនៈណាមួយ ក្នុងរយៈពេល ៥ វិនាទីសូមចង្អុលជើងព្យញ្ជនៈបន្ទាប់ ហើយធ្វើសញ្ញា "ទៅមុខទៀត"<br>• ២៧ ជើងព្យញ្ជនៈ | កិច្ចការរងទី៥.២៖<br>ការកំណត់ឈ្មោះជើងព្យញ្ជនៈ<br>⏱(១៣៥វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅជើងព្យញ្ជនៈណាមួយ ក្នុងរយៈពេល ៥ វិនាទីសូមចង្អុលជើងព្យញ្ជនៈបន្ទាប់ ហើយធ្វើសញ្ញា "ទៅមុខទៀត"<br>• ២៧ ជើងព្យញ្ជនៈ | កិច្ចការរងទី៥.២៖<br>ការកំណត់ឈ្មោះជើងព្យញ្ជនៈ<br>⏱(១៣៥វិនាទី) ប្រសិនបើសិស្សស្ទាក់ ស្ទើរ ឬឈប់នៅជើងព្យញ្ជនៈណាមួយ ក្នុងរយៈពេល៥វិនាទីសូមចង្អុលជើងព្យញ្ជនៈបន្ទាប់ ហើយធ្វើសញ្ញា "ទៅមុខទៀត"<br>• ២៧ ជើងព្យញ្ជនៈ |
| | កិច្ចការរងទី៥.៣៖<br>ការកំណត់ឈ្មោះស្រៈនិស្ស័យ<br>⏱(១២០វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅស្រៈនិស្ស័យណាមួយ ក្នុង | កិច្ចការរងទី៥.៣ ៖<br>ការកំណត់ឈ្មោះស្រៈនិស្ស័យ<br>⏱(១២០វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅស្រៈនិស្ស័យណាមួយ ក្នុង | កិច្ចការរងទី៥.៣៖<br>ការកំណត់ឈ្មោះស្រៈនិស្ស័យ<br>⏱(១២០វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់ត្រង់ស្រៈនិស្ស័យណាមួយ |

| | | | |
|---|---|---|---|
| | រយៈពេល ៥ វិនាទី សូមចង្អុលស្រៈនិស្ស័យបន្ទាប់ ហើយធ្វើសញ្ញា ˝ទៅមុខទៀត˝<br>• ២៣ស្រៈ | រយៈពេល ៥ វិនាទី សូមចង្អុល ស្រៈ និស្ស័យបន្ទាប់ ហើយធ្វើសញ្ញា ˝ទៅមុខទៀត˝<br>• ២៣ស្រៈ | ក្នុងរយៈពេល ៥ វិនាទី សូមចង្អុល ស្រៈនិស្ស័យ បន្ទាប់ ហើយធ្វើសញ្ញា ˝ទៅមុខទៀត˝<br>• ២៣ស្រៈ |
| | កិច្ចការរងទី៥.៤៖ ការកំណត់ឈ្មោះស្រៈពេញតួ ⏱(៦៥វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់ត្រង់ស្រៈពេញតួណាមួយ ក្នុងរយៈពេល ៨វិនាទី សូមចង្អុល ស្រៈពេញតួបន្ទាប់ ហើយធ្វើសញ្ញា ˝**ទៅមុខទៀត**˝<br>• ៨ស្រៈពេញតួ | កិច្ចការរងទី៥.៤៖ ការកំណត់ឈ្មោះស្រៈពេញតួ ⏱(១២០វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់ត្រង់ ស្រៈពេញតួណាមួយ ក្នុងរយៈពេល ៨វិនាទី សូមចង្អុល ស្រៈពេញតួបន្ទាប់ ហើយធ្វើសញ្ញា ˝**ទៅមុខទៀត**˝<br>• ១៥ស្រៈពេញតួ | កិច្ចការរងទី៥.៤៖ ការកំណត់ឈ្មោះស្រៈពេញតួ ⏱(១២០វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់ត្រង់ ស្រៈពេញតួណាមួយក្នុងរយៈពេល ៨វិនាទី សូមចង្អុល ស្រៈពេញតួបន្ទាប់ ហើយធ្វើសញ្ញា ˝**ទៅមុខទៀត**˝<br>• ១៥ស្រៈពេញតួ |
| | កិច្ចការរងទី៥.៥៖ ការកំណត់ឈ្មោះសញ្ញាវណ្ណយុត្តិ និងបញ្ចប់ល្បះ ⏱(៣០វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅសញ្ញាវណ្ណយុត្តិ និងបញ្ចប់ល្បះណាមួយ ក្នុងរយៈពេល ៥វិនាទីសូមចង្អុលសញ្ញាវណ្ណយុត្តិ និងបញ្ចប់ល្បះបន្ទាប់ ហើយធ្វើសញ្ញា ˝**ទៅមុខទៀត**˝<br>• ៦សញ្ញាវណ្ណយុត្តិ | កិច្ចការរងទី៥.៥៖ ការកំណត់ឈ្មោះសញ្ញាវណ្ណយុត្តិ និងបញ្ចប់ល្បះ ⏱(៣០វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅសញ្ញាវណ្ណយុត្តិ និងបញ្ចប់ល្បះណាមួយ ក្នុងរយៈពេល ៥វិនាទីសូមចង្អុលសញ្ញាវណ្ណយុត្តិ និងបញ្ចប់ល្បះបន្ទាប់ ហើយធ្វើសញ្ញា ˝**ទៅមុខទៀត**˝<br>• ៦សញ្ញាវណ្ណយុត្តិ | កិច្ចការរងទី៥.៥៖ ការកំណត់ឈ្មោះសញ្ញាវណ្ណយុត្តិ និងបញ្ចប់ល្បះ ⏱(៣០វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅសញ្ញាវណ្ណយុត្តិ និងបញ្ចប់ល្បះណាមួយ ក្នុងរយៈពេល ៥ វិនាទីសូមចង្អុលសញ្ញាវណ្ណយុត្តិ និងបញ្ចប់ល្បះបន្ទាប់ ហើយធ្វើសញ្ញា ˝**ទៅមុខទៀត**˝<br>• ៨សញ្ញាវណ្ណយុត្តិ |
| | **កិច្ចការរងទី៦៖ ការប្រកបដោយប្រើម្រាមដៃ** ⏱(១៦០វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់ត្រង់ពាក្យណាមួយក្នុងរយៈពេល ១០ វិនាទី សូមចង្អុលពាក្យបន្ទាប់ហើយនិយាយថា «**ទៅមុខទៀត**» | **កិច្ចការរងទី៦៖ ការប្រកបដោយប្រើម្រាមដៃ** ⏱(២០០វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់ត្រង់ពាក្យណាមួយក្នុងរយៈពេល១០ វិនាទី សូមចង្អុលពាក្យបន្ទាប់ហើយនិយាយថា «**ទៅមុខទៀត**» | **កិច្ចការរងទី៦៖ ការប្រកបដោយប្រើម្រាមដៃ** ⏱(១២០វិនាទី) ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់ត្រង់ពាក្យណាមួយក្នុងរយៈពេល ១០ វិនាទី សូមចង្អុលពាក្យបន្ទាប់ហើយនិយាយថា «**ទៅមុខទៀត**» |

| | | | |
|---|---|---|---|
| | ៦.១.ពាក្យព្យញ្ជនៈផ្សំស្រៈ ៥ពាក្យ (៥០វិនាទី)<br>៦.២.ពាក្យប្រកប ៥ ពាក្យ (៥០វិនាទី)<br>៦.៣.ពាក្យផ្ញើជើង ៣ពាក្យ (៣០ វិនាទី)<br>៦.៤.ពាក្យព្យាង្គតម្រួត ៣ពាក្យ (៣០វិនាទី)<br>សរុប១៦ពាក្យ | ៦.១.ពាក្យព្យញ្ជនៈផ្សំស្រៈ ៥ពាក្យ (៥០វិនាទី)<br>៦.២.ពាក្យប្រកប ៥ ពាក្យ (៥០វិនាទី)<br>៦.៣.ពាក្យផ្ញើជើង ៥ពាក្យ (៥០វិនាទី)<br>៦.៤.ពាក្យព្យាង្គតម្រួត ៥ពាក្យ (៥០វិនាទី)<br>សរុប២០ពាក្យ | ៦.១.ពាក្យព្យញ្ជនៈផ្សំស្រៈ ៥ពាក្យ (៥០វិនាទី)<br>៦.២.ពាក្យប្រកប ៥ ពាក្យ (៥០វិនាទី)<br>៦.៣.ពាក្យផ្ញើជើង ៥ពាក្យ (៥០វិនាទី)<br>៦.៤.ពាក្យព្យាង្គតម្រួត ៥ពាក្យ (៥០វិនាទី)<br>សរុប ២០ពាក្យ |
| | **កិច្ចការវង់ទី៧៖ ការអានស្ទាត់** ⏱(១២០វិនាទី)<br>រយៈពេល១០វិទាទីប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅពាក្យណាមួយ ក្នុងរយៈពេល ១០វិនាទី សូមចង្អុលពាក្យបន្ទាប់ហើយនិយាយថា «**ទៅមុខទៀត**» | **កិច្ចការវង់ទី៧៖ ការអានស្ទាត់** ⏱(១២០វិនាទី)<br>ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់នៅពាក្យណាមួយ ក្នុងរយៈពេល១០វិនាទី សូមចង្អុលពាក្យបន្ទាប់ ហើយនិយាយថា «**ទៅមុខទៀត**» | **កិច្ចការវង់ទី៧៖ ការអានស្ទាត់** ⏱(១២០វិនាទី)<br>ប្រសិនបើសិស្សស្ទាក់ស្ទើរ ឬឈប់ត្រង់ពាក្យណាមួយ ក្នុងរយៈពេល ១០ វិនាទី សូមចង្អុលពាក្យបន្ទាប់ ហើយនិយាយថា «**ទៅមុខទៀត**» |

# មេរៀនទី១១៖ ផែនការជួយសិស្សជាបុគ្គល

## ខ្លឹមសារ

## វត្ថុបំណង

នៅក្នុងមេរៀននេះបង្ហាញអំពី ការស្វែងយល់ពីតម្រូវការរបស់សិស្ស និងប្រាប់អំពីការរៀបចំផែនការជួយសិស្សជាបុគ្គល និងការអនុវត្តផែនការជួយសិស្សជាបុគ្គល។

## ខ្លឹមសារ

### ១១.១ ការស្វែងយល់អំពីតម្រូវការរបស់សិស្ស

ដើម្បីឱ្យផែនការទទួលបានជោគជ័យ គ្រូបង្រៀនគួរគប្បីចេះស្វែងយល់ និងពិពណ៌នាឱ្យបានច្បាស់លាស់អំពីការលំបាករបស់សិស្សដែលបានជួបប្រទះទាំងនៅផ្ទះ និងនៅសាលារៀន រួចលើកផែនការសកម្មភាពដើម្បីដោះស្រាយរាល់ការលំបាកទាំងនេះដោយរៀបចំគម្រោងពេលវេលា ទិសដៅផ្សារភ្ជាប់ទៅនឹងសកម្មភាពឱ្យបានជាក់លាក់ និងធ្វើការវាយតម្លៃផែនការសកម្មភាពឱ្យបានច្បាស់លាស់។

គ្រូគួរចងចាំថា ផែនការអប់រំសិស្សជាបុគ្គលជាការបំពេញបន្ថែមលើកិច្ចតែងការបង្រៀនសម្រាប់សិស្សទាំងអស់នៅក្នុងថ្នាក់រៀន។ ផែនការអប់រំសិស្សជាបុគ្គលជួយកំណត់បានអំពីវិធីជួយឱ្យបានសមស្រប តាមសមត្ថភាព និងតម្រូវការ។

### ១១.២ ការរៀបចំផែនការជួយសិស្សជាបុគ្គល

គ្រូប្រចាំថ្នាក់ គប្បីធ្វើការកំណត់អត្តសញ្ញាណសិស្ស និងប្រមូលចងក្រងព័ត៌មានទាំងនេះឱ្យបានច្បាស់លាស់ និងប្រាកដពីការលំបាកនៅក្នុងថ្នាក់រៀនចំពោះសិស្សប្រភេទនេះ ដោយត្រូវបញ្ជាក់ពីឈ្មោះ ភេទ អាយុ ប្រភេទពិការ មូលហេតុពិការ និងថ្នាក់រៀនរបស់សិស្សនោះ ដើម្បីផ្តល់ភាពងាយស្រួលដែលពាក់ព័ន្ធនឹងការផ្តល់សេវាផ្សេងៗក្នុងករណីចាំបាច់។ មិនតែប៉ុណ្ណោះ គ្រូត្រូវរៀបរាប់ពីការលំបាកឱ្យច្បាស់លាស់ គឺស្រង់ចេញពីអត្តបទព័ត៌មានរបស់សិស្សនោះថាតើគេមានការលំបាកអ្វីខ្លះ ដោយមូលហេតុអ្វី ឬពិការភាពអ្វី ហើយត្រូវការសេវាអ្វី? ចំពោះកាលបរិច្ឆេទវិញជាពេលដែលយើងចាប់ផ្តើមដំណើរការផែនការអប់រំកុមារជាបុគ្គលរួមមាន ថ្ងៃ ខែ ឆ្នាំ។

### ១១.៣ ការអនុវត្តផែនការជួយសិស្សជាបុគ្គល

គោលដៅ គឺជាចំណុចដែលយើងចង់ឱ្យកុមារនោះទៅដល់ ឬលទ្ធផលដែលគេនឹងសម្រេចបានក្រោយពីយើងបានអនុវត្តតាមគម្រោងផែនការអប់រំកុមារជាបុគ្គលនោះរួច។ ផែនការសកម្មភាពជាសកម្មភាពលម្អិតដើម្បីឱ្យសម្រេចគោលដៅខាងលើ រួមជាមួយនឹងកាលបរិច្ឆេទទៅតាមសកម្មភាពទាំងនោះ ដែលត្រូវធ្វើឱ្យសម្រេចនៅពេលណាមួយ។ រីឯការវាយតម្លៃវិញគឺជាលទ្ធផលនៃសកម្មភាពនីមួយៗចំពោះសិស្សនោះតាមរយៈពេលកំណត់ ដើម្បីឱ្យប្រាកដថាតើ មានការប្រែប្រួលអ្វីខ្លះ និងទទួលបានលទ្ធផលសិក្សាយ៉ាងណា។

ខាងក្រោមនេះ គឺជាឧទាហរណ៍អំពីរបៀបធ្វើផែនការជួយសិស្សជាបុគ្គល៖

| ១ - អត្តសញ្ញាណទូទៅ | |
|---|---|
| ការប្រមូលព័ត៌មាន៖ | ប៊ុនធឿន អាយុ ៦ឆ្នាំ គាត់ទើបចូលរៀន ហើយគាត់អង្គុយក្រោយគេបង្អស់តែម្នាក់ឯង នៅពេលគ្រូហៅឡើងក្តារខៀនម្តងៗ គាត់តែងដើរប៉ះទង្គិចតុ និងកៅអីជារឿយៗ។ |

| | |
|---|---|
| | នៅពេលចម្លងអត្ថបទពីក្តារខៀន គាត់ពិតជាមានការលំបាកជាខ្លាំងតែងតែដើរទៅមុខ និងទៅក្រោយដើម្បីចម្លងមេរៀន ហើយនឹងពុំមានសិស្សផ្សេងទៀតអង្គុយក្បែរគាត់នោះទេក្រៅពីគាត់អង្គុយម្នាក់ឯង។ |
| ការកំណត់អត្តសញ្ញាណសិស្ស៖ | ឈ្មោះ៖ ឡូយ ប៊ុនធឿន |
| | អាយុ៖ ៦ឆ្នាំ |
| | ថ្នាក់ទី៖ ១ ‘គ’ |
| ពិពណ៌នាអំពីការលំបាក៖ | ម៉ោងមុខវិជ្ជាភាសាខ្មែរ ប៊ុនធឿន រៀន និងចម្លងមេរៀនមិនទាន់សិស្សផ្សេងទៀតទេ គាត់តែងតែសួរ និងដើរទៅជិតក្តារខៀនមើលអក្សរនៅលើក្តារខៀន។ សរុបសេចក្តីមកគាត់អាចមានការលំបាកក្នុងការមើល។ |
| កាលបរិច្ឆេទ៖ | ១៥ កញ្ញា ២០២៣ |

### ២ - ផែនការសកម្មភាព

| គោលដៅ | ផែនការសកម្មភាព | កាលបរិច្ឆេទចុងក្រោយ | ការវាយតម្លៃ |
|---|---|---|---|
| ពង្រឹងការរៀនអានដល់ ប៊ុនធឿន | ១.ឱ្យប៊ុនធឿនអង្គុយតុមុខគេ | សីហា | គាត់អង្គុយតុមុខគេ និងមានពន្លឺគ្រប់គ្រាន់ |
| | ២.គ្រូសរសេរអក្សរធំៗនៅលើក្តារខៀន | សីហា | គាត់អាចចម្លងអក្សរបាន និងមានឧបសគ្គតិចតួច |
| | ៣.ឱ្យប៊ុនធឿនអង្គុយជិតសិស្សពូកែដើម្បីឱ្យគាត់អាចចម្លងមេរៀនតាម និងជួយបង្រៀនគាត់ | សីហា | គាត់មានមិត្តភក្តិរួមតុចាំជួយបង្រៀនគាត់ និងគាត់អាចចម្លងមេរៀនពីមិត្តភក្តិបាន |
| | ៤.គ្រូប្រាប់ឪពុកម្តាយឱ្យនាំប៊ុនធឿន ទៅពិនិត្យភ្នែក | សីហា ដល់ កញ្ញា | ក្រោយការពិនិត្យភ្នែកគ្រូពេទ្យតម្រូវឱ្យគាត់ប្រើប្រាស់វ៉ែនតាជំនួយគំហើញ |

## <u>សកម្មភាពអន្តរាគមន៍ជួយសិស្ស</u>

| | |
|---|---|
| សកម្មភាពគ្រូជួយសិស្ស | ○ ជួយសិស្សតាមរយៈការសួរសំណួរឱ្យសិស្សឆ្លើយ<br>○ សួរសំណួរស្រដៀងដែលមាននៅក្នុងសន្លឹកកិច្ចការនីមួយៗ<br>○ អាចពន្យល់បន្ថែមនៅពេលដែលសិស្សមានចម្ងល់<br>○ ផ្តល់ជាឧទាហរណ៍គំរូឱ្យបានច្រើន<br>○ ផ្តល់ពេលវេលាគ្រប់គ្រាន់ក្នុងការហ្វឹកហាត់ និងអនុវត្តឱ្យបានច្រើន<br>○ ប្រើប្រាស់សម្ភារៈបង្រៀន និងរៀន ដើម្បីឱ្យសិស្សងាយយល់ និងបង្កើនការចងចាំ |

| | |
|---|---|
| | ○ បង្កើតល្បែងសិក្សាដើម្បីឱ្យសិស្សលេងសប្បាយរីករាយ និងមានការចងចាំមេរៀន ឱ្យស្របតាមទ្រឹស្តីលេងគឺរៀន រៀនគឺលេង<br>○ ប្រើប្រាស់វិធីសាស្ត្រពីរូបី ទៅពាក់កណ្តាលរូបី និងអរូបី។ |
| សកម្មភាពជាដៃគូ | ○ សិស្សពូកែឱ្យអង្គុយជាមួយសិស្សរៀនយឺត និងឱ្យជួយបង្រៀនដល់ពួកគេ<br>○ សិស្សថ្នាក់ធំឱ្យជួយបង្រៀនសិស្សថ្នាក់តូច ដើម្បីបង្កើតជាទម្លាប់ការរៀនល្អ<br>○ ប្រើប្រាស់វិធីសាស្ត្រមិត្តជួយមិត្ត មានទាំងសកម្មភាពជួយក្នុងថ្នាក់ និងក្រៅថ្នាក់<br>○ លើកទឹកចិត្តសិស្សគំរូដែលបានជួយសិស្សរៀនយឺត (អាចជាទស្សនៈកិច្ចសិក្សានៅទីរមនីយដ្ឋានផ្សេងៗ ពាក្យសម្តីលើកទឹកចិត្ត និងរង្វាន់តិចតួច)<br>○ រៀងរាល់ម៉ោងបណ្ណាល័យផ្តល់ឱកាសឱ្យសិស្សធំ ឬសិស្សពូកែជួយបង្រៀនដល់សិស្សរៀនយឺត។ |
| សកម្មភាពស្វ័យសិក្សា | ○ បង្កើតសកម្មភាពឱ្យសិស្សរៀនសូត្រពីគ្នាទៅវិញទៅមក មុនពេលចូលគេងសម្រាប់សិស្សស្នាក់នៅក្នុងសាលាអន្តេវាសិកដ្ឋាន<br>○ ដាក់កិច្ចការផ្ទះសម្រាប់សិស្សស្នាក់នៅផ្ទះផ្ទាល់ខ្លួន<br>○ លើកទឹកចិត្តដល់ឪពុកម្តាយឱ្យជួយបង្រៀនកូនបន្ថែមនៅផ្ទះ។ |

# មេរៀនទី១២៖ បណ្ណាល័យសមស្រប

## ខត្ថុបំណង

នៅក្នុងមេរៀននេះបង្ហាញអំពីទិដ្ឋភាពទូទៅនៃបណ្ណាល័យ ការគ្រប់គ្រង កាលវិភាគ និងប្រាប់អំពីធនធានបណ្ណាល័យ។

## ខ្លឹមសារ

### ១២.១ ទិដ្ឋភាពទូទៅនៃបណ្ណាល័យ

បណ្ណាល័យគឺជាកន្លែងតម្កល់ឯកសារ សម្ភារៈ និងបរិក្ខារ សម្រាប់ធ្វើសកម្មភាពឆ្ពោះទៅរកការអាន និងបង្កើតទម្លាប់មូលដ្ឋាន។ គោលបំណងរួមរបស់បណ្ណាល័យ គឺអភិវឌ្ឍទម្លាប់អានដល់សិស្សានុសិស្ស ជំរុញការចង់ដឹងរបស់កុមារអំពីសៀវភៅ និងលើកទឹកចិត្តសិស្សឱ្យចាប់ផ្តើមស្រឡាញ់ចូលចិត្ត និងថែរក្សាសៀវភៅ។ ក្នុងនេះ បណ្ណាល័យត្រូវមាន សៀវភៅសិក្សាគោល សៀវភៅរឿង សៀវភៅ និងឯកសារនានាជាច្រើនប្រភេទពាក់ព័ន្ធទៅនឹងអក្សរប្រៃយ៍ ភាសាសញ្ញា និងសៀវភៅសកម្មភាពជារូបភាព និងរបស់របរលេងជាច្រើន ហើយសម្បូរបែបសមស្របទៅតាមសមត្ថភាព និងកម្រិតនៃការអានរបស់សិស្សដែលរៀននៅវិទ្យាល័យអប់រំពិសេស។

បណ្ណាល័យមានច្រើនប្រភេទដូចជា បណ្ណាល័យជាអគារ បណ្ណាល័យជាបន្ទប់ បណ្ណាល័យជ្រុងថ្នាក់ បណ្ណាល័យទីចាត់ការ និងបណ្ណាល័យចល័ត ហើយបណ្ណាល័យទាំងអស់នេះត្រូវធានាឱ្យបាននូវដំណើរការប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។ ម៉្យាងវិញទៀតបណ្ណាល័យមិនមែនគ្រាន់តែបង្កើតឡើងមួយរយៈពេលខ្លីហើយបិទទៅវិញនោះទេ ព្រោះនាំឱ្យខាតបង់ពេលវេលា ការប្រឹងប្រែង និងថវិកាសម្រាប់ចំណាយទៅលើការបង្កើត។

ដូច្នេះគ្រូពាក់ព័ន្ធទាំងអស់ចាំបាច់ត្រូវរក្សាតម្លៃបណ្ណាល័យជាសារវន្ត ព្រោះបណ្ណាល័យជួយបណ្តុះទម្លាប់អានដល់សិស្សានុសិស្សគ្រប់ប្រភេទ ហើយទម្លាប់អាននេះគឺកើតឡើងនៅពេលដែលសិស្សអានដោយស្ម័គ្រចិត្ត អានជាញឹកញាប់ និងមានភាពសប្បាយរីករាយជាមួយនឹងការអាន រួមទាំងការអាននៅសាលារៀន នៅផ្ទះ និងនៅទីកន្លែងផ្សេងទៀតផងដែរ។ ជាការរំពឹងទុក សិស្សានុសិស្សនឹងយល់ថា ការអានជាសកម្មភាពគួរឱ្យរំភើប និងមានភាពសប្បាយរីករាយព្រមទាំងយល់នូវអ្វីដែលពួកគេបានអាន ហើយពួកគេនឹងក្លាយជាអ្នកអានដោយមានភាពម្ចាស់ការ។

បណ្ណាល័យដែលល្អត្រូវគិតទៅដល់ភាពធំទូលាយដែលសិស្សមានពិការភាពអាចធ្វើការបំលាស់ទីបាន ហើយគិតដល់ភាពសមស្រប និងចាំបាច់សម្រាប់សិស្សចូលមកអាន និងធ្វើការសិក្សាស្រាវជ្រាវ។ បណ្ណាល័យមិនត្រូវតូចចង្អៀត រឺឯសម្ភារៈ និងឯកសារដែលពុំចាំបាច់មិនត្រូវស្តុកពេញក្នុងបណ្ណាល័យនោះឡើយ។

មិនតែប៉ុណ្ណោះ រៀងរាល់ពេលចេញលេងម្តងៗ សិស្សានុសិស្សជាច្រើនបានធ្វើដំណើរតម្រង់ឆ្ពោះទៅបណ្ណាល័យនៅពេលចេញលេង និងម៉ោងសម្រាប់បណ្ណាល័យដែលបានកំណត់ ហើយពួកគេអាចខ្ចីសៀវភៅយកទៅអាននៅផ្ទះទៀតផង។ នៅក្នុងបណ្ណាល័យដែលមានប្រសិទ្ធភាព សិស្សអាចអានសៀវភៅ និងចូលរួមក្នុងសកម្មភាពអំណាន ក្រោមបរិយាកាសរួសរាយរាក់ទាក់ ការជួយគាំទ្រ និងសុវត្ថិភាពផ្លូវអារម្មណ៍។

### ក) ប្រភេទបណ្ណាល័យ

| | |
|---|---|
| បណ្ណាល័យជាអគារ | អគារត្រូវសមស្របតាមបទដ្ឋានបច្ចេកទេសសំណង់អប់រំ ជាពិសេសអគារបណ្ណាល័យត្រូវមានទំហំយ៉ាងហោចណាស់ ៧ម៉ែត្រ x ៩ម៉ែត្រ ត្រូវមានបំពាក់ដូចជា កម្រាលការ៉ូ ឈើនីវលើជញ្ជាំងសម្រាប់វាយដែកគោលដាក់តាំងស្លាកអប់រំផ្សេងៗ ចម្រឹងបង្អួច និងទ្វាររឹងមាំ។ |
| បណ្ណាល័យជាបន្ទប់ | បន្ទប់បណ្ណាល័យត្រូវសមស្រប រឹងមាំ និងមានសុវត្ថិភាព ហើយបន្ទប់នោះត្រូវមានទំហំ ៧ម៉ែត្រ x ៨ម៉ែត្រ ស្ថិតនៅដើម ឬចុងនៃអគារសិក្សា។ មិនតែប៉ុណ្ណោះត្រូវធានាថា ដំបូលរឹងមាំការពារជ្រាបទឹក ទ្វារបង្អួចមានចម្រឹង លាបថ្នាំជញ្ជាំង ក្រាលការ៉ូ និងបំពាក់ឈើនីវលើជញ្ជាំងសម្រាប់វាយដែកគោលតាំងបង្ហាញស្លាកអប់រំផ្សេងៗ។ |
| បណ្ណាល័យជ្រុងថ្នាក់ | បណ្ណាល័យបែបនេះត្រូវបានរៀបចំធ្វើសង្ហារិមតាំងសៀវភៅនៅខាងក្រោយតុសិស្សនៃថ្នាក់រៀននីមួយៗ និងអនុវត្តសកម្មភាពអំណានជាមួយសិស្សដូចបណ្ណាល័យជាបន្ទប់ ឬអគារផងដែរ។ |

## ១២.២ ការគ្រប់គ្រងបណ្ណាល័យ

បណ្ណាល័យ ត្រូវធានាសុវត្ថិភាព និងស្វាគមន៍ដល់កុមារគ្រប់រូប ដើម្បីឱ្យពួកគេទទួលបានអារម្មណ៍រីករាយក្នុងការចូលអានសៀវភៅក្នុងបណ្ណាល័យ។ គ្រឿងសង្ហារិមត្រូវរៀបចំឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដែលសមស្របសម្រាប់កុមារក្នុងការស្វែងរកសៀវភៅ ធ្វើសកម្មភាពដឹកនាំកុមារទៅរកការអាន និងការការពារសៀវភៅពីការខូចខាតដោយកត្តាធម្មជាតិ មនុស្ស និងសត្វ។

បណ្ណារក្សត្រូវពិនិត្យមើលថា គ្រឿងសង្ហារិមគ្មានជ្រុងស្រួច គ្មានក្បាលវីស ឬក្បាលដែកគោលលៀនចេញមកក្រៅដែលអាចបណ្ដាលឱ្យមានគ្រោះថ្នាក់ដល់កុមារ។ ទីតាំងធ្នើរសៀវភៅត្រូវរៀបចំ ដែលមិននៅចំមុខបង្អួចដើម្បីជៀសវាងសំណើម និងទឹកភ្លៀង ឬមិនចំពន្លឺព្រះអាទិត្យដោយផ្ទាល់ដែលធ្វើឱ្យសន្លឹកសៀវភៅធាប់ខូច ឬផុយស្រួយ។ តុសម្រាប់កុមារអានក៏ត្រូវរៀបចំនៅទីកន្លែងដែលសមស្របដែលកុមារអាចអង្គុយអានសៀវភៅបានស្រួល និងមានពន្លឺ ហើយខ្យល់អាកាសចេញចូលគ្រប់គ្រាន់ផងដែរ។

ម៉្យាងទៀត បណ្ណារក្សត្រូវប្រាកដថា ទ្វារ និងបង្អួច ងាយបិទបើក ងាយដាក់គន្លឹះ និងងាយចាក់សោ ហើយក៏ត្រូវពិនិត្យមើលថា ផ្ទៃបាតនៃកម្រាលបន្ទប់មិនមានការបែកស្រាំ មិនមានរន្ធ ឬខូចខាតផ្នែកខ្លះដែលអាចបង្កគ្រោះថ្នាក់ដល់កុមារ បន្ទប់បណ្ណាល័យត្រូវមានអនាម័យ មានរបៀបរៀបរយ និងសុវត្ថិភាពជាប្រចាំ។

### ក) បញ្ជី និងសៀវភៅកំណត់ត្រាផ្សេងៗ

បណ្ណាល័យត្រូវមានបញ្ជីរដ្ឋបាល និងសៀវភៅកំណត់ត្រាផ្សេងៗ ដូចខាងក្រោម៖

| | |
|---|---|
| បញ្ជីរួម | បញ្ជីសម្រាប់កត់ត្រាឯកសារចូលថ្មីគ្រប់ប្រភេទក្នុងបណ្ណាល័យ ហើយមុននឹងចុះបញ្ជីរួម បណ្ណារក្សគប្បីត្រូវបែងចែកឯកសារ ឬសៀវភៅ ឱ្យដាច់ដោយឡែកពីគ្នារវាងប្រភេទសៀវភៅអក្សរសិល្ប៍ សៀវភៅព័ត៌មាន និងសាមយិកបត្រ (លេខរៀង ថ្ងៃខែឆ្នាំចូល លេខបញ្ជី/វិក្កយបត្រ សរុបចំនួនចំណងជើង និងចំនួនក្បាលសៀវភៅ)។ |
| បញ្ជីសារពើភណ្ឌសៀវភៅ | បញ្ជីកត់ត្រាព័ត៌មានលម្អិតនៃសៀវភៅទាំងអស់ដែលមាននៅក្នុងបណ្ណាល័យ បញ្ជីនេះត្រូវបានប្រើប្រាស់សម្រាប់ជួយបណ្ណារក្សក្នុងការគ្រប់គ្រងសៀវភៅកាន់តែជាក់លាក់ |

| | |
|---|---|
| | និងច្បាស់លាស់ (លេខសារពើភណ្ឌ ថ្ងៃខែឆ្នាំចូល ចំណងជើង ឈ្មោះអ្នកនិពន្ធ គ្រឹះស្ថានបោះពុម្ពផ្សាយ ឆ្នាំបោះពុម្ព លេខកូដសៀវភៅ និងប្រភពផ្ដល់ផ្សេងៗ ឬកម្រិតសៀវភៅ)។ |
| សៀវភៅកំណត់ត្រាសកម្មភាពអំណាន | គ្រូប្រចាំថ្នាក់នីមួយៗត្រូវកត់ត្រាអំពីសកម្មភាពអំណាន ដែលពួកគេបានដឹកនាំក្នុងម៉ោងបណ្ណាល័យ ដើម្បីទុកជាព័ត៌មានអាចជួយគណៈគ្រប់គ្រងសាលាឱ្យដឹងពីសកម្មភាពគ្រូបានធ្វើក្នុងម៉ោងបណ្ណាល័យ (កាលបរិច្ឆេទ ថ្នាក់ ប្រភេទអំណាន ចំណងជើងរឿង (អំណានឮ/អំណានចូលរួម) ចំនួនសិស្សចូលរួម ឈ្មោះគ្រូដឹកនាំ និងហត្ថលេខា)។ |
| សៀវភៅកំណត់ត្រាភ្ញៀវ ឬមន្ត្រីអប់រំចូលទស្សនកិច្ច | សម្រាប់ភ្ញៀវ ឬមន្ត្រីអប់រំបានមកធ្វើទស្សនកិច្ចនៅបណ្ណាល័យហើយបណ្ណារក្សត្រូវជូនសៀវភៅនេះទៅពួកគេដើម្បីកត់ត្រាអំពីចំណាប់អារម្មណ៍ចំពោះការគ្រប់គ្រង និងដំណើរការបណ្ណាល័យ (កាលបរិច្ឆេទ ឈ្មោះ អង្គភាព/ស្ថាប័ន មតិយោបល់ ម៉ោង និងហត្ថលេខា)។ |
| បញ្ជីខ្ចី និងសងសៀវភៅ | សម្រាប់កត់ត្រាសៀវភៅដែលកុមារបានខ្ចីយកទៅអាននៅផ្ទះ នឹងអាចទទួលបានពេលវេលាកាន់តែគ្រប់គ្រាន់សម្រាប់ការអានប្រកបដោយភាពរីករាយ និងជាសកម្មភាពជំរុញបណ្ដុះទម្លាប់អានដល់កុមារ (លេខរៀង ឈ្មោះ ភេទ ថ្នាក់ ចំណងជើងសៀវភៅ លេខសារពើភណ្ឌ កំណត់ត្រាខ្ចី (កាលបរិច្ឆេទ និងហត្ថលេខា) កំណត់ត្រាសង (កាលបរិច្ឆេទ និងហត្ថលេខា) និងផ្សេងៗ។ |

ខ) សមាសភាពនៃប្រសិទ្ធភាពរបស់បណ្ណាល័យ

| | |
|---|---|
| បរិយាកាសអំណាន | - បរិយាកាសអំណានត្រូវបានបង្កើតឡើងដោយមានសម្ភារៈព្រីនរីច ដែលជាទីមេត្រីរបស់កុមារ<br>- ត្រូវមានសៀវភៅ និងសម្ភារៈគ្រប់គ្រាន់ ស្របតាមកម្រិតសមត្ថភាពសិស្ស<br>- ការរៀបចំសៀវភៅត្រូវមានក្បួនខ្នាតត្រឹមត្រូវ<br>- បណ្ណាល័យមិនត្រូវចង្អៀតខ្លាំងដែលបង្កផលលំបាកដល់សិស្សមានពិការភាពចេញ និងចូលអាននោះឡើយ។ |
| គុណភាពសមរម្យនៃសម្ភារៈអំណាន | - មានសៀវភៅរឿង សៀវភៅមានរូបភាពច្រើន និងឯកសារយោងថ្មីៗដែលបានទិញពីបណ្ណាគារ ក៏ដូចជាការបោះពុម្ពបន្ថែម។ |
| ពេលវេលាត្រូវអាន | - មានម៉ោងបណ្ណាល័យផ្លូវការនៅក្នុងកាលវិភាគសាលារៀន ដោយកំណត់យ៉ាងហោចណាស់ ១ម៉ោងសិក្សាក្នុង ១សប្ដាហ៍ សម្រាប់ថ្នាក់នីមួយៗ ដើម្បីឱ្យសិស្សមានពេលវេលាចូលអាន។ |
| ការកសាងសមត្ថភាព | - គណៈគ្រប់គ្រងសាលា បណ្ណារក្ស និងគ្រូបង្រៀន ត្រូវទទួលបានការបណ្ដុះបណ្ដាលតាមរយៈការបណ្ដុះបណ្ដាលផ្ទាល់ ឬពីចម្ងាយ និងការសិក្សាដោយខ្លួនឯង ដើម្បី |

| | |
|---|---|
| | ឱ្យមានបំណិនផ្នែកគ្រប់គ្រងបណ្ណាល័យ និងដឹកនាំសកម្មភាពអំណានកាន់តែប្រសើរ។ |

## គ) បណ្ណាល័យកុមារមេត្រី

ដើម្បីក្លាយជាបណ្ណាល័យកុមារមេត្រី តម្រូវឱ្យមានកត្តាធំៗចំនួនពីរគឺ (១) មានសម្ភារៈគ្រប់គ្រាន់ក្នុងបណ្ណាល័យ (២) អាកប្បកិរិយា និងឥរិយាបថវិជ្ជមានរបស់គ្រូពាក់ព័ន្ធ។

| | |
|---|---|
| លក្ខណៈសម្បត្តិ និងសកម្មភាព | - មានសៀវភៅជាច្រើនប្រភេទសម្រាប់សិស្សដែលសៀវភៅទាំងនោះបានបិទកម្រិតអានច្បាស់លាស់ និងដាក់តាំងបង្ហាញនៅលើធ្នើរ ដើម្បីឱ្យសិស្សងាយស្រួលក្នុងការស្វែងរកសៀវភៅឱ្យត្រូវតាមកម្រិតអានរបស់សិស្សរាប់បញ្ចូលទាំងអក្សរប្រៃយ៍ និងភាសាសញ្ញាផងដែរ<br>- មានសម្ភារៈព្រីនរីច ដែលសិស្សអាចអានបាន និងដាក់តាំងបង្ហាញបានត្រឹមត្រូវ<br>- មានគ្រឿងសង្ហារឹមក្នុងបណ្ណាល័យដែលត្រូវបានរៀបចំយ៉ាងមានរបៀបរៀបរយ ដើម្បីឱ្យសិស្សអាចរកសៀវភៅ និងសម្ភារៈសិក្សាផ្សេងៗបានយ៉ាងងាយស្រួល<br>- មានកន្លែងសម្រាប់សិស្សអានជាបុគ្គល ជាដៃគូ និងជាក្រុម ឬធ្វើការខ្ចីសងសៀវភៅបានងាយស្រួល<br>- មានកាលវិភាគម៉ោងបណ្ណាល័យសម្រាប់ថ្នាក់នីមួយៗ ព្រមទាំងការកំណត់ពេលវេលាសម្រាប់សិស្សអាន និងខ្ចីសៀវភៅ និងដាក់តាំងបង្ហាញក្នុងបណ្ណាល័យសម្រាប់ការអនុវត្តប្រចាំថ្ងៃ<br>- មានគោលការណ៍ណែនាំច្បាស់លាស់អំពីប្រព័ន្ធគ្រប់គ្រង និងប្រើប្រាស់បណ្ណាល័យ ហើយគ្រូប្រចាំថ្នាក់ទាំងអស់ បានដឹកនាំសកម្មភាពនេះជារៀងរាល់ថ្ងៃ<br>- មានបណ្ណារក្សដែលបានទទួលការបណ្តុះបណ្តាល ដើម្បីទទួលខុសត្រូវលើការគ្រប់គ្រងបណ្ណាល័យ<br>- គ្រូទាំងអស់ទទួលបានការបណ្តុះបណ្តាលអំពីរបៀបដឹកនាំសកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ មានគណៈកម្មការគ្រប់គ្រងសាលារៀន និងមាតាបិតាសិស្សដើរតួនាទីយ៉ាងសកម្មក្នុងការទ្រទ្រង់សកម្មភាពបណ្ណាល័យ។ |
| អាកប្បកិរិយា និងឥរិយាបថរបស់គ្រូពាក់ព័ន្ធ | - បណ្ណារក្ស និងគ្រូបង្រៀន ជួយសិស្សរកសៀវភៅទៅតាមកម្រិតអានរបស់ពួកគេដោយធ្វើជាគំរូក្នុងការអាន មានការលើកដាក់សំឡេង បង្ហាញពីអារម្មណ៍រីករាយក្នុងការអាន និងលើកទឹកចិត្តសិស្សឱ្យមានតួនាទីក្នុងការជួយគ្រប់គ្រងបណ្ណាល័យ<br>- គណៈគ្រប់គ្រងសាលារៀន និងមាតាបិតាសិស្ស ជំរុញយ៉ាងសកម្មឱ្យមានការប្រើប្រាស់បណ្ណាល័យ និងគាំទ្រដល់សកម្មភាពគ្រប់គ្រងបណ្ណាល័យជាក់ស្តែងដើម្បីធានាឱ្យបាននូវបរិយាកាសសិក្សាជាវិជ្ជមាននៅក្នុងបណ្ណាល័យ។ |

| | |
|---|---|
| | - គណៈគ្រប់គ្រងសាលារៀន មាតាបិតាសិស្ស បណ្ណារក្ស និងគ្រូបង្រៀន ចូលរួមយ៉ាងសកម្មជាមួយនឹងសហគមន៍ ដើម្បីធានាថា ពួកគេបានយល់ដឹងពីគោលបំណង និងការប្រើប្រាស់បណ្ណាល័យ<br>- គណៈគ្រប់គ្រងសាលារៀន មាតាបិតាសិស្ស បណ្ណារក្ស និងគ្រូបង្រៀន លើកទឹកចិត្តយ៉ាងសកម្ម និងគាំទ្រសិស្សក្នុងការអាន ដោយមិនគិតពីសមត្ថភាពរបស់ពួកគេ<br>- បណ្ណារក្ស និងគ្រូបង្រៀន បានប្រាស្រ័យទាក់ទងជាមួយសិស្សដោយមិនបានដាក់សម្ពាធចំពោះសិស្សក្នុងការអាន ហើយត្រូវទទួលស្គាល់សមត្ថភាពសិស្សគ្រប់គ្នា និងធានាបាននូវបរិយាកាសអានដែលប្រកបដោយសុវត្ថិភាពក្នុងផ្លូវអារម្មណ៍។ |

## ១២.៣ កាលវិភាគបណ្ណាល័យ

ថ្នាក់នីមួយៗមានម៉ោងបណ្ណាល័យយ៉ាងតិច ១ម៉ោងសិក្សាក្នុង ១សប្ដាហ៍ ហើយបណ្ណាល័យក៏ត្រូវបើកឱ្យដំណើរការក្នុងម៉ោងដែលសិស្សសម្រាកចេញលេងផងដែរ ព្រោះជាពេលវេលាដ៏សំខាន់សម្រាប់សិស្សចូលធ្វើសកម្មភាពមានដូចជា ការបត់ផ្កា ការនិទានរឿង ការអានរឿងនិទាន ការអានរឿងស្រាវជ្រាវ ការអានរឿងរូបភាព ការអានសៀវភៅសុខភាព ការផាត់ពណ៌ ការលេងល្បែងសិក្សា សកម្មភាពអប់រំសីលធម៌ ការនាំកុមារលេងដូចជា រៀបរូបភាពប្រណាំងគ្នា (Puzzle) ការលេងល្បែងជីតជ្ជ ការអានរឿងនៅក្នុងថាប់ប្លែត ទូរទស្សន៍ និងកុំព្យូទ័រ។ ក្នុងនេះបណ្ណារក្សក៏អាចប្រើប្រាស់នូវភាពច្នៃប្រឌិត និងភាពទន់ភ្លន់របស់ខ្លួនទៅតាមកម្រិតចំណាប់ចំណូលចិត្តរបស់សិស្ស។

ម៉ោងបណ្ណាល័យ និងម៉ោងអំណានសេរី ត្រូវបានដាក់បញ្ចូលក្នុងតារាងកាលវិភាគបណ្ណាល័យដែលដាក់តាំងបង្ហាញក្នុងបណ្ណាល័យ ដើម្បីអភិវឌ្ឍទម្លាប់អាន អភិវឌ្ឍបំណិនអំណាន ប្រើប្រាស់បណ្ណាល័យសម្រាប់ការសិក្សាស្រាវជ្រាវបង្កើនចំណេះដឹង និងឱ្យសិស្សចេះប្រើប្រាស់សកម្មភាពខ្ចីសៀវភៅទុកសម្រាប់អាននៅផ្ទះ និងសងត្រឡប់មកបណ្ណាល័យវិញផងដែរ។

## ១២.៤ ធនធានបណ្ណាល័យ

សម្ភារៈអំណានផ្សេងៗ ដែលស្របតាមកម្រិតនៃការអានរបស់សិស្សត្រូវបានផ្តល់ជូន និងសកម្មភាពសិក្សាតាមបែបសិស្សមជ្ឈមណ្ឌលក៏ត្រូវបានអនុវត្តផងដែរ ដើម្បីធានាថា សិស្សទាំងអស់បានចូលរួម និងជោគជ័យក្នុងការអាន ដោយមិនគិតអំពីភេទ ឬសមត្ថភាព។ បណ្ណារក្ស គ្រូបង្រៀន និងមាតាបិតាសិស្សគប្បីលើកទឹកចិត្តសិស្សក្នុងការអានដើម្បីបង្កើនចំណេះដឹង។

### ក) ការកំណត់សម្ភារៈបណ្ណាល័យ

| ធនធានសៀវភៅ | សង្ហារិម | សម្ភារៈជំនួយផ្សេងៗ |
|---|---|---|
| បណ្ណាល័យជាអគារ | | |
| - *សមាមាត្រសិស្ស ១នាក់ស្មើ៣ ឬ៥ ក្បាល* | - ធ្នើរសៀវភៅមុខ២ = ៤ធ្នើរ<br>- ធ្នើរសៀវភៅមុខ១ = ២ធ្នើរ<br>- តុសិស្សអាន = ៤តុ | - សម្ភារៈទ្រទ្រង់ការងាររដ្ឋបាលសៀវភៅ |

| | | |
|---|---|---|
| - *មានសៀវភៅយ៉ាងតិច ៥០០ ចំណងជើង*<br>- *មានសៀវភៅយ៉ាងតិច ១០០ ក្បាល* | - តុបណ្ណារក្ស = ១តុ<br>- កៅអីបណ្ណារក្ស = ២កៅអី<br>- ខ្នាតធ្នើរមុខពីរ (៤ថ្នាក់ = ១.៤ម x ១.៤ម x ០.៥ម)<br>- ខ្នាតធ្នើរមុខមួយ (៤ថ្នាក់ = ១.៤ម x ១.៤ម x ០.២៧ម) | - កេសឡាំងដែក១ ឬទូរសម្រាប់រក្សាទុកសៀវភៅ<br>- ហោប៉ៅក្រណាត់ ឬធ្នើរផ្តៅសម្រាប់តាំងសៀវភៅមកដល់ថ្មី<br>- ក្រដាសផ្ទាំងធំអប់រំផ្សេងៗ |
| **បណ្ណាល័យជាបន្ទប់** | | |
| - *សមាមាត្រសិស្ស១នាក់ស្មើ ៣ ឬ៥ក្បាល*<br>- *មានសៀវភៅយ៉ាងតិច ៥០០ ចំណងជើង*<br>- *មានសៀវភៅយ៉ាងតិច ១០០០ ក្បាល* | - ធ្នើរសៀវភៅមុខ២ = ៤ធ្នើរ<br>- ធ្នើរសៀវភៅមុខ១ = ២ធ្នើរ<br>- តុសិស្សអាន = ៤តុ<br>- តុបណ្ណារក្ស = ១តុ<br>- កៅអីបណ្ណារក្ស = ២កៅអី<br>- ខ្នាតធ្នើរមុខពីរ (៤ថ្នាក់ = ១.៤ម x ១.៤ម x ០.៥ម)<br>- ខ្នាតធ្នើរមុខមួយ (៤ថ្នាក់ = ១.៤ម x ១.៤ម x ០.២៧ម) | - សម្ភារៈទ្រទ្រង់ការងាររដ្ឋបាលសៀវភៅ<br>- កេសឡាំងដែក១ ឬទូរសម្រាប់រក្សាទុកសៀវភៅ<br>- ហោប៉ៅក្រណាត់ ឬធ្នើរផ្តៅសម្រាប់តាំងសៀវភៅមកដល់ថ្មី<br>- ក្រដាសផ្ទាំងធំអប់រំផ្សេងៗ |
| បណ្ណាល័យជ្រុងថ្នាក់ | | |
| - ជាសមាមាត្រសិស្ស១នាក់<br>- ស្មើ៣ ឬ៥ក្បាល<br>- មានសៀវភៅយ៉ាងតិច ៥០ ចំណងជើង ក្នុង១បន្ទប់<br>- មានសៀវភៅយ៉ាងតិច ១០០ ក្បាល ក្នុង១បន្ទប់ | - ធ្នើរសៀវភៅមុខ១ = ១ធ្នើរ ក្នុងបន្ទប់រៀន<br>- | - សម្ភារៈទ្រទ្រង់ការងាររដ្ឋបាលសៀវភៅ<br>- កេសឡាំងដែក១ ឬទូរសម្រាប់រក្សាទុកសៀវភៅ<br>- ហោប៉ៅក្រណាត់ ឬធ្នើរផ្តៅសម្រាប់តាំងសៀវភៅមកដល់ថ្មី<br>- ក្រដាសផ្ទាំងធំអប់រំផ្សេងៗ |

### ខ) បណ្ណាល័យឌីជីថល

បណ្ណាល័យនេះ គឺជាបណ្ដុំឯកសារទាំងអស់ត្រូវបានរក្សាទុកជាទម្រង់ឌីជីថល ហើយទម្រង់ឯកសារទាំងនេះអាចប្រើប្រាស់បានតាមប្រព័ន្ធទូរស័ព្ទដៃវៃឆ្លាត ទូរទស្សន៍វៃឆ្លាត ថាប់ប្លែត និងកុំព្យូទ័រ ជាដើម សម្រាប់អាន ឬមើល ដែលងាយប្រើប្រាស់ និងចំណេញពេលវេលាទៀតផង។

| | |
|---|---|
| ឯកសារអត្ថបទ | មាន សម្រង់អត្ថបទ របាយការណ៍ សៀវភៅទាំងមូល (E-Books និង PDF Books) សៀវភៅសរសេរដោយដៃ និក្ខេបបទ និងរបាយការណ៍បច្ចេកទេស។ |
| ឯកសារសោតទស្សន៍ (វីដេអូឯកសារ សំឡេង) | មាន វីដេអូឯកសារ ខ្សែភាពយន្ត និងតន្ត្រី សម្រាប់សិស្សពិបាកក្នុងការមើលសិក្សាស្រាវជ្រាវ។ |
| ព័ត៌មានភូមិសាស្ត្រ | មាន ផែនទី ផែនទីថតពីអាកាស រូបភាពបង្ហាញទីតាំង។ |
| រូបភាព និងក្រាហ្វិច | មាន រូបគំនូរ និងរូបថតជាទម្រង់ 2D ឬ 3D ជាដើម។ |

# ឯកសារយោង

- ✓ ការអប់រំបញ្ចូលគ្នាសម្រាប់កុមារពិការ ឆ្នាំ២០០៩
- ✓ ការអប់រំបញ្ចូលគ្នា ឆ្នាំ២០១២
- ✓ ឯកសារស្តីពីការអប់រំបរិយាបន្ន សម្រាប់គ្រូឧទ្ទេស ឆ្នាំ២០១៧
- ✓ ស្តង់ដារបណ្ណាល័យបឋមសិក្សា ឆ្នាំ២០១១
- ✓ ឯកសារណែនាំប្រតិបត្តិស្តីពីបណ្ណាល័យបឋមសិក្សា ឆ្នាំ២០២១
- ✓ ការអប់រំកុមារមានពិការភាពសតិបញ្ញា ឆ្នាំ២០១៨
- ✓ វិន័យវិជ្ជមាន និងការគ្រប់គ្រងថ្នាក់រៀនឱ្យមានប្រសិទ្ធភាព (សៀវភៅណែនាំគ្រូបង្រៀនថ្នាក់បឋមសិក្សា)
- ✓ ឯកសារណែនាំប្រតិបត្តិកម្មវិធីសិក្សាអប់រំពិសេស នាយកដ្ឋានអប់រំពិសេស ឆ្នាំ២០២២
- ✓ កម្មវិធីសិក្សាលម្អិតភាសាខ្មែរ កម្រិតបឋមសិក្សា ឆ្នាំ២០១៨
- ✓ ការបង្រៀនសិស្សមានបញ្ហាបញ្ញានៅក្នុងថ្នាក់អប់រំបញ្ចូលគ្នា
- ✓ ការចុះប្រមូលព័ត៌មាននៅវិទ្យាល័យអប់រំពិសេស នាយកដ្ឋានអប់រំពិសេស និងវិទ្យាស្ថានជាតិអប់រំពិសេស
- ✓ School and Classroom Disabilities Inclusion Guide ( RTI International )